ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 13-Jun-2013, 15:50
CMS/CFO: Sann Rada

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៣**

**ម៉ោង ០៩:០៦នាទី**

**សវនាការលើកទី១៩៦**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក ដាវ អានសាន

កញ្ញា ហ្វៃហ្សា ស៊ូអាគ្រី
*(Ms. Faiza ZOUAKRI)*

លោកស្រី មីរាម ម៉ាហ្វេសសាន់ទិ
*(Ms. Miriam MAFESSANTI)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

កញ្ញា សុង ឆវ័ន្ត

លោក ថារីក អាប់ឌុលឡាក់
*(Mr. Tarik ABDULHAK)*

លោក រេយ៍ន័រ ឃីត*(Mr. Keith RAYNOR)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក វ៉ិចទ័រ កូប៉េ*(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក  គង់ សំអុន

លោក អាកទួរ វែកគែន

*(Mr. Arthur VERCKEN)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោក ពេជ អង្គ

លោកស្រី ស៊ីន សុវ៉ន

លោក ឡៅ ជុនធី

លោក ហុង គឹមសួន

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី សួ សុទ្ធាវី

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក ឃីត វេយ៍ន័រ | អង់គ្លេស |
| លោក គង់ សំអុន | ខ្មែរ |
| លោក អាកទួរ វែកគែន | បារាំង |
| លោក រ៉ិចទ័រ កូប៉េ | អង់គ្លេស |
| លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត | បារាំង |
| លោក ពេជ អង្គ | ខ្មែរ |
| លោក ទន់ សឿន (TCW-742) | ខ្មែរ |
| លោកស្រី សូ សុជាតិ (TCW-673) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក ឆន់ សឿន** (TCW-742)

សួរដោយប្រធានអង្គជំនុំ ផ្តើមពី ........................................ទំព័រ ២
សួរដោយលោក គង់ សំអុន ផ្តើមពី ........................................ទំព័រ ៤
សួរដោយលោក ឃីត រេយ៍ន័រ ផ្តើមពី........................................ទំព័រ ១៥
សួរដោយលោក ពេជ អង្គ ផ្តើមពី ........................................ទំព័រ ៣២

**ការសួរសំណួរទៅសាក្សី៖ លោកស្រី សូ សុជាតិ** (TCW-673)

សួរដោយប្រធានអង្គជំនុំ ផ្តើមពី ........................................ទំព័រ ៣៧
សួរដោយលោក អាកទូរ វែកគែន ផ្តើមពី ........................................ទំព័រ ៣៩

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៦:១១]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។

នៅថ្ងៃនេះអង្គជំនុំជម្រះធ្វើសវនាការស្ដាប់សក្ខីកម្មចំនួនពីររូប គឺសាក្សីទី១ដែលមានរហស្សនាម TCW-742 ហើយនិងសាក្សីទី២ – 673 បាទ។

លោក ដាវ អានសាន ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ!

**ក្រឡាបញ្ជី៖**

សូមគោរពជម្រាបលោកប្រធាន។ នៅក្នុងសវនាការនៅថ្ងៃនេះ គ្រប់ភាគីនៃរឿងក្ដីមានវត្តមាន ដោយឡែកជនជាប់ចោទ នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ តាមសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដោយសារមូលហេតុមានបញ្ហាសុខភាព។

ដូចដែលលោកប្រធានបានជម្រាបជូនអង្គសវនាការកាលអម្បាញ់មិញនេះ សវនាការតាមការគ្រោងទុកនៅព្រឹកនេះ គឺស្ដាប់សក្ខីកម្មរបស់សាក្សីដែលមានរហស្សនាម TCW-742 និងពេលរសៀល គឺស្ដាប់សក្ខីកម្មរបស់សាក្សីTCW-673 ទៅលើផ្នែកនៃអង្គហេតុពាក់ព័ន្ធនឹងអត្តចរិតរបស់ជនជាប់ចោទ ខៀវ សំផន។

[០៩:០៧:៥២]

សាក្សីដែលមានរហស្សនាម TCW-742 បានបញ្ជាក់ផងដែរថា គាត់មានចំណងញាតិពន្ធជាមួយនឹងលោកជនជាប់ចោទ ខៀវ សំផន។ ប៉ុន្តែតាមសមត្ថភាពអាចដឹងគឺមិនមានជាប់ចំណងញាតិលោហិត ឬញាតិពន្ធជាមួយនឹងភាគីផ្សេងទៀតនៃរឿងក្ដីនេះទេ។

យោងតាមវិធាន២៤ អនុវិធាន២ នៃវិធានផ្ទៃក្នុងសាក្សីទាំងពីររូបនេះមិនចាំបាច់ -- សាក្សីដែលរហស្សនាម TCW-742 នេះមិនចាំបាច់ធ្វើសម្បថចំពោះសក្ខីកម្មពាក់ព័ន្ធនឹងជនជាប់ចោទ ខៀវ សំផន ឡើយ។ ប៉ុន្តែសាក្សីបានធ្វើសម្បថនៅចំពោះមុខលោកតាដំបងដែកកាលពីព្រឹកមិញនេះ ចំពោះសក្ខីដែល

ពាក់ព័ន្ធនឹងជនចាប់ចោទរូបលោក នួន ជា។ សាក្សីរូបនេះមានវត្តមានរួចហើយ រង់ចាំការកោះហៅពីអង្គជំនុំជម្រះ។ នៅព្រឹកនេះមានសាក្សីបម្រុងដែលមានរហស្សនាមៗ TCW-648។

បាទអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយមន្ត្រីរដ្ឋបាលតុលាការ អញ្ជើញសាក្សី TCW-742 ចូលមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ!

*(សាក្សីចូលក្នុងបន្ទប់សវនាការ)*

[០៩:១០:២០]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** អរុណសួស្តីលោកសាក្សី តើលោកឈ្មោះអី?

**លោក ទន់ សឿន៖**

**ឆ៖** ខ្ញុំឈ្មោះ ទន់ សឿន។

**ស៖** បាទ អរគុណលោក ទន់ សឿន។ តើលោកអាយុប៉ុន្មានឆ្នាំហើយ?

**ឆ៖** *(ឮមិនច្បាស់)* ឆ្នាំលោកប្រធាន។

**ស៖** ម្តងទៀត តើលោកមានអាយុប៉ុន្មានឆ្នាំ?

លោក ទន់ សឿន កុំអាលទាន់ឆ្លើយតបនឹងសំណួរ ស្តាប់សំណួរសិន ហើយអាចផ្អាកបន្តិចរហូតដល់ក្បាលមីក្រូហ្វូននៅចំពោះមុខលោកនុំងប្រតិបត្តិការឲ្យសញ្ញាភ្លើងក្រហមនៅពីមុខ នៅទីនេះក៏ដូចជានៅក្បាលមីក្រូហ្វូនក៏ដូចជាលើប៊ូតុង ដែលចុចហ្នឹងឲ្យសញ្ញាក្រហម មានន័យថា ក្បាលមីក្រូហ្វូនហ្នឹងប្រតិបត្តិការហើយ។ អ៊ីចឹងលោកអាចនិយាយទៅសំឡេងលោកនឹងចែកចាយដល់ភាគីពាក់ព័ន្ធនៃរឿងក្តីសាធារណជន ក៏ដូចជាសម្រាប់ដល់អង្គភាពបកប្រែភាសាដើម្បីបកប្រែភាសារបស់លោកទៅជាពីរភាសាផ្សេងទៀត។ ភាសាអង់គ្លេស និងភាសាបារាំងណា៎។

សព្វថ្ងៃនេះតើលោករស់នៅទីកន្លែងណា?

[០៩:១១:៣៤]

**ឆ៖** ខ្ញុំនៅប៉ៃលិន។

**ស៖** បាទ អរគុណ។ ហើយលោក សឿន តើប្រកបមុខរបរអី?

**ឆ៖** ខ្ញុំធ្វើចម្ការ។

**ស៖** អរគុណ។ ឪពុកបង្កើតរបស់លោកឈ្មោះអី? ហើយម្ដាយបង្កើតរបស់លោកឈ្មោះអី?

**ឆ៖** ឪពុកខ្ញុំឈ្មោះ ទន់ សុំ។ ម្ដាយឈ្មោះ កង សេង។

**ស៖** អរគុណ។ ហើយចុះប្រពន្ធរបស់លោកគាត់ឈ្មោះអី? ហើយលោកមានកូនប៉ុន្មាននាក់?

**ឆ៖** ប្រពន្ធខ្ញុំឈ្មោះ ខៀវ រតនា។ កូនមានបីនាក់។

[០៩:១២:២៣]

**ស៖** បាទ អរគុណ។ ហើយលោក ទន់ សឿន តាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការអម្បាញ់មិញនេះ ថាលោកត្រូវជាញាតិពន្ធជាមួយនឹងជនជាប់ចោទ ខៀវ សំផន ហើយលោកមិនជាប់ញាតិលោហិត ឬញាតិពន្ធជាភាគីដទៃទៀតនៃរឿងក្ដីនេះទេ។

សំណួរ ថាតើលោកត្រូវជាម៉េចជាមួយនឹងលោក ខៀវ សំផន?

**ឆ៖** ជាកូនប្រសា លោកប្រធាន។

**ស៖** បាទ អរគុណ ហើយចំពោះភាគីដទៃទៀតនៃរឿងក្ដីមានជនជាប់ចោទ នួន ជា ផងដែរគឺថា របាយការណ៍របស់ក្រឡាបញ្ជីថា លោកមិនមានជាប់លោហិត ឬញាតិពន្ធជាមួយនឹងបុគ្គលដទៃទៀតដែលទទួលយកជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងរឿងក្ដីនេះទេ ហើយក៏មិនជាប់ញាតិលោហិត ឬក៏ញាតិពន្ធជាមួយនឹងលោក នួន ជា ផងដែរ។ ហើយលោកបានធ្វើសម្បថរួចហើយក្នុងករណីនេះ នៅមុនពេលចូលមកផ្ដល់សក្ខីកម្មនេះ ក្នុងករណីរលោកត្រូវឆ្លើយតបទៅនឹងសំណួរដែលសួរឡើងដោយពាក់ព័ន្ធទៅនឹងករណីលោក នួន ជា។ តើពិតមែនទេ?

[០៩:១៣:២៨]

**ឆ៖** បាទ លោកប្រធាន។

**ស៖** លោក ទន់ សឿន ក្នុងនាមលោកជាសាក្សីដែលត្រូវផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះនេះ គឺលោកមានសិទ្ធិបដិសេធទៅនឹងសំណួរ ឬក៏សូមឲ្យលោកធ្វើអត្ថាធិប្បាយ ឬអំណះអំណាងណាមួយឬច្រើន ដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង។ សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង។ ហើយក្នុងករណីនេះ គឺអង្គជំនុំជម្រះបានធ្វើការបញ្ជោនេះជាមួយនឹងអង្គភាពគាំពារសាក្សីនិងអ្នកជំនាញ ក្នុងការផ្ដល់នូវមេធាវីប្រឹក្សានៅជិតលោកនេះរួចហើយ ក្នុងករណីមានសំណួរណាដែលមានទម្រង់ថាដាក់

ពិរុទ្ធភាពលើខ្លួនលោក ដើម្បីឲ្យលោកឆ្លើយតប គឺលោកពិភាក្សាជាមួយនឹងមេធាវីរបស់លោក ដើម្បីលោកថាប្រើសិទ្ធិឆ្លើយតប ឬក៏មិនឆ្លើយតប។

ហើយក្នុងករណី -- អំពីករណីយកិច្ច ក្នុងនាមលោកជាសាក្សីត្រូវឆ្លើយតបទៅនឹងសំណួរទាំងឡាយដែលភាគី ឬក៏ចៅក្រមនៃអង្គជំនុំជម្រះសួរលោក។ ហើយលោកត្រូវតែឆ្លើយតែការណ៍ណាដែលពិត ដែលលោកបានដឹង បានឮ បានឃើញដោយផ្ទាល់ ឬក៏បានមានបទពិសោធន៍ជួបប្រទះ ឬក៏ធ្វើការសង្កេតនៅព្រឹត្តិហេតុ ឬហេតុការណ៍ទាំងឡាយដែលពាក់ព័ន្ធនឹងសំណួរដែលសួរ គឺភាគី និងចៅក្រមដែលនឹងសួរលោក។ លោក ទន់ សឿន តើលោកដែលធ្លាប់ផ្តល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេ កន្លងមកនេះ?

**ឆ៖** អត់មានទេ។

[០៩:១៥:០៩]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយក្នុងការសួរដេញដោលសាក្សីរូបនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន មានឱកាសតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះមុនភាគីដទៃទៀតនៃរឿងក្តី។ ហើយសូមជម្រាបផងដែរថាសាក្សី -- មេធាវីការពារក្តីលោក ខៀវ សំផន រួមនឹងមេធាវីការពារក្តីលោក នួន ជា ក្នុងការសួរសាក្សីរូបនេះមានរយៈពេល១ម៉ោង១៥នាទីបាទ។

សូមអញ្ជើញ!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ សូមគោរពក្រុមប្រឹក្សាជំនុំជម្រះ។ សូមគោរពអង្គសវនាការទាំងមូល។

[០៩:១៥:៤១]

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក គង់ សំអុន៖**

**ស៖** សូមជម្រាបសួរលោក ទន់ សឿន។ ខ្ញុំឈ្មោះ គង់ សំអុន ជាមេធាវីរបស់លោក ខៀវ សំផន។ ហើយតទៅនេះខ្ញុំមានសំណួរមួយចំនួនដើម្បីឲ្យលោកជួយឆ្លើយបញ្ជាក់។ ជាដំបូងលោកអាចបញ្ជាក់ពីការអប់រំរបស់លោកបានទេ លោករៀនសូត្របានប៉ុន្មានឆ្នាំដែរ?

**លោក ទន់ សឿន៖**

**ឆ៖** ខ្ញុំរៀនបាន ១ឆ្នាំកន្លះ។

**ស៖** លោករៀនអីគេ?

**ឆ៖** រៀនអក្សរសាស្ត្រខ្មែរ និងគណិត។

**ស៖** លោករៀននៅឯណា?

**ឆ៖** រៀននៅជំនាន់កម្ពុជាប្រជាធិបតេយ្យ។

**ស៖** លោករៀននៅទីកន្លែងណាដែរ?

**ឆ៖** ខ្ញុំរៀននៅសាលាបឋមសិក្សា នៅជិតវត្តស្វាយពពៃ។

**ស៖** បាទ សូមអរគុណ។ ទាក់ទងនឹងការងាររបស់លោក តើលោកបានធ្វើកិច្ចការអីខ្លះពីរយៈពេលកន្លងមក? លោកអាចបញ្ជាក់ពីការងារសំខាន់ៗរបស់លោក?

**ឆ៖** សូមទោស! លោកចៅក្រមចង់សួរពីឆ្នាំណាដល់ឆ្នាំណា?

**ស៖** បាទការងារដំបូងរបស់លោកៗធ្វើជាអ្វីដែរ? ពីឆ្នាំណាដែលលោកចាប់ផ្តើមធ្វើហ្នឹង លោកអាចបញ្ជាក់មកពីអាចក្នុងសម័យមុន៧៥ ឬក៏ក្រោយ៧៥ ឬក៏ក្រោយឆ្នាំ៧៩? លោកបញ្ជាក់តាមពេលវេលាមក?

[០៩:១៧:៣៤]

**ឆ៖** កាលពីដើមឡើយ ឆ្នាំ៧៧ ខ្ញុំបានរៀននៅសាលាបឋមសិក្សាមួយនៅក្បែរវត្តស្វាយពពៃរយៈពេល១ឆ្នាំកន្លះ។ ក្រោយមកបានខ្ញុំផ្លាស់កន្លែងទៅនៅមួយកន្លែងទៀតដែលនៅក្រុមលោកដែលឈ្មោះ ផង់ អាហ្នឹង៧៨។

**ស៖** លោកនៅកន្លែងឈ្មោះ ផង់ ហ្នឹង លោកនៅរៀន ឬមួយក៏លោកធ្វើការងារ?

**ឆ៖** ខ្ញុំនៅរៀនៗវ៉ៃអង្គុលីលេខ។

**ស៖** លោកអាចបញ្ជាក់សាជាថ្មីបានទេ ឆ្នាំណាដែល ដែលលោកនៅរៀនវ៉ៃអង្គុលីលេខហ្នឹង?

**ឆ៖** ចុងឆ្នាំ៧៨។

**ស៖** លោករៀននៅកន្លែងវាយអង្គុយលីលេខហ្នឹងរយៈពេលប៉ុន្មានខែប៉ុន្មានឆ្នាំដែរ?

**ឆ៖** ប្រហែលជាបីបួនខែ។

**ស៖** លោកស្គាល់ទីតាំងច្បាស់លាស់ទេថាជាកន្លែងអ្វី នៅកន្លែងណា?

**ធ៖** ខ្ញុំដឹងថាទីតាំងហ្នឹងនៅកន្លែងឈ្មោះក-៣។

**ស៖** បាទ សូមអរគុណ។ លោកអាចបញ្ជាក់បានទេថាមុនឆ្នាំ៧៥ លោកនៅឯណាដែរ?

**ធ៖** ខ្ញុំឆ្នាំ៧៥ ខ្ញុំនៅជាមួយឪពុកម្តាយ នៅឯស្រុកទន្លេបាទី។

[០៩:២០:០២]

**ស៖** ចុះម៉េចបានជាលោកបានចូលមកភ្នំពេញនៅក-៣ហ្នឹង?

**ធ៖** ដំបូងខ្ញុំមកចូលក្នុងជួរកុមារនៅកងទ័ព នៅខេត្តកំពង់ស្ពឺជាមួយបងប្រុស។

**ស៖** បាទ ហើយម៉េចទៀត?

**ធ៖** ក្រោយមកបានគេជ្រើសរើសកុមារឡើងមកភ្នំពេញ។

**ស៖** នៅឆ្នាំណាដែរ ដែលគេជ្រើសរើសកុមារនាំមកភ្នំពេញហ្នឹង?

**ធ៖** ឆ្នាំ៧៦។

**ស៖** លោកចាំខែទេ?

**ធ៖** ប្រហែលជាចុងឆ្នាំ៧៦ ខែ៧ ខែ៨។

**ស៖** ពេលនោះលោកអាយុប៉ុន្មានឆ្នាំដែរ?

**ធ៖** ខ្ញុំមានអាយុ១១ឆ្នាំ។

**ស៖** លោកចេញពីកំពង់ស្ពឺមកភ្នំពេញតាមការជ្រើសរើសហ្នឹង ដំបូងមកដល់ភ្នំពេញហ្នឹងលោកនៅកន្លែងណា?

**ធ៖** ខ្ញុំមកនៅកន្លែងរដ្ឋសភាសព្វថ្ងៃ។

**ស៖** គេហៅស្អីគេដែរ កន្លែងនុ៎ង?

**ធ៖** កន្លែងហ្នឹងគេហៅកន្លែងសភា ជំនាន់ហ្នឹងគេហៅសភា។

**ស៖** នៅពេលលោកមកដល់កន្លែងសភាហ្នឹង តើគេឲ្យលោកធ្វើអីដែរ?

[០៩:២២:២៧]

**ធ៖** ការងាររបស់ខ្ញុំជំនាន់ហ្នឹង គេឲ្យជាអ្នកសម្អាតកន្លែងទីធ្លាជុំវិញរដ្ឋសភា និងការបោសសម្រាម និងជម្រះស្មៅកាត់ស្មៅ ថែសួន។

**ស៖** លោកនៅកន្លែងរដ្ឋសភាហ្នឹងរយៈពេលប៉ុន្មាន?

**ធ៖** ប្រហែលជា២ឬ៣ខែ។

**ស៖** មានអ្នកណាផ្សេងទៀតនៅក្នុងក្រុមរបស់លោកហ្នឹងដែរទេ?

**ឆ៖** មានពួកម៉ាកខ្ញុំ២០នាក់ ប៉ុន្តែបែកគ្នាអស់ហើយ។

**ស៖** ចុះពេលដែលលោកចេញពីមន្ទីររដ្ឋសភាហ្នឹង លោកទៅណាវិញ?

**ឆ៖** ខ្ញុំបានទៅមន្ទីរមួយឈ្មោះហៅ ក-៨ កន្លែងបង្កបង្កើនផល។

**ស៖** នៅកន្លែងណាដែរ ក-៨ហ្នឹង?

**ឆ៖** នៅជិតស្ពានទូតរុស្ស៊ីសព្វថ្ងៃ នៅខាងត្បូង ដីទំនាបមាត់ទន្លេ។

**ស៖** អ្នកណាជាអ្នកគ្រប់គ្រងលោកដែរនៅពេលនោះ?

**ឆ៖** ឈ្មោះ ពូតាំង ប្រធានមន្ទីរ។

[០៩:២៤:២៨]

**ស៖** លោកនៅយូរទេ នៅក-៨ហ្នឹង?

**ឆ៖** នៅមួយរយៈ ខ្ញុំមិនដឹងជាប៉ុន្មានខែទេ។

**ស៖** លោកមានធ្វើអ្វីផ្សេងក្រៅពីការងារដាំដុះទេ?

**ឆ៖** អត់មាន។

**ស៖** ចុះលោកចេញពីក-៨ហ្នឹង នៅពេលណា?

**ឆ៖** ខ្ញុំចេញដើម៧៧ ទៅរៀននៅសាលាបឋមសិក្សាជិតវត្តស្វាយពពែ -- វត្តស្វាយពពែហ្នឹង។

**ស៖** អាហ្នឹងជាកន្លែងដែលលោកបានបញ្ជាក់ថា លោករៀនអក្សរសាស្ត្រនៅទីនោះមែនទេ?

**ឆ៖** បាទ។

**ស៖** លោកមានរៀនអ្វីផ្សេងក្រៅពីអក្សរសាស្ត្រទេ នៅកន្លែងជិតវត្តស្វាយពពែហ្នឹង?

**ឆ៖** អត់មានក្រៅពីរៀនអក្សរសាស្ត្រ និងគណិតទេ។

[០៩:២៥:៥៨]

**ស៖** មានអ្នករៀនប៉ុន្មាននាក់ដែរ ជាមួយលោកហ្នឹង?

**ឆ៖** ប្រហែលជា៣០នាក់។

**ស៖** អ្នកណាអ្នកបង្រៀនលោក?

**ឆ៖** គឺឈ្មោះ ផង់។

**ស៖** មានអ្នកផ្សេងទៀតទេ អ្នកបង្រៀន?

ផ៖ មានឈ្មោះ បងជន។

ស៖ អស់ហើយ នៅមានទៀត?

ផ៖ អស់ហើយ។

ស៖ លោករៀនរយៈពេលប៉ុន្មាននៅជិតវត្តស្វាយពពៃហ្នឹង?

[០៩:២៧:០២]

ផ៖ ខ្ញុំរៀន១ឆ្នាំកន្លះជាង។

ស៖ រហូតដល់ពេលណា ទើបលោកចេញពីវត្តស្វាពពៃ?

ផ៖ ម្តុំខែ៦ ខែ៧, ៧៨។

ស៖ ហើយលោកចេញទៅណាវិញ?

ផ៖ ទៅនៅ ក-៣។

ស៖ លោកមានតួនាទីអីដែរ នៅក-៣ ហ្នឹង?

ផ៖ ខ្ញុំជាកុមារធម្មតា រៀនខាងវ៉ៃអង្គុលីលេខ។

ស៖ ចុះអ្នកផ្សេងទៀត?

ផ៖ អ្នកផ្សេងទៀតគេមានការងារ ប៉ុន្តែព្រោះគេ ពួកគេចាស់ជាងខ្ញុំ។

ស៖ លោកចាំថានៅកន្លែងវាយអង្គុលីលេខនៅក-៣ ហ្នឹងមានគ្នាប៉ុន្មាននាក់ដែរ?

ផ៖ ប្រហែលជាជាង១០នាក់។

ស៖ ការងាររបស់លោកក្នុងការវាយអង្គុលីលេខហ្នឹង វាយប្រភេទឯកសារអ្វីដែល លោកអាចបញ្ជាក់បានទេ?

[០៩:២៩:០៦]

ផ៖ រៀបវ៉ៃធម្មតា។ យកទស្សនាវដ្តីយកអីមករៀនវ៉ៃ ដើម្បីឲ្យស្ទាត់។

ស៖ បាទ។ មានវាយឯកសារជាប្រភេទជាសារទំនាក់ទំនងគ្នាទេ?

ផ៖ អត់មានទេ។

ស៖ នៅពេលដែលលោកនៅ ក-៣ហ្នឹង ការស្នាក់នៅរបស់លោកនៅកន្លែងណា?

ផ៖ នៅផ្ទះមួយនៅកៀនខាងកើត ឆៀងខាងជើងនៃមន្ទីរ ក-៣។ ហើយជំនាន់នោះគេហៅថាដូចកុងស៊ុលរបស់សាំងហ្គាពួ ខ្ញុំមិនសូវច្បាស់ដែរ ប៉ុន្តែគ្រាន់តែឮគេនិយាយអ៊ីចឹង។ នៅស្នាក់ក្នុងផ្ទះនុ៎ង។

**ស៖** នរណាជាមេផ្ទាល់របស់ក្រុមលោកនៅពេលនុ៎ង?

**ឆ៖** ពូ ផង់។

**ស៖** បាទ អ៊ីចឹង ផង់ ដដែល ដែលបង្រៀនអក្សរលោកនៅជិតវត្តស្វាយពពៃហ្នឹងមានទេ?

**ឆ៖** បាទ។

**ស៖** លោកដឹងពីស្ថានភាពរស់នៅ នៅទីនោះយ៉ាងម៉េចដែរ លោកអាចបញ្ជាក់បានទេពីការហូប ចុក ឬក៏ពីកន្លែងធ្វើការងារ កន្លែងរៀនសូត្ររបស់លោកហ្នឹង?

[០៩:៣១:១៥]

**ឆ៖** ជីវភាពធម្មតា បានហូបបាយ។ កន្លែងធ្វើការ ធ្វើនៅ -- កន្លែងរៀនហ្នឹងនៅកន្លែងដេក មានបន្ទប់ កន្លែងដាក់អង្គុលីលេខសម្រាប់រៀនវ៉ៃ។

**ស៖** លោកនៅក-៣ ហ្នឹងរយៈពេលប៉ុន្មានដែរ?

**ឆ៖** ប្រហែលជាបីបួនខែប៉ុណ្ណោះ នៅពេលវៀតណាមចូលមកក៏ខ្ញុំជម្លៀសចេញ។

**ស៖** នៅក-៣ លោកមានបានជួបអ្នកណាខ្លះទេ ដែលជាថ្នាក់ដឹកនាំធំៗរបស់កម្ពុជាប្រជា-ធិបតេយ្យ?

**ឆ៖** អត់ដែលជួប។

**ស៖** លោកដែលជួបលោក ខៀវ សំផន ទេ នៅក-៣ ហ្នឹង?

**ឆ៖** អត់ដែលជួបគាត់ទេ។

**ស៖** បាទ សូមអរគុណ។ នៅពេលណាដែលលោកស្គាល់លោក ខៀវ សំផន បានជួបមុខលោក ខៀវ សំផន?

**ឆ៖** ខ្ញុំជួបគាត់នៅសម័យតស៊ូត្រីភាគី។

**ស៖** លោកអាចបញ្ជាក់ខែ ឬក៏ឆ្នាំបានទេ នៅពេលណាពិតប្រាកដដែលលោកបានជួប?

**ឆ៖** ឆ្នាំ៨២។

[០៩:៣៣:២៨]

**ស៖** លោកមានតួនាទីជាអីនៅពេលហ្នឹង?

**ឆ៖** ពេលហ្នឹង ខ្ញុំធ្វើការបកសារ បកប្រែជា គេហៅបកសារ -- បកប្រែ។

**ស៖** លោកធ្វើការយ៉ាងដូចម្ដេចដែរជាមួយលោក ខៀវ សំផន លោកអាចបញ្ជាក់បានទេពី

ការងារដែលោកធ្វើ ឬក៏ពីទំនាក់ទំនងរបស់លោកជាមួយនឹងលោក ខៀវ សំផន នៅឆ្នាំ១៩៨២?

**ផ៖** ខ្ញុំជាអ្នកនាំសារជូនគាត់ទៅ ទទួលសារតាំងនៅស្រុកម៉ាឡៃ។

**ស៖** ញឹកញាប់ប៉ុនណាដែរ លោកអាចបញ្ជាក់បានទេ?

**ផ៖** នៅពេលទូតប្រទេសនានាដែលមកប្រគល់សារតាំងថ្វាយសម្ដេចឳ។

[០៩:៣៥:០៣]

**ស៖** តើលោកធ្វើការជាប់ជាមួយលោក ខៀវ សំផន រហូតដល់ពេលណា?

**ផ៖** ខ្ញុំនៅក្រោមការគ្រប់គ្រងរបស់លោក ផង់ ប៉ុន្តែពេលមានបេសកកម្ម ខ្ញុំធ្វើដំណើរទៅជាមួយគាត់។

**ស៖** លោកអាចបញ្ជាក់ពីឆ្នាំណាដល់ឆ្នាំណាដែរ ដែលលោកធ្វើការពេលមានបេសកកម្មទៅជាមួយគាត់ហ្នឹង?

**ផ៖** ពី៨២ ដល់ ៨៣។

**ស៖** មានរយៈពេលណាទៀតទេ ដែលលោកធ្វើការជាមួយលោក ខៀវ សំផន?

**ផ៖** ពេលនោះខ្ញុំបែកពីគាត់ ខ្ញុំមានភារកិច្ចទៅស្រុកបារាំង។

**ស៖** ឆ្នាំណាដែលលោកពេលដែលលោកបែកពីលោក ខៀវ សំផន ទៅ?

**ផ៖** ចុង ៨៣។

**ស៖** រហូតដល់ពេលណាទើបលោកជួបគាត់វិញ?

**ផ៖** ៨៩។

[០៩:៣៧:១០]

**ស៖** នៅពេលដែលលោកជួបលោក ខៀវ សំផន នៅឆ្នាំ១៩៨៩ ហ្នឹងលោកមានតួនាទីជាអីដែរ?

**ផ៖** ខ្ញុំនៅជាអ្នកបក -- នាំសារដដែល។

**ស៖** នាំសារឲ្យអ្នកណាគេ?

**ផ៖** ជូនលោក ខៀវ សំផន។

**ស៖** រហូតដល់ពេលណាដែរ ដែលការងារនាំសាររបស់លោកនេះ?

**ផ៖** ដល់ឆ្នាំ៩០ ខ្ញុំត្រូវមានភារកិច្ចទៅនៅស្ថានទូតនៅប៉េកាំង។

**ស៖** អ៊ីចឹងលោកចេញពីស្រុកខ្មែរទៅប៉េកាំង។ ហើយលោកនៅប៉េកាំងរយៈពេលប៉ុន្មានឆ្នាំទៅ?

**ឆ៖** ខ្ញុំនៅដល់៩១។

**ស៖** នៅពេលដែលលោកត្រឡប់នៅដល់៩១ តើលោកត្រឡប់ចូលស្រុកខ្មែរវិញ ឬក៏លោកទៅកន្លែងណាផ្សេងទៀត?

[០៩:៣៨:៥៩]

**ឆ៖** ខ្ញុំត្រឡប់មកស្រុកខ្មែរវិញ។

**ស៖** លោកមានតួនាទីធ្វើអីដែរ នៅពេលត្រឡប់ចូលស្រុកខ្មែរវិញ?

**ឆ៖** ខ្ញុំនៅអង្គភាពចាស់ដដែល។

**ស៖** បាទ កាលពីចាប់ផ្ដើមលោកមកដល់អង្គសវនាការដំបូង លោកបានឆ្លើយបញ្ជាក់ជាមួយលោកប្រធានថាលោកបាន លោកជាកូនប្រសាររបស់លោក ខៀវ សំផន។ តើលោកអាចបញ្ជាក់បាន ទេ តើលោករៀបការនៅឆ្នាំណាដែរ?

**ឆ៖** ខ្ញុំរៀបការនៅខែវិច្ឆិកា ថ្ងៃ០៩, ៩៤។

**ស៖** នៅពេលហ្នឹងលោកមានឋានៈជាអីដែរ?

**ឆ៖** ខ្ញុំជាយុទ្ធជនធម្មតា។

**ស៖** លោកអាចបញ្ជាក់អំពីទំនាក់ទំនងរបស់លោកជាមួយលោក ខៀវ សំផន នៅពេលដែលលោកធ្វើការជាអ្នកនាំសារឲ្យលោក ខៀវ សំផន ថាតើលោកកត់សម្គាល់យ៉ាងដូចម្ដេចដែរចំពោះលោក ខៀវ សំផន ជាលក្ខណៈទូទៅ?

**ឆ៖** អត្តចរិតគាត់គឺស្លូតបូត តែគាត់ឈ្មោះត្រង់ រាបសាជាមួយមហាជន។

**ស៖** លោកដឹងពីការងាររបស់លោក ខៀវ សំផន នៅក្រោយឆ្នាំ១៩៧៩ ដែរទេ?

**ឆ៖** គាត់ជារដ្ឋមន្ត្រីក្រសួងការបរទេសរបស់ត្រីភាគី។

**ស៖** តើលោកដឹងពីទំនាក់ទំនងរបស់លោក ខៀវ សំផន ជាមួយនឹងថ្នាក់ដឹកនាំដទៃទៀតនៃរបបកម្ពុជាប្រជាធិបតេយ្យដែរទេ? ក្រោយឆ្នាំ៧៩ហ្នឹង?

[០៩:៤២:២៦]

**ឆ៖** គាត់ ខ្ញុំដឹង គាត់ទាក់ទងភាគច្រើននៅខាងក្រៅប្រទេសជាមួយសម្ដេចឪ ជាមួយឯកឧត្ដម សឺន សាន។ សំខាន់គាត់ធ្វើការនៅខាងក្រៅប្រទេស។

**ស៖** តើលោកដែលដឹងថាលោក ខៀវ សំផន មានតួនាទីណាមួយក្នុងផ្នែកយោធាទេនៅក្រោយ

ឆ្នាំ១៩៧៩?

**ឆ៖** អត់ទេ។

**ស៖** តើលោកមានដឹងលោក ខៀវ សំផន ជាប់ពាក់ព័ន្ធទៅនឹងការធ្វើសេចក្ដីសម្រេចណាមួយ ទាក់ទងទៅនឹងការប្រតិបត្តិការយោធានៅក្នុងសម័យក្រោយឆ្នាំ១៩៧៩ដែរទេ?

**ឆ៖** អត់ទេ។

[០៩:៤៣:៤៦]

**ស៖** ទាក់ទងទៅនឹងបុគ្គលិកលក្ខណៈរបស់លោក ខៀវ សំផន ដោយផ្ទាល់ ចំណុចល្អអ្វីខ្លះ ដែលលោកសង្កេតឃើញពីអត្តចរិត ពីបុគ្គលិកលក្ខណៈរបស់លោក ខៀវ សំផន ជាលក្ខណៈពិសេសណាមួយដែលធ្វើឲ្យលោកចាប់អារម្មណ៍អំពីលោក ខៀវ សំផន?

**ឆ៖** គឺគាត់ស្មោះត្រង់ ហើយគាត់រាបសា។ គាត់មានការទាក់ទងជាមួយក្រៅប្រទេសច្រើន ជាមួយអាណិកជនខ្មែរ។ គេស្រឡាញ់គាត់។

**ស៖** ចុះទាក់ទងទៅនឹងការសង្កេតរបស់លោក ចំពោះលោការប្រព្រឹត្តរបស់លោក ខៀវ សំផន ចំពោះបុគ្គលិកដទៃទៀត លោកសង្កេតឃើញយ៉ាងដូចម្ដេចដែរ?

**ឆ៖** មិនមានអីឃើញគាត់ជាមនុស្សឃោរឃៅអីទេ។ គាត់ជាមនុស្សស្លូត។

**ស៖** ទាក់ទងទៅនឹងជីវភាពប្រចាំថ្ងៃ អំពីការរស់នៅក្នុងក្រុមគ្រួសារ តើលោកសង្កេតឃើញលោក ខៀវ សំផន យ៉ាងដូចម្ដេចដែរ?

[០៩:៤៥:៤០]

**ឆ៖** ការរស់នៅប្រចាំថ្ងៃសាមញ្ញ។ បើជីវភាពរស់នៅមានអីហូបហ្នឹង។ គាត់មិនមែនជាអ្នករើសអើង ហើយគាត់ខំតែណែនាំកូន។

**ស៖** លោកអាចបញ្ជាក់អំពីថា លោកខៀវ សំផន ណែនាំកូន ខំណែនាំកូនហ្នឹង គាត់ណែនាំ ឬក៏អប់រំយ៉ាងដូចម្ដេចដែរ លោកអាចបញ្ជាក់បានទេ?

**ឆ៖** ឲ្យធ្វើល្អ គោរពច្បាប់ និងខំរកស៊ី បង្កបង្កើនផល។

**ស៖** បាទ ខ្ញុំសូមបញ្ជាក់បន្ថែមទាក់ទងទៅនឹងពេលវេលាដែលលោកបានរស់នៅជាមួយលោក ខៀវ សំផន ថាតើរយៈពេលចុងក្រោយរហូតដល់ពេលដែលលោក ខៀវ សំផន ត្រូវបានចាប់ខ្លួនមកតុលាការនេះ រយៈពេលដែលលោកនៅជិតស្និទ្ធជាមួយនឹងលោក ខៀវ សំផន ហ្នឹងតើរយៈយូរប៉ុន្មាន

ដែរ? ពីពេលណាដល់ពេលណា?

[០៩:៤៧:១៥]

**ផ៖** តាំងពីសមាហរណកម្មមក។

**ស៖** ឆ្នាំណាដែរ?

**ផ៖** ៩៨, ៩៩។

**ស៖** លោករស់នៅជាមួយលោក ខៀវ សំផន ក្រោមដំបូលតែមួយ ឬផ្ទះផ្សេងគ្នា?

**ផ៖** នៅជាមួយគ្នា។

**ស៖** ចុះក្នុងរយៈពេលពីឆ្នាំ៩៤ ក្រោយពេលដែលលោករៀបការមក រហូតមកដល់ឆ្នាំ៩៨ហ្នឹង លោកនៅកន្លែងណាដែរ?

**ផ៖** ខ្ញុំនៅជាអង្គភាព។

**ស៖** នៅពេលហ្នឹង តើលោកមានទំនាក់ទំនងជាលក្ខណៈការងារជាមួយលោក ខៀវ សំផន ដែរទេ?

**ផ៖** អត់ទេ។

**ស៖** បាទ ខ្ញុំសូមត្រឡប់មកនិយាយអំពីអត្តចរិតរបស់លោក ខៀវ សំផន វិញ។ ថាតើក្នុងនាមលោកជាកូនប្រសាររបស់លោកខៀវ សំផន។ លក្ខណៈពិសេសអ្វីខ្លះដែលលោកកត់សម្គាល់ក្នុងទំនាក់ទំនងរវាងញាតិរបស់លោក កូនប្រសាឪពុកក្មេក ដែលលោកគិតថា ជាចំណុចដែលគួរឲ្យចាប់អារម្មណ៍ ជាឪពុកល្អ ឬជាកូនល្អសម្រាប់ក្នុងសង្គមគ្រួសារ។ សូមលោកជួយបញ្ជាក់?

[០៩:៤៩:២១]

**ផ៖** គាត់មិនមានបែងចែកជាកូនប្រសា ជាកូនបង្កើត។ គាត់ស្រឡាញ់ដូចគ្នា។

**ស៖** ចុះសម្រាប់លោកវិញ ក្នុងការប្រព្រឹត្តរបស់លោកចំពោះលោក ខៀវ សំផន។ តើលោកមានការគោរពចំពោះលោក ខៀវ សំផន យ៉ាងដូចម្ដេចដែរ?

**ផ៖** គោរពគាត់ជាឪពុក។

**ស៖** តើលោកមានចំណុចណាដែលបញ្ជាក់អំពីស្នាដៃរបស់លោក ខៀវ សំផន ដែលធ្វើឲ្យលោកពេញចិត្តជាងគេបំផុតនោះ? លោកមានអ្វីដែលជាព័ត៌មាននៅក្នុងខ្លួនរបស់លោកដែរទេ ដែលលោកអាចបញ្ជាក់អំពីស្នាដៃរបស់លោក ខៀវ សំផន ដែលធ្វើឲ្យលោកពេញចិត្តចំពោះគាត់?

**ឆ៖** គាត់រាបសា គាត់មិនរើសអើង។

**ស៖** បាទ ចុះទាក់ទងទៅនឹងការប្រព្រឹត្តចំពោះអ្នកជិតខាងនៅក្នុងតំបន់ដែលលោករស់នៅលោកបញ្ជាក់អំមិញថា នៅប៉ៃលិន តើការប្រព្រឹត្តរបស់លោក ខៀវ សំផន ចំពោះអ្នកជិតខាងរបស់គាត់ហ្នឹងយ៉ាងដូចម្ដេចដែរ លោកអាចបញ្ជាក់បានទេ? ហើយចំពោះអ្នកជិតខាងវិញ តើមានការប្រព្រឹត្តយ៉ាងដូចម្ដេចចំពោះលោក ខៀវ សំផន?

[០៩:៥១:៣៣]

**ឆ៖** គាត់រាប់អានមហាជន ប្រជាជនទូទៅស្មើគ្នា គាត់ -- ហើយគេក៏គោរពស្រឡាញ់គាត់ ទៅមកសួរនាំគាត់ មិនមានអ្នកណាមួយស្អប់គាត់ទេ។

**ស៖** បាទ ចុះទាក់ទងទៅនឹងអតីតភាពរបស់លោក ខៀវ សំផន ដែលធ្លាប់ធ្វើជាប្រមុខនៃគណៈប្រធានរដ្ឋរបស់កម្ពុជាប្រជាធិបតេយ្យ តើលោកមានបានដឹងអំពីការពិភាក្សា ឬការជជែកគ្នាណាមួយទាក់ទងទៅនឹងលោក ខៀវ សំផន អំពីអតីតកាលនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែរទេ?

**ឆ៖** អត់ទេ។

**ស៖** តើលោកដឹងអំពីទស្សនៈនយោបាយរបស់លោក ខៀវ សំផន ដែរទេ ថាតើលោក ខៀវ សំផន គាត់ប្រកាន់យកការដឹកនាំប្រទេសយ៉ាងដូចម្ដេចដែរ?

លោក សឿន លោកយល់សំណួរខ្ញុំទេ?

[០៩:៥៣:៣៥]

**ឆ៖** សូមលោកនិយាយឲ្យច្បាស់។

**ស៖** បាទ ខ្ញុំចង់សួរលោកថា ដោយសារលោកធ្លាប់រស់នៅជាមួយលោក ខៀវ សំផន នៅក្នុងផ្ទះជាមួយគ្នា។ អ៊ីចឹងខ្ញុំចង់ឲ្យលោកជួយបញ្ជាក់ជូនអង្គជំនុំជម្រះថា ទស្សនៈនយោបាយរបស់លោក ខៀវ សំផន តើគាត់មានទស្សនៈបែបណាដែរ? ជាពិសេសទាក់ទងទៅនឹងកិច្ចការដឹកនាំប្រទេសធំៗ នៅពេលដែលលោកមានការពិភាក្សា ឬក៏លោកបានស្ដាប់ពីការពិភាក្សាណាមួយរបស់លោក ខៀវ សំផន ជាមួយនឹងអ្នកដទៃទៀតអំពីបញ្ហាប្រទេសជាតិជាដើម។ តើលោកអាចយល់ ឬក៏ស្ដាប់បាន ឬក៏ដឹងអំពីទស្សនៈនយោបាយរបស់លោក ខៀវ សំផន ដែរទេ?

**ឆ៖** តាមខ្ញុំឃើញការប្រព្រឹត្តរបស់គាត់ គឺគាត់គោរពតាមលំអានសម្ដេចឪ គាត់លម្អៀងទៅខាងសម្ដេចឪដឹកនាំ។ គាត់មានគោលជំហរមួយ ឯករាជ្យ អព្យាក្រឹត តាមលំនាំសម្ដេចឪ។

**ស៖** បាទ សូមអរគុណ។ ទាក់ទងទៅនឹងការរកស៊ីសម្រាប់ផ្គត់ផ្គង់ជីវភាពគ្រួសារ តើលោកធ្លាប់បានដំបូន្មានអ្វីខ្លះពីលោក ខៀវ សំផន ដែរទេ?

**ឆ៖** គាត់ណែនាំឲ្យរកស៊ី សំខាន់មានដី មានផ្ទះនៅ និងបង្កបង្កើនផលចិញ្ចឹមខ្លួនដោយប្រឹងប្រែង សំខាន់មានជីវភាពជាមានដីមានធ្លីដើម្បីចិញ្ចឹមជីវិត។

**ស៖** បាទ សូមអរគុណ។ លោក ទន់ សឿន តើលោកមានចំណុចណាមួយដែលលោកចង់ឆ្លើយបញ្ជាក់ជូនអង្គជំនុំជម្រះបន្ថែមទៀតទេ?

**ឆ៖** អត់។

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោក ទន់ សឿន។ លោកប្រធាន ខ្ញុំអស់សំណួរហើយ។ សូមអរគុណ។

[០៩:៥៦:៤៧]

**ប្រធានអង្គជំនុំ៖**

បាទ សូមអរគុណ។ ហើយជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមតំណាងសហព្រះរាជអាជ្ញាដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះអ្នក -- ចំពោះសាក្សីរូបនេះ។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក ឃើត វេយ៍ន័រ៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម មេធាវីការពារក្តី និងភាគីទាំងអស់។ ហើយនិងជម្រាបសួរលោកសាក្សី ទន់ សឿន។

**ស៖** សំណួរទី១របស់ខ្ញុំជូនលោកគឺថា តើនៅពេលណាដែល លោកដឹងឬក៏បានរៀនអំពីការបកសារទូរលេខនេះ បកប្រែបាទ?

**លោក ទន់ សឿន៖**

**ឆ៖** ខ្ញុំរៀននៅសម័យត្រីភាគី។

**ស៖** តើលោករៀនបកប្រែទូរលេខនេះនៅពេលដែលលោកនៅក-៣ នោះលោកបានរៀនដែរឬទេ?

**ឆ៖** នៅក-៣ ខ្ញុំរៀនវ៉ៃម៉ាស៊ីនអង្គុលីលេខ។

**ស៖** តើលោកបានរៀនបកប្រែទូរលេខទេ នៅ ក-៣?

[០៩:៥៨:៣៣]

**ឆ៖** អត់។

**ស៖** តើលោកដឹងទេ ថាមេធាវីការពារក្ដីនងដាក់ឯកសារ E9/11.2 ដែលនិយាយអំពីបញ្ហាទាក់ទងទៅនឹងលោក។ សូមដកស្រង់ "ទន់ សឿន គឺជាខ្មែរក្រហមវ័យក្មេងដែលបានបញ្ជូនមកភ្នំពេញជាមួយនឹងកុមារផ្សេងៗទៀតនៅឆ្នាំ១៩៧៦ (ទៅអតីតរដ្ឋសភា បន្ទាប់មកទៅ ក-១ ហើយនៅទីបំផុតដើម្បីឲ្យគាត់រៀនបកប្រែទូរលេខនៅ ក-៣)"។ តើលោកបានដឹងពីឯកសារនេះ ដែលមេធាវីដាក់ជូនមកតុលាការដែរឬទេ?

**ឆ៖** អត់ទេ។

**ស៖** ខ្ញុំចង់ត្រឡប់ទៅក្រោយបន្តិចនៅពេលដែលនៅដើមឆ្នាំ១៩៧៧ នៅពេលដែលលោកបានរៀននៅបឋមសិក្សានៅជិតវត្តស្វាយពពៃ ដែលលោកបានឆ្លើយព្រឹកនេះ។ តើសាលានេះជាសាលាដែលលោករៀននៅជិតផ្លូវសុធារស ឬក៏នៅជិតសាលាសុធារសបាទ?

**ឆ៖** គឺសាលាសុធារសហ្នឹងឯង។

**ស៖** គ្រូរបស់លោកនៅពេលដែលលោកនៅសាលាសុធារសនោះគឺថាឈ្មោះ ផង់។ តើឈ្មោះពេញរបស់គាត់ឈ្មោះ នួន សុផង់ ឬក៏ នង សុផង់ ឬក៏ឈ្មោះអ្វីបាទ?

**ឆ៖** ពេលនោះ ខ្ញុំអត់ស្គាល់នាមត្រកូលគាត់ទេ ស្គាល់តែគេហៅ ពូផង់ៗ។

[១០:០០:៤៤]

**ស៖** តើត្រូវដែរឬទេ នៅពេលដែលលោកចូលថ្នាក់មានកុមារផ្សេងៗទៀតមកពីខេត្តផ្សេងៗ ឬក៏មកពីកន្លែងណានៅក្នុងប្រទេសកម្ពុជាទេទៅរៀនជាមួយលោកកាលនោះ?

**ឆ៖** មកច្រើនខេត្ត ប៉ុន្តែខ្ញុំមិនដឹងអ្នកណានៅខេត្តណាខ្លះ។

**លោក ឃឹត វេយ៍ន័រ៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតអំពីសក្ខីកម្មពីខាងនោះ ហើយខ្ញុំត្រូវបោះពុម្ពចេញជូនលោក ហើយខ្ញុំមានជាភាសាអង់គ្លេសតែប៉ុណ្ណោះ។ ហើយសូមអនុញ្ញាតលោកប្រធានដើម្បីសូមដកស្រង់ បាទជាសក្ខីកម្មរបស់ នង សុផង់ នៅថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១២។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

[១០:០១:៥៥]

**លោក ឃីត វេយ៍ន័រ៖**

ដើម្បីឲ្យមេធាវីការពារក្ដីអាចតាមដាន គឺថានៅថ្ងៃ២៩ ខែសីហា ឆ្នាំ២០១២ ពេលវេលាពាក់ព័ន្ធនោះគឺ ១៤:២៣:៤៩ ម៉ោងដែលពាក់ព័ន្ធ។

**សួរដោយលោក ឃីត វេយ៍ន័រ៖**

**ស៖** ដូច្នេះលោក ទន់ សឿន ខ្ញុំនឹងអានជូនលោកអំពីអ្វីដែល នង សុផង់ នោះគាត់និយាយអំពីសាលាសុធារសបាទ។ សូមដកស្រង់៖

"ខ្ញុំជាគ្រូបង្រៀននៅទីនោះ។ ខ្ញុំទទួលក្នុងការផ្ដល់វគ្គហ្វឹកហ្វឺនដល់មនុស្សមួយចំនួនដែលគេអាចបញ្ជូនមកពីខេត្តផ្សេងៗ។ ខ្ញុំបណ្ដុះបណ្ដាលពួកគេឲ្យគេយល់អំពីរបៀបសរសេរ ការអាន ហើយនិងការវាយអង្គុលីលេខ។ ហើយខ្ញុំក៏មានភារកិច្ចបង្រៀនពួកគេឲ្យគេយល់អក្សរឡាតាំងខ្លះៗ ហើយនិងភាសាអង់គ្លេសផងដែរ។ ហើយបន្តបន្ទាប់ទៅ ខ្ញុំបានបង្រៀនពួកគេឲ្យបកប្រែសារទូរលេខសម្ងាត់ៗផងដែរ។ សូមសួរលោកបន្ត នៅពេលដែលលោកបង្រៀនកុមារទាំងអស់នោះ តើកុមារនោះអាយុប៉ុន្មាន? ថាតើមូលហេតុនៃការបង្រៀនកុមារទាំងអស់នេះគឺអ្វី? ជាពិសេសអំពីការបកប្រែទូរលេខហ្នឹង? ចម្លើយរបស់លោក សុផង់៖ គោលបំណងសំខាន់នៃការបង្រៀនគឺដើម្បីធានាថាឲ្យកុមារទាំងអស់នេះគឺមានជំនាញមួយចំនួនដើម្បីបម្រើបក្សក្នុងពេលអនាគត។ ជាពិសេសពួកគេត្រូវការការបណ្ដុះបណ្ដាលអំពីការបកប្រែទូរលេខ ហើយនិងវាយអង្គុលីលេខ។ ការងារទាំងអស់នេះសំខាន់ណាស់ជាផ្នែកមួយនៃជំនាញរបស់ពួកគេ ដើម្បីឲ្យពួកគេបំពេញការងារដើម្បីបម្រើបក្ស។ កុមារទាំងអស់នេះ គឺភាគីច្រើនគឺអាយុ១២ឆ្នាំ"។ នេះជាសម្ដីរបស់ នង សុផង់។

[១០:០៤:១៩]

ឥឡូវនេះខ្ញុំចង់សួរលោកបន្តទៅទៀត តើលោកបានរៀនអ្វីខ្លះដែរឬទេនៅពេលដែលលោករៀននៅសាលាសុធារសនោះ អំពីនិយាយអំពីការបកប្រែសារទូរលេខបាទ?

**លោក ទន់ សឿន ៖**

**ឆ៖** ខ្ញុំអត់បានរៀនទេ ព្រោះនៅទើបរៀនអក្សរ អត់ទាន់ចេះអក្សរទេ។

**ស៖** តើដល់ពេលណាមួយដែលលោកនៅសុធារសនោះ លោកបានដឹងថាមានកូនសិស្សកុមារៗហ្នឹងគឺថាបានរៀនអំពីវិធីបកប្រែសារទូរលេខទេ ក្រោយពេលដែលលោកទៅ ហើយរយៈពេលដែលលោកនៅកន្លែងនោះ?

**ឆ៖** ការរៀនបកប្រែសាទូរលេខនេះ គឺគេអ្នកធំៗដែលចេះអក្សរច្រើនហើយ គេចូលរៀន តែចំពោះក្រុមខ្ញុំក្មេងៗតូចមិនទាន់បានចូលរៀនទេ។ នៅរៀនអក្សរសាស្ត្រ និងគណិតនៅឡើយ។

**ស៖** ខ្ញុំនឹងចូលទៅដល់ពេលមួយដែលលោកធ្វើការ ឬក៏លោកនៅ ក-៣។ លោកបាននិយាយថា "ខ្ញុំបានសរសេររៀបវាយអង្គុលីលេខ" -- ដែលលោកបានឆ្លើយព្រឹកមិញនេះ។ លោកមេធាវីរបស់លោក ខៀវ សំផន នោះបានសួរលោកថា "តើលោកបានវាយឯកសារអ្វីខ្លះ?" ចម្លើយរបស់លោក លោកបានឆ្លើយថា "ខ្ញុំបានមើលទស្សនាវដ្ដី ហើយព្យាយាមអនុវត្តការងារតាមហ្នឹង។ ហើយគាត់បានសួរថា "តើលោកបានពាក់ព័ន្ធអ្វីនឹងសារ និងសំបុត្រទេ?" លោកបានឆ្លើយថា "អត់ទេ"។

នៅក-៣ នៅដំណាក់កាលមួយចំនួននោះ តើលោកបានទទួលការណែនាំ ឬក៏បានចូលរួមទាក់ទងទៅនឹងការបកប្រែសាទូរលេខដែរឬទេ?

[១០:០៦:៤៦]

**ឆ៖** អត់ទេ។

**ស៖** ក្នុងភស្តុតាងរបស់លោក លោកនិយាយថានៅសាលាសុធារស នៅដើមឆ្នាំ១៩៧៧ រហូតដល់ខែកក្កដា ឆ្នាំ១៩៧៨។ តើត្រូវអ៊ីចឹងដែរឬទេ?

**ឆ៖** បាទ។

**ស៖** តើកម្រិតនៃការរៀនអក្សរសាស្ត្រហ្នឹង គឺថា១ឆ្នាំកន្លះនៅសុធារសនោះ កម្រិតលោកលោកចេះដល់ណាដែរអំពីអក្សរសាស្ត្រនោះ ដែលលោកនិយាយ?

**ឆ៖** អាចមើលបាន សរសេរបាន។

**ស៖** នៅពេលដែលលោកនៅ ក-៣ តើមានសិស្សប៉ុន្មាននៅជាមួយលោកនៅ ក-៣នោះ?

**ឆ៖** ទាំងអ្នកធ្វើការ ទាំងពួកខ្ញុំក្មេងៗប្រហែលជា១០នាក់។

**ស៖** តើលោកធ្លាប់ -- ក្នុងសម័យកម្ពុជាប្រជាធិបតេយ្យឆ្នាំ១៩៧៥ ដល់១៩៧៩ លោកធ្លាប់ឃើញតារាងដែលមានគេដាក់ប្រលោះៗនៅក្នុងហ្នឹង។ បាទដែលថាប្រអប់ហ្នឹងមានឯកសារ មានអីដែលថាគេរក្សាទុក ឬក៏សារដែលគេបកពីសារទូរលេខមក។ តើលោកធ្លាប់បានឃើញទេ?

**ឆ៖** អត់ទេ។

[១០:០៨:៤៦]

**ស៖** បាទឥឡូវនេះ ខ្ញុំចូលដល់ឆ្នាំ១៩៧០ -- ១៩៨២ ដែលលោកបានទទួល គេហៅថាលិខិត

សារតាំងនៅម៉ាឡៃ នៅពេលដែលលោក ពេលនោះគឺថាលោកបានឃើញអំពីសារទូរលេខដែលត្រូវបានគេបកប្រែ។ តើលោកអាចជម្រាបតុលាការ និងខ្ញុំបន្ថែមបានទេ?
**ផ៖** សារហ្នឹងគ្រាន់តែផ្ញើមកពីស្ថានទូតផ្សេងៗនៅក្រៅប្រទេសជូនមកលោក ខៀវ សំផន ដើម្បីបញ្ជាក់ថាមានអង្គទូតណាខ្លះដែលមកថ្វាយសារតាំងដល់សម្ដេចឪ។
**ស៖** ចំណុចដែលខ្ញុំចង់ស្ដាប់ពីលោកនោះ ថាតើលោកជាអ្នកបកប្រែសារហ្នឹងដែរឬទេ សារទូរលេខនៅក្នុងឆ្នាំ១៩៨២?
**ផ៖** បាទ។
**ស៖** តើលោកមានបទពិសោធដូចម្ដេចដែរ គឺថាមុនឆ្នាំ១៩៨២ លោកមានជំនាញខាងបកប្រែទេ?
**ផ៖** ខ្ញុំបានរៀននៅអង្គភាព ពូផង់ ហ្នឹង ខ្ញុំមានជំនាញធ្វើការខាងហ្នឹង។
**ស៖** តើក្នុងឆ្នាំណា?
**ផ៖** ៨១, ៨២ បាទ។
**ស៖** ខ្ញុំនឹងចូលទៅសំណួរមួយចំនួនទៀត រហូតមកដល់ឆ្នាំ១៩៨៩ ហើយសំណួរមួយចំនួនទៅលោកព្រឹកមិញនេះលោកបានឆ្លើយ។ ឥឡូវ ខ្ញុំស្រង់សម្ដីលោក “ខ្ញុំនៅតែទទួលបន្ទុកក្នុងការបញ្ជូនសំបុត្រ និងសារមួយចំនួន”។ ហើយនៅពេលដែលគេសួរបំភ្លឺ “តើសារទាំងអស់នេះទៅលោក ខៀវ សំផន ដែរឬទេ?”។ ឥឡូវនេះគឺថា តើសារទាំងអស់នេះជាសារទូរលេខ ឬក៏តេឡិច ឬក៏ជាឧបករណ៍ផ្សព្វផ្សាយតាមវិទ្យុ ឬក៏ជាឯកសារតាមរបៀបណា?
[១០:១១:២៩]
**ផ៖** ជាសារទូរលេខ។
**ស៖** នៅឆ្នាំ១៩៨៩ នោះតើមានពាក្យសម្រាប់មន្ទីរ ជាឈ្មោះកូដអំពីមន្ទីរតេឡេក្រាមនោះទេបាទ? តើលោកធ្លាប់ឮដែរឬទេ? ឬក៏មានឈ្មោះហ្នឹងដែរឬទេ?
**ផ៖** គឺទាក់ទងតែតាមស្ថានទូតខ្មែរដែលប្រចាំនៅបរទេស ដែលជូនមកគាត់។
**ស៖** តើលោក ខៀវ សំផន គាត់នៅកន្លែងណានៅពេលដែលលោកបញ្ជូនសារទៅឱ្យគាត់នៅឆ្នាំ១៩៨៩ តើនៅក្នុងតំបន់ណា? នៅក្នុងប្រទេសណា? បាទ សូមលោកបញ្ជាក់ជូនតុលាការ?
**ផ៖** ពេលហ្នឹង គេមានចាត់ឱ្យប្រជុំក្រៅផ្លូវការមួយដើម្បីរកដំណោះស្រាយប្រទេសកម្ពុជាដែល

ចាប់ផ្ដើមដំបូងប្រជុំក្រៅផ្លូវការនៅក្រុងប៉ារីស ឆ្នាំ៨៩ ខែ៧ ខែ៨។

[១០:១២:៥៥]

**ស៖** ប្រហែលជាខ្ញុំមិនសួរលោកឲ្យបានច្បាស់។ ខ្ញុំសួរថា នៅពេលដែលលោកបញ្ជូនតេឡេក្រាម សំបុត្រទូរលេខទៅឲ្យលោក ខៀវ សំផន តើលោកបានធ្វើការងារហ្នឹងនៅក្នុងប្រទេសផ្សេង ឬក៏លោកបញ្ជូនសារទូរលេខទៅគាត់ដែរឬទេ នៅពេលដែលគាត់នៅកម្ពុជា ឬក៏នៅពេលដែលគាត់នៅជាប់ -- នៅជិតព្រំដែនថៃនោះ?

**ឆ៖** ពេលដែលគាត់នៅព្រំដែន ក៏បញ្ជូនឲ្យគាត់។

**ស៖** សូមអរគុណ។ នៅពេលដែលលោកបញ្ជូនសារទៅជូនលោក ខៀវ សំផន នៅជិតព្រំដែនថៃនោះ តើលោកអាចជម្រាបពីឈ្មោះខេត្តដែលលោក ខៀវ សំផន បានស្នាក់នៅ នៅពេលនោះដែរឬទេ?

**ឆ៖** គាត់នៅភ្នំក្រវាញ។

**លោក ឃីត រេយ៉ន័រ៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាត បាទ នៅក្នុងឯកសារជាភាសាខ្មែរដើម្បីជូនទៅ គឺ TCWៗគឺ 69 -- 639 បាទ។ ជាឯកសារ ដើម្បីឲ្យសាក្សីបានពិនិត្យបាទ។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត!

មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីតំណាងសហព្រះរាជអាជ្ញា យកជូនសាក្សីពិនិត្យ!

[១០:១៤:៤៨]

**សួរដោយលោក ឃីត រេយ៉ន័រ៖**

**ស៖** លោក ទន់ សឿន ខ្ញុំចង់ឲ្យលោកពិនិត្យមើល បាទពីទំព័រដំបូងនៅលើឯកសារនេះ ហើយលោកនឹងបានឃើញឈ្មោះសាក្សីរូបនេះ ហើយមុនពាក្យ នៅមុខពាក្យ៥៩ -- អ៊ំ! ៥៥ឆ្នាំ នៅលើនោះ គឺថាទំព័រ 00284289 នៅទំព័រទី២ នៃឯកសារហ្នឹង។ បាទ នៅមុខពាក្យ ៥៥ឆ្នាំមានឈ្មោះម្នាក់ហើយខ្ញុំសួរលោកមុនគេ តើលោកស្គាល់ឈ្មោះ ឬក៏លោកចាំឈ្មោះមនុស្សនោះទេ គ្រាន់តែឆ្លើយទេឬបាទ? លោកកុំទាន់ថាឈ្មោះគាត់?

ខ្ញុំមិនសូមឲ្យអានទេ ខ្ញុំគ្រាន់តែបញ្ជាក់ថាគឺថា លោកមេធាវីប្រឹក្សាអាចនឹងជួយគាត់ ថាតើគាត់

នៅចាំឈ្មោះហ្នឹងដែរឬទេ? ស្គាល់ទេ?

**ប្រធានអង្គជំនុំ៖**

កុំអាល់ទាន់ឆ្លើយ! សូមអញ្ជើញលោកមេធាវី ខៀវ សំផន!

[១០:១៦:៣៦]

**លោក គង់ សំអុន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំចង់ឲ្យតំណាងសហព្រះរាជអាជ្ញាមេត្តាបញ្ជាក់ទៅលើឯកសារនេះ ដោយសារទី១ ឯកសារនេះពុំមាននៅក្នុងអ៊ីនធឺហ្វេស អ៊ីចឹងយើងក៏ពិបាកតាមដានរក។ ហើយទី២ សូមឲ្យលោកជួយបញ្ជាក់លេខ ERN ឲ្យច្បាស់ពីទីតាំងចំណុចដែលលោកចង់ឲ្យសាក្សីសួរបាទ។ សូមអរគុណ។

**លោក ឃីត វេយ៍ន័រ៖**

បាទ E3/71 ខ្មែរ 00284289។ បាទលោក ទន់ សឿន តើលោកស្គាល់ឈ្មោះអ្នកដែលឆ្លើយចម្លើយនេះដែរឬទេ?

**ប្រធានអង្គជំនុំ៖**

លោក ទន់ សឿន គ្រាន់តែឆ្លើយថា លោកស្គាល់ ឬក៏មិនស្គាល់បានហើយ។ លោកមើលឈ្មោះអ្នកដែលផ្តល់ចម្លើយហ្នឹងទៅ ហើយលោកឆ្លើយតបទៅនឹងសំណួរនេះ។ គ្រាន់ថាស្គាល់ឬមិនស្គាល់ ដោយមិនចាំបាច់បញ្ចេញឈ្មោះរបស់អ្នកដែលផ្តល់ចម្លើយនោះទេ។ ហើយមេធាវីប្រឹក្សាអាចជួយសម្រួលពិនិត្យគាត់លើអំពីបញ្ហាឈ្មោះអ្នកដែលផ្តល់សក្ខីកម្មនៅក្នុងឯកសារនោះ ហើយប្រាប់គាត់ថា តើគាត់ស្គាល់ទេ ឬក៏មិនស្គាល់ទេ?

**លោក ឃីត វេយ៍ន័រ៖**

បាទ សូមជម្រាបថានៅទំព័រទី២ ហើយនៅប្រយោគទី១ នៃទំព័រទី២ ហ្នឹង។

[១០:១៨:៤៥]

**លោក ទន់ សឿន៖**

**ឆ៖** អត់ទេ។

**ស៖** នេះជាទំព័រ 00288622 គាត់បាននិយាយថា បាទ នេះជា ERN ជាភាសាអង់គ្លេសទេ គឺខ្មែរ ERN00784291។ សូមដកស្រង់ "បន្ទាប់ពីនោះមកឆ្នាំ១៩៨១ ខ្ញុំបានជួប ផង់ ម្តងទៀតនៅ ក-១៨

នៅភូមិត្រាត ប្រទេសថៃ។ នៅពេលនោះ ប៉ុល ពត និង ខៀវ សំផន ក៏បានរស់នៅ ក-១៨ ដែរ។ ផង់ គឺជាប្រធាននៃអង្គភាពមន្ទីរទូរលេខនៅក-១៨ ជាការងារធ្វើការរបស់ ប៉ុល ពត ហើយនិង ខៀវ សំផន។ ខ្ញុំធ្វើការនៅ ខ-១៨ នៅក្នុងអង្គភាពសារទូរលេខជាមួយ ផង់ រហូតដល់ ១៩៨២ និង ១៩៨៣"។ ឥឡូវសំណួរខ្ញុំចំពោះលោកសាក្សីនៅពេលនេះលោក ទន់ សឿង តើលោកធ្លាប់បានដឹងដែរឬទេថា មន្ទីរសារទូរលេខនៅក-១៨ ហ្នឹងជាមន្ទីរធ្វើការរបស់លោក ប៉ុល ពត និងលោក ខៀវ សំផន? តើលោកធ្លាប់បានដឹងដែរឬទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីឆ្លើយតបនឹងសំណួរ! ស្ដាប់យល់ទេ? ស្ដាប់សំណួរយល់ទេ? បើមិនយល់សួរឡើងវិញ សូមឲ្យគេសួរម្ដងទៀត។ ហើយបើយល់ហើយសូមឆ្លើយតបនឹងសំណួរបាទ។

[១០:២១:១៨]

**លោក ទន់ សឿង៖**

**ឆ៖** ស្គាល់ លោកប្រធាន។

**សួរដោយលោក ឃីត រេយ៍ន័រ៖**

**ស៖** ខ្ញុំគ្រាន់តែចង់បំភ្លឺ លោកស្គាល់អង្គភាពសារទូរលេខនៅក-១៨ នោះ ជាមន្ទីរធ្វើការរបស់លោក ប៉ុល ពត ហើយនិងលោក ខៀវ សំផន តើត្រឹមត្រូវដែរឬទេ លោកសាក្សី?

**ឆ៖** នៅខុសគ្នាបាទ។

**ស៖** តើលោកបានដឹងថា ប៉ុល ពត និង ខៀវ សំផន មានមន្ទីរធ្វើការជាមួយគ្នាដែរឬទេនៅកន្លែងមួយជិតកោះកុង?

**ឆ៖** គាត់នៅកន្លែងខុសគ្នា។

[១០:២២:២៩]

**ស៖** តើលោកធ្លាប់ជួប ឬក៏និយាយជាមួយអង្គរក្ស ឬក៏អ្នកការពាររបស់លោក ខៀវ សំផន ថា តើលោក ខៀវ សំផន ធ្លាប់បានទៅជួបប្រជុំនៅកន្លែងនោះដែរឬទេ?

**ឆ៖** ខ្ញុំអត់ដឹង។

**ស៖** បើទៅទំព័រខ្មែរ ទំព័រ 00284296 នៅលើឯកសារដែលលោកមាននេះ, អង់គ្លេស ERN 00288622 បាទដើម្បី ខ្មែរ 00284296 បាទ។ មានផ្នែកមួយនៅក្នុងចម្លើយនេះខ្ញុំសូមដកស្រង់ សាក្សី

គាត់និយាយអំពីក-១៨ ហើយគាត់បាននិយាយដូចតទៅនេះថា "ប៉ុល ពត ហើយនិង ខៀវ សំផន គឺជាអ្នកដឹកនាំខ្ញុំផ្ទាល់ ជាអ្នកឲ្យបញ្ជាផ្ទាល់ក្នុងការងារនៅក-១៨"។ ថាតើបុរសទាំងពីររូបនេះ តើធ្លាប់បង្គាប់ ឬក៏ណែនាំឲ្យលោកធ្វើការអីដោយផ្ទាល់ដែរឬទេបាទ?

**ឆ៖** ខ្ញុំទទួលការបញ្ជារបស់ ពូផង់ ខ្ញុំនៅក្រោម ពូផង់។

[១០:២៤:៤៩]

**ស៖** ដូច្នេះ តើមន្ទីរសារទូរលេខដែលធ្វើការងារជាមួយ ផង់ ហ្នឹងនៅក្នុងឆ្នាំ១៩៨៩ គេហៅថាក-១៨ មែនឬទេ?

**ឆ៖** លោក ផង់ អត់មាននៅ១៨ហ្នឹងទេ នៅកន្លែងផ្សេង។

**ស៖** តើលោកអាចប្រាប់ខ្ញុំឲ្យច្បាស់បានទេ ថាតើអ្នកណាខ្លះនៅធ្វើការនៅក-១៨ នោះ?

**ឆ៖** --

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! សូមអញ្ជើញលោកមេធាវីការពារក្តីលោក ខៀវ សំផន!

**លោក អាកទួរ វែកគែន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំឃើញថាច្រើនដងហើយ ព្រោះថាអត់មានអ្នកណាងើបឡើងតវ៉ា។ ខ្ញុំគិតថា មាន -- ប្រហែលជាមិនមានគេស្តាប់ការបកប្រែជាភាសាបារាំងទេ អ៊ីចឹងជាច្រើនដងណាស់ហើយដែលថា ខាងដើមឃ្លាហ្នឹងអត់មានការបកប្រែជាភាសាបារាំងទេ។ ហើយអម្បាញ់មិញនេះសំណួរហ្នឹងក៏អត់មានការបកប្រែ។ ផ្នែកខាងដើមសំណួរហ្នឹងក៏អត់មានការបកប្រែដែរ លោកប្រធាន។

[១០:២៦:១៥]

**លោក ឃីត រេយ៉ន័រ៖**

ខ្ញុំនឹងសួរឡើងវិញនៅសំណួរប៉ុន្មានចុងក្រោយ ដើម្បីឲ្យមេធាវីការពារក្តីអាចនឹងយល់បានទាំងស្រុងបាទ។

**សួរដោយលោក ឃីត រេយ៉ន័រ៖**

**ស៖** លោក ទន់ សឿន ភស្តុតាងដែលលោកបានឆ្លើយជូនតុលាការមកដល់ពេលនេះ គឺតាំងពីឆ្នាំ១៩៨៩ លោក ខៀវ សំផន មានមន្ទីរខុសពី ប៉ុល ពត តើត្រូវដែរឬទេ?

**លោក ទន់ សឿន៖**

**ឆ៖** បាទ។

**ស៖** តើទីតាំងរបស់ ប៉ុល ពត នៅកន្លែងណា? ហើយទីតាំងរបស់លោក ខៀវ សំផន នៅកន្លែងណា? ជាកន្លែងគាត់រស់នៅ និងធ្វើការ នៅកាលណោះបាទ?

**ឆ៖** គាត់នៅជាមួយក្រុមសហការីគាត់ គឺខាងក្រសួងការបរទេស។

**ស៖** ខ្ញុំសូមសួរឡើងវិញ នៅក្នុងឆ្នាំ១៩៨៩ តើនៅទីតាំងភូមិសាស្ត្រកន្លែងណាដែលលោក ខៀវ សំផន មានមន្ទីរធ្វើការរបស់គាត់? ហើយទីតាំងភូមិសាស្ត្រកន្លែងណាដែលជាទីកន្លែងមន្ទីរធ្វើការរបស់ ប៉ុល ពត ខ្ញុំចង់សួរបែបនេះ?

[១០:២៧:៥៤]

**ឆ៖** នៅផ្សេងគ្នា ខ្ញុំអត់ដឹងទេ កន្លែង ប៉ុល ពត។ ប៉ុន្តែកន្លែងលោក ខៀវ សំផន គាត់នៅកន្លែងផ្សេង មិនដឹងជាគេហៅភូមិអីទេ នៅហ្នឹង ប៉ុន្តែគ្រាន់តែខ្ញុំដឹង។ ហើយគាត់មានសហការីគាត់ គឺពួកបញ្ញាជននៅជាមួយ ជួបជុំគ្នា។

**ស៖** តើក-១៨ ជាកន្លែងរបស់ ប៉ុល ពត ឬក៏ជាកន្លែងរបស់លោក ខៀវ សំផន ឬក៏មានកន្លែងណាមួយផ្សេងមួយទៀត ខុសពីអ្នកទាំងពីរនេះ? និយាយពីរឿងក-១៨ បាទ។

**ឆ៖** កន្លែងគាត់នៅផ្សេង គាត់នៅជាមួយក្រុមបញ្ញាជនដែលជាសហការីរបស់គាត់ នៅកន្លែងផ្សេង ហើយខ្ញុំក៏នៅជាកន្លែងផ្សេងដែរ ប៉ុន្តែពេលមានបេសកកម្មទើបគេចុចហៅឈ្មោះខ្ញុំទៅបម្រើការងារជាមួយគាត់។

[១០:២៨:១២]

**ស៖** តើខ្ញុំយល់ត្រូវដែរឬទេ នៅពេលដែលលោកទទួលសារ ឬក៏ទូរលេខនៅពីកន្លែងរបស់លោក បន្ទាប់មកលោកចេញពីកន្លែងរបស់លោកទៅជួបគាត់ ទៅកន្លែងលោក ខៀវ សំផន ដើម្បីផ្តល់ទូរលេខ ឬក៏សារនោះ ទៅជូនគាត់ តើអ៊ីចឹងដែរឬទេ?

**ឆ៖** បាទ។

**ស៖** តើលោក ខៀវ សំផន ធ្លាប់សរសេរសារទូរលេខអ្វីដែរឬទេ? ហើយនិងត្រឡប់មកឲ្យលោក ដើម្បីឲ្យបញ្ជូនទៅអ្នកផ្សេងទៀតនោះ? បាទ តើមានចំណាររបស់គាត់លើសារទូរលេខអ្វីដែរឬទេបាទ?

**ឆ៖** គាត់សរសេរខ្លឹមសារក្នុងសារទូរលេខហ្នឹង គឺភាគច្រើនគាត់ទាក់ទងទៅខាងក្រៅប្រទេស ជាមួយស្ថានទូតកម្ពុជាប្រជាធិបតេយ្យប្រចាំនៅបរទេស ដែលមានរបាយការណ៍ពីស្ថានទូតផ្សេងៗ និងណែនាំទៅវិញ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកតំណាងសហព្រះរាជអាជ្ញា។ ឥឡូវនេះដល់ពេលឈប់សម្រាកហើយ។ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះទៅរហូតដល់ម៉ោងដប់មួយខ្វះដប់នាទី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំ សម្រាប់សាក្សី និងអ្នកជំនាញដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលសម្រាក និងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនេះវិញនៅវេលាម៉ោងដប់មួយខ្វះដប់នាទី រួមទាំងមេធាវីប្រឹក្សារបស់គាត់ផង។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៣១នាទី ដល់ម៉ោង ១០:៥២នាទី)*

[១០:៥២:១៦]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនិងផ្តល់វេទិកាជូនក្រុមតំណាងសហព្រះរាជអាជ្ញាដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។ សូមអញ្ជើញ!

**លោក ឃីត វេយ៉ន័រ៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ឃីត វេយ៉ន័រ៖**

**ស៖** លោក ទន់ សឿន មុនពេលយើងឈប់សម្រាក លោកបានពន្យល់ថានៅក្នុងឆ្នាំ១៩៨៩ ខៀវ សំផន ទទួលខុសត្រូវផ្នែកការបរទេស ហើយលោកបានបញ្ជូនសារទូរលេខទៅកាន់គាត់។ គាត់ក៏

បានសរសេរព័ត៌មាននៅក្នុងសារទូលេខទាំងនោះ។ លោកបានឆ្លើយថា សារទូលេខព័ត៌មាននោះវាពាក់ព័ន្ធទៅនឹងស្ថានទូតនៅតាមបណ្តាប្រទេសផ្សេងៗ។ តើអ្វីដែលលោកនិយាយនេះគឺពិតជាអ៊ីចឹងត្រឹមត្រូវដែរឬទេ?

[១០:៥៣:១៧]

**លោក ទន់ សឿង៖**

**ឆ៖** បាទ។

**ស៖** តើ ខៀវ សំផន ធ្លាប់ផ្តល់សារទូរលេខទៅឲ្យលោក ប្រសិនបើមានសារទូរលេខនោះដើម្បីឲ្យលោកនោះធ្វើការងារទៅលើសារទូរលេខនោះដែរឬទេ? តើលោក -- តើគាត់ធ្លាប់ឲ្យសារទូរលេខលោកធ្វើការងារលើសារទូរលេខនោះដែរឬទេ?

**ឆ៖** សួរម្តងទៀត ខ្ញុំអត់យល់សំណួរទេ។

**ស៖** ប្រហែលជាលោកមិនយល់ផ្នែកពាក់កណ្តាលនៃសំណួររបស់ខ្ញុំ ដូច្នេះខ្ញុំសូមពន្យល់ឡើងវិញ។ សារទូរលេខគឺលោកបានទទួលមក ហើយបន្ទាប់មកបញ្ជូនទៅឲ្យ ខៀវ សំផន។ ខៀវ សំផន បន្ទាប់ពីទទួលបានសរសេរនៅសារទូរលេខនោះ។ តើគាត់ធ្លាប់ផ្តល់សារទូរលេខហ្នឹងត្រឡប់មកឲ្យលោក ដើម្បីឲ្យលោកបញ្ជូនបន្តទៅអ្នកផ្សេងដែរឬទេ?

[១០:៥៤:៣៧]

**ឆ៖** គាត់មានលេខាផ្ទាល់គាត់មួយ។

**ស៖** ខ្ញុំនឹងអានចំណុចដកស្រង់ចេញពីកំណត់ហេតុដែលមាននៅចំពោះមុខលោកគឺ TCW-639 00288627 ជា ERN ជាភាសាអង់គ្លេស, ខ្មែរគឺ 00284297។ សាក្សីនុំង គឺបានត្រូវបានគេសួរសំណួរដូចខាងក្រោមនេះ៖

"នៅពេលដែលមេដឹកនាំផ្តល់ការណែនាំនោះ តើការណែនាំនោះ ផ្តល់តាមផ្ទាល់មាត់ ឬក៏គាត់សរសេរ ចារនៅលើសារទូលេខ? ឆ្លើយ៖ ពេលខ្លះមេដឹកនាំចារនៅលើសារទូលេខ លើកឡើងថាសារទូលេខមួយនេះ ឬមួយនោះ ត្រូវតែបញ្ជូនទៅឈ្មោះបុគ្គលនេះ ឬបុគ្គលនោះ។ ពេលខ្លះនៅពេលដែលខ្ញុំផ្តល់សារទូលេខទៅឲ្យគាត់អាន មេដឹកនាំ គឺទុកពីរបីថ្ងៃសិន ដើម្បីពិនិត្យជាមុន។ ក្រោយពីពិនិត្យរួចមកគាត់ផ្តល់សារទូលេខមកឲ្យខ្ញុំវិញដើម្បីបញ្ជូនបន្ត ដោយនៅក្នុងសារទូលេខនោះមានចំណារថាត្រូវបញ្ជូនបន្តទៅបុគ្គលនេះ ឬក៏បុគ្គលនោះ។ ពេលខ្លះ គាត់ណែនាំដោយផ្ទាល់មាត់។ សំណួរ តើលោកឃើញ

ចំណាររបស់នរណាគេដែរ? ឆ្លើយ៖ ជាញឹកញាប់នោះ ខ្ញុំឃើញចំណាររបស់ ប៉ុល ពត និងចំណាររបស់ ខៀវ សំផន។ ហើយចំពោះ សុន សេន និង នួន ជា ខ្ញុំក៏បានឃើញចំណាររបស់ពួកគាត់ផងដែរ នៅពេលដែលខ្ញុំធ្វើការងារជាមួយនឹងពួកគាត់"។ បញ្ចប់ការដកសម្រង់សម្ដី។

ខ្ញុំចង់សួរសំណួរទៅកាន់លោកថា ក្រោយពេលដែលលោកឲ្យ -- ហុចសារទូលេខទៅឲ្យ ខៀវ សំផន នោះ តើខៀវ សំផន នោះ មានណែនាំលោកដោយផ្ទាល់មាត់ ថាត្រូវធ្វើម៉េចទៀតចំពោះសារទូលេខដែលគាត់ឲ្យត្រឡប់មកវិញនេះដែរឬទេ?

[១០:៥៧:០៨]

**ឆ៖** គាត់មានលេខាផ្ទាល់គាត់ អ្នកសរសេរលិខិត ឬមួយក៏បញ្ជូនលិខិតទៅឲ្យគាត់។

**ស៖** តើលេខាផ្ទាល់របស់គាត់នោះ ដែលធ្វើការងារហ្នឹង មានឈ្មោះអ្វីដែរ?

**ឆ៖** ឈ្មោះ ឃន។

**ស៖** តើ ឃន ធ្វើការងារអចិន្ត្រៃយ៍ជាមួយនឹង ខៀវ សំផន? ឬក៏ធ្វើការជាមួយ ខៀវ សំផន នៅកន្លែងខុសៗគ្នា?

**ឆ៖** គាត់ជាលេខារបស់លោក ខៀវ សំផន។

**ស៖** តើគាត់នៅប្រចាំ ឬជាអចិន្ត្រៃយ៍ជាមួយ ខៀវ សំផន ដែរឬទេ នៅពេលដែលគាត់ធ្វើលេខាផ្ទាល់នោះ?

**ឆ៖** គាត់នៅជាមួយអចិន្ត្រៃយ៍។

[១០:៥៨:៣០]

**ស៖** ក្នុងពេលដែលលោកជាអ្នកបញ្ជូនសារទូលេខទៅដល់ ខៀវ សំផន តើលោកធ្លាប់បានឃើញ ប៉ុល ពត ដែរឬទេ?

**ឆ៖** អត់ដែលជួបទេ។

**ស៖** តើមន្ទីរ ប៉ុល ពត មានចម្ងាយប៉ុន្មានពីមន្ទីររបស់ ខៀវ សំផន បើគិតជាគីឡូម៉ែត្រនោះ?

**ឆ៖** ឆ្ងាយ។

**ស៖** លោកបញ្ជាក់រួចមកហើយ ថា ខៀវ សំផន ទទួលបន្ទុកការងារបរទេស។ ខ្ញុំចង់យោងទៅលើឯកសារមួយទៀត គឺឯកសារ E3/703។ ឯកសារនេះ គឺចេញពីមន្ទីរអនុប្រធានកម្ពុជាប្រជាធិបតេយ្យទទួលបន្ទុកការបរទេស។ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៨៧។ ERN ជាភាសាអង់គ្លេស គឺ

00004002, បារាំងមានលេខ 00693796 រហូលទៅដល់ 97, ខ្មែរគឺ 00700551 ដល់ 52។ មន្ទីរអនុប្រធាននៃកម្ពុជាប្រជាធិបតេយ្យទទួលបន្ទុកផ្នែកការបរទេសបានសរសេរលើកឡើងដូចតទៅ ខ្ញុំសូមដកស្រង់សម្ដី៖

"ចំណងជើង: <u>ចំនួនមនុស្សដែលស្លាប់ដោយកំហុសរបស់យើង។</u> កម្មាភិបាលរបស់យើងភាគច្រើន គឺបានធ្វើការដោយស្មោះស្ម័គ្រ ដើម្បីផលប្រយោជន៍ជាតិ និងប្រជាជនកម្ពុជា ក៏ប៉ុន្តែពួកគេពុំមានបទពិសោធន៍នៅក្នុងការងារការបរទេស -- ក្នុងការងាររដ្ឋ។ ស្ថានភាពធ្វើឲ្យមានការភាន់ភាំង ច្រឡំច្រើន ហើយមានភាពច្របូកច្របល់ ដោយសារមានបញ្ហាភ្នាក់ងារយួន។ ហេតុដូច្នេះ នៅក្នុងវិធានការរបស់យើងដើម្បីចាប់ខ្លួន និងដាក់ទោសភ្នាក់ងារគិញវៀតណាម យើងបានប្រព្រឹត្តកំហុស។ កំហុសទាំងអស់នេះ វាបានធ្វើឲ្យប៉ះពាល់ទៅដល់ជីវិតជនស្លូតត្រង់ ជនស៊ីវិលស្លូតត្រង់ ឬក៏អ្នកប្រព្រឹត្តកំហុសតិចតួច។ ពីឆ្នាំ១៩៧៥ រហូតទៅដល់ឆ្នាំ១៩៧៨ មិន-- មានមនុស្សជាង៣០០០នាក់បានស្លាប់នៅក្នុងប្រភេទបែបនេះ"។ សូមបញ្ចប់ការដកស្រង់សម្ដី។

សំណួររបស់ខ្ញុំគឺចង់សួរថា តើ ខៀវ សំផន ធ្លាប់បានប្រាប់លោកដែរឬទេថា មានមនុស្ស៣០០០នាក់បានស្លាប់ ជាពិសេសនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនេះ?

[១១:០៣:០៥]

**ប្រធានអង្គជំនុំ៖**

បាទៗ ផ្អាកសិនបាទ!

សូមអញ្ជើញលោកមេធាវី!

**លោក ម៉ម រិទ្ធា ៖**

សូមគោរពលោកប្រធាន អម្បាញ់មិញលោកសាក្សី គាត់ថាស្ដាប់អត់ឮ ហើយឥឡូវហ្នឹងឮឡើងវិញ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

តំណាងសហព្រះរាជអាជ្ញា អម្បាញ់មិញនេះសាក្សី គាត់ស្ដាប់អត់ឮទេ ហើយសូមលោកសួរសំណួរអំមិញចុងក្រោយនេះម្ដងទៀត។

ហើយមន្ត្រីរដ្ឋបាលតុលាការពិនិត្យថាមពលនៅឧបករណ៍ស្ដាប់សំឡេងរបស់គាត់មើល ក្រែងលោមានបញ្ហាមកពីថាមពល!

[១១:០៤:១៧]

**លោក ឃីត រេយ៉ន័រ៖**

**ស៖** លោក ទន់ សឿន ខ្ញុំនឹងអានសំណួររបស់ខ្ញុំឡើងវិញ។ តើ ខៀវ សំផន ធ្លាប់បានប្រាប់លោកដែរឬទេថា មានជនស៊ីវិលស្លូតត្រង់៣០០០នាក់បានស្លាប់ក្នុងពេលចាប់ខ្លួនដោយភ័ន្តច្រឡំក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែរឬទេ?

**លោក ទន់ សឿន៖**

**ឆ៖** អត់ទេ។

**ស៖** ដើម្បីផលប្រយោជន៍ទៅកាន់មេធាវីការពារក្តី ខ្ញុំលើកឡើងឯកសារ ដដែលទេ ត្រង់ ERN 00004005, បារាំងមានលេខ 00693799, ខ្មែរមានលេខ 00700558 គឺមន្ទីរ អនុប្រធានកម្ពុជាប្រជាធិបតេយ្យទទួលបន្ទុកផ្នែកការបរទេស បានលើកឡើងដូចតទៅ៖

ខ្ញុំសូមដកស្រង់សម្តី "ដើម្បីឲ្យមានភាពយុត្តិធម៌ ចំនួនមនុស្សដែលបានស្លាប់នៅក្នុងប្រទេសកម្ពុជាពីចន្លោះឆ្នាំ១៩៧៥ រហូតដល់ឆ្នាំ១៩៧៨ គឺមានចំនួនតិចជាងមនុស្សដែលស្លាប់ដោយគ្រោះថ្នាក់ដោយសាររថយន្តនៅតាមនៅលើពិភពលោក។ ដោយសារតែមនុស្សដែលស្លាប់ដោយគ្រោះថ្នាក់ចរាចរណ៍នោះមានចំនួនច្រើនជាងនេះ"។ បញ្ចប់ការដកស្រង់សម្តី។

ខ្ញុំសូមសួរសំណួរនេះទៅកាន់លោកដូចតទៅ: តើ ខៀវ សំផន ធ្លាប់បាននិយាយប្រាប់លោកប្រៀបធៀបចំនួនមនុស្សដែលស្លាប់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ជាមួយនឹងមនុស្សស្លាប់នៅក្នុងគ្រោះថ្នាក់ចរាចរណ៍នៅតាមបណ្តាប្រទេសផ្សេងដែរឬទេ?

[១១:០៥:៥២]

**ឆ៖** អត់ទេ។

**ស៖** ក្រោយពេលដែលលោកចូលរៀននៅសាលាសុធារស ក្នុងដើមឆ្នាំ១៩៧៧ តើលោកធ្លាប់បានឮការចាក់ផ្សាយតាមវិទ្យុដោយ ខៀវ សំផន ដែរឬទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! បាទ សូមអញ្ជើញលោកមេធាវី!

**លោក អាកឡូរ វែកគែន៖**

បាទ យើងអត់ទទួលបានចម្លើយជាភាសាបារាំងទេ។ អ៊ីចឹងខ្ញុំ គិតថារកមធ្យោបាយអីមួយដើម្បី

អ្នកបកប្រែជាភាសាបារាំងហ្នឹងរកមធ្យោបាយណាមួយឲ្យគាត់បកប្រែបាន។ ខ្ញុំមិនចង់ក្រោករាល់ដង នោះទេ នៅពេលដែលអ្នកបកប្រែចេញជាភាសាបារាំងនោះ ថាគាត់ស្តាប់ចម្លើយមិនទាន់បាន ឬក៏គាត់អត់យល់អ្វីដែលនិយាយនោះ។ រឿងនេះកើតមានឡើងច្រើនដងណាស់ ខ្ញុំមិនចង់ក្រោកឡើងជម្រាបជូនតុលាការរហូតនោះទេ។ ហើយខ្ញុំក៏មិនចង់កាត់ផ្តាច់សហភាតារបស់ខ្ញុំរាល់៥នាទីម្តងនោះដែរ។ អ៊ីចឹងសូមឲ្យយល់ពីប្រព័ន្ធបកប្រែនេះផងបាទ។

[១១:០៨:០៩]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ ខ្ញុំសូមរំឭកដល់ការអនុវត្តល្អ ដើម្បីឲ្យមានការបកប្រែបានល្អនៅទីនេះ។ ទី១ គឺថា ត្រូវសម្រាកបន្តិចសិន នៅចន្លោះចម្លើយ ហើយនិងសំណួរថ្មីរបស់អ្នកសួរ។ បើសិនជាឆ្លើយចប់ភ្លាម ចាប់ផ្តើមសួរភ្លាមនោះនឹងបង្កឲ្យមានបញ្ហា។ ចំណុចទី២ គឺចំពោះសាក្សីនោះ គឺថាគាត់ត្រូវចាំឲ្យឃើញមានពន្លឺក្រហមសិនចាំឆ្លើយ បើសិនជាគាត់ឆ្លើយមុនពេលឃើញពន្លឺក្រហមនោះ ចម្លើយគាត់មិនត្រូវបានបកប្រែឲ្យភាគីទេ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា សាជាថ្មីម្តងទៀតនៅសំណួរចុងក្រោយរបស់លោក!

[១១:០៩:១៥]

**លោក ឃីត រេយ៉ន័រ៖**

ជាការពិត សូមអរគុណលោកប្រធាន។

**សួរដោយលោក ឃីត រេយ៉ន័រ៖**

**ស៖** លោក ទន់ សឿន តើលោក ខៀវ សំផន នៅពេលដែលគាត់ជជែកពិភាក្សាជាមួយលោកនោះ តើលោក ខៀវ សំផន ធ្លាប់មានបានលើកឡើងការប្រៀបធៀបរវាងចំនួនមនុស្សស្លាប់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ជាមួយនឹងចំនួនមនុស្សស្លាប់ដោយសារគ្រោះថ្នាក់ចរាចរណ៍តាមរថយន្តនៅតាមបណ្តាប្រទេសនានាដែរឬទេ?

**ឆ៖** អត់ទេ។

**ស៖** ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ តើលោកធ្លាប់ស្ដាប់ឮការចាក់ផ្សាយតាមវិទ្យុដោយឮសំឡេង ខៀវ សំផន នៅថ្ងៃប្រារព្ធខួបជ័យជម្នះថ្ងៃ១៧ ខែមេសាដែរឬទេ ដែលនៅក្នុងការចាក់ផ្សាយវិទ្យុនោះ ខៀវ សំផន បានរៀបរាប់លើកឡើងអំពី -- ជាដំបូងគឺគាត់លើកឡើងអំពី "យើងត្រូវតែបោសសម្អាត ខ្មាំងក្នុងនាមដែលយើងធ្វើជាម្ចាស់ការលើស្ថានភាព។ ទី២ គឺជីករំលើងគល់ ខ្មាំងគ្រប់វណ្ណៈ"។

**ឆ៖** លោក ខ្ញុំស្ដាប់អត់យល់សំណួរគាត់និយាយចប់អំមិញ។

**ស៖** តើតាមវិទ្យុលោកធ្លាប់ឮសំឡេងលោក ខៀវ សំផន លើកឡើងតាមវិទ្យុនាសម័យនោះអំពីការបោសសម្អាតខ្មាំងដែរឬទេ?

**ឆ៖** អត់។

**ស៖** នៅពេលដែលលោកធ្វើការងារនៅមន្ទីរ ក-៣ តើលោកធ្លាប់ឃើញមានមនុស្សបាត់ពីមន្ទីរនោះដែរឬទេ?

**ឆ៖** អត់ទេ។

[១១:១៣:០៧]

**ស៖** នៅពេលដែលលោកធ្វើការងារនៅមន្ទីរក-៣ តើមានអ្នកធ្វើការជាមួយលោកណាមួយដែលចង្អុលបង្ហាញលោកប្រាប់ថាអ្នកនេះអ្នកនោះ ឬជាអ្នកដឹកនាំរបបកម្ពុជាប្រជាធិបតេយ្យដែរឬទេ?

**ឆ៖** អត់ទេ។

**ស៖** តើលោកដឹងដែរឬទេ មេដឹកនាំរបបកម្ពុជាប្រជាធិបតេយ្យធ្លាប់បានរស់នៅជួបជុំគ្នានៅមន្ទីរ ក-៣ ដែរឬទេ?

**ឆ៖** អត់ដឹង។

**លោក ឃីត រេយ៉ន័រ៖**

សូមអរគុណលោក ទន់ សឿន។ ខ្ញុំបានបញ្ចប់ការតាំងសំណួរពីខាងតំណាងសហព្រះរាជអាជ្ញា។ សូមអរគុណច្រើន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្តទៅនេះអង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។ បើសិនជាមានសំណួរសូមអញ្ជើញ។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី**

**សួរដោយលោក ពេជ អង្គ៖**

**ស៖** បាទ សូមគោរពលោកប្រធាន។ ខ្ញុំសូមគោរពលោក លោកស្រីចៅក្រម អង្គសវនាការទាំងមូល សាធារណជននិងដើមបណ្ដឹងរដ្ឋប្បវេណី។ សូមជម្រាបសួរលោកសាក្សី។ ខ្ញុំមិនមានសំណួរសួរទៅលោកច្រើនទេ។ មានតែចំណុចតូចៗបន្តិចបន្តួចតែប៉ុណ្ណោះ។ ចង់សួរពាក់ព័ន្ធទៅនឹងលោកធ្វើការនៅ ក-៣ តើលោកអាចជម្រាបបានទេថាតើមានអ្នកណាខ្លះដែលធ្វើការនៅក-៣?

**ឆ៖** គឺខ្ញុំនៅក្រុម ពូផង់ ហ្នឹងគឺមួយក្រុមហ្នឹងមានគ្នា១២នាក់ហ្នឹង វាបែកខ្ញែកគ្នាអស់ មិនដឹងគេទៅណាណីអស់ទេ។

**ស៖** បាទ ប្រហែលជាសំណួររបស់ខ្ញុំមិនសូវច្បាស់សម្រាប់លោក។ ខ្ញុំសួរថាពេលដែលលោកធ្វើការនៅក-៣ ហ្នឹងលោកមានដឹងទេក្រៅពីក្រុម ពូផង់ ហ្នឹងតើលោកមានដឹងថាតើមានអ្នកណាផ្សេងទៀតទេធ្វើការនៅទីតាំង ក-៣ ហ្នឹង?

[១១:១៥:៥៩]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! សូមអញ្ជើញលោកមេធាវីជាតិការពារក្ដីលោក ខៀវ សំផន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំសូមជម្រាបអង្គសវនាការថា សាក្សីនេះមិនទាន់ មិនដែលបានបញ្ជាក់ថាខ្លួនធ្វើការនៅក-៣ទេ ហើយនៅក-៣ហ្នឹងខ្លួនរៀន រៀនវៃអង្គុលីលេខ។ អ៊ីចឹងចំណុចនេះវាអាចធ្វើឲ្យសាក្សីយល់ច្រឡំទៅលើសំណួរ។ សូមឲ្យមេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណីមេត្តាសម្រួលសំណួរនេះឡើងវិញ។ បាទសូមអញ្ជើញ!

**លោក ពេជ អង្គ៖**

បាទ អរគុណ ខ្ញុំនឹងសម្រួលសំណួរតាមហ្នឹង។

**សួរដោយលោក ពេជ អង្គ៖**

**ស៖** នៅពេលដែលលោកនៅ ក-៣ តើអាចនិយាយបានទេមានអ្នកណាខ្លះដែលនៅក-៣ ហ្នឹង ហើយមានអ្នកដែលនៅក-៣ហ្នឹង ទាំងធ្វើការទាំងស្នាក់នៅក-៣ ហ្នឹងមានគ្នាប៉ុន្មាននាក់? តើលោកអាចនិយាយបានទេ?

**លោក ទន់ សឿង៖**

**ឆ៖** នៅក្នុងក-៣ហ្នឹងគេមានផ្នែកៗគេ ខ្ញុំមិនអាចស្គាល់កន្លែងគេច្បាស់ទេ ព្រោះមិនមែនកន្លែងតូចទេកន្លែងហ្នឹងធំ គេមានផ្នែកៗគេនៅដោយឡែកៗពីគ្នា។

**ស៖** តើលោកអាចនិយាយបានខ្លះទេ អំពីផ្នែកៗដែលលោកស្គាល់នៅក-៣ហ្នឹង មានផ្នែកអ្វីខ្លះដែលលោកអាចនៅចងចាំ? ហើយផ្នែកនីមួយៗគេធ្វើការងារអ្វីខ្លះលោកអាចនិយាយបានទេ?

[១១:១៧:៤៩]

**ឆ៖** អត់ទេ! ព្រោះអីខ្ញុំនៅក្មេងនៅរៀន ខ្ញុំអត់មាន ការងារគេយើងមិនអាចដឹងពីកន្លែងគេផ្សេងបាន។

**ស៖** លោកបាននិយាយថាក-៣ ជាកន្លែងមួយធំ។ តើលោកអាចនិយាយបានទេធំយ៉ាងម៉េចទៅមានទីតាំងធំប៉ុនណា ផ្ទៃក្រឡា ឬក៏ថាមានផ្ទះដែលនៅចំណុះឲ្យក-៣ហ្នឹង នៅម្តុំកន្លែងក-៣ហ្នឹងមានផ្ទះដែលយ៉ាងម៉េចខ្លះ? មានអ្នកណាគេដែលនៅកន្លែងនោះខ្លះ?

**ឆ៖** គេនៅជាផ្នែកៗទេ ប៉ុន្តែដីប្រហែលជាឆ្ងាយ ប៉ុន្មានប្លុកនៅម្តុំនោះហ្នឹង មានគេ ខ្ញុំមិនអាចវាស់បានទេ ប្រហែលជាទំហំដីប្រហែលជា១គីឡូបួនជ្រុង បើថាតាមមើលទៅមានផ្ទះ។ ផ្នែកគេផ្នែកៗនៅដោយម្តុំៗទៅ តែមិនអាចទាក់ទងគ្នាទេ។ គ្រាន់តែជាក្រុមផ្នែកផ្សេងៗពីគ្នា។

**ស៖** ខ្ញុំចង់សួរបញ្ជាក់បន្តិច នៅកន្លែងទីតាំងក-៣ហ្នឹង មានសាលារៀននៅជិតក-៣ហ្នឹងដែរឬទេ? ហើយក-៣ហ្នឹងនៅខាងណានៃសាលារៀន នៅក-៣នោះ? ហើយសាលានោះគឺសាលាស្អីខ្លះលោកអាចបញ្ជាក់បានទេ?

[១១:១៩:៣៥]

**ឆ៖** ខ្ញុំអត់ស្គាល់សាលាហ្នឹង ប៉ុន្តែដឹងតែសាលារៀននៅពីខាងជើងជាប់ផ្លូវសាលារៀនហ្នឹងទៅរហូតទៅខាងត្បូងទៅ ប្រហែលដីប៉ុន្មានល្វែង ប៉ុន្មានប្លុក មានផ្លូវតូចៗហ្នឹង គេខណ្ឌប៉ុន្មានប្លុក ដូចបីប្លុកហើយបណ្តោយហ្នឹងវែង។

**ស៖** លោកអាចបញ្ជាក់បានទេ ខ្ញុំនឹងមិនសួរអំពីបញ្ហាក-៣ ហ្នឹងទៀតទេ។ ចង់សួររឿងបញ្ហាមួយផ្សេងទៀត ដែលលោកនិយាយថាលោក ខៀវ សំផន ជាមនុស្សស្មោះត្រង់។ ថាតើមូលហេតុអ្វីបានជាលោកនិយាយថា លោក ខៀវ សំផន ជាមនុស្សស្មោះត្រង់? តើលោកអាចធ្វើការអត្ថាធិប្បាយ និងបញ្ជាក់ពីមូលហេតុរឿងនេះបានទេ?

**ឆ៖** គាត់ស្មោះត្រង់ គឺគាត់មិនលោភលន់ មិនចង់ធ្វើអ្វី ហៅថាលោភអំណាច ឬមួយក៏ជាទ្រព្យសម្បត្តិអី គាត់មិនមាននេះទេ គឺគាត់ ហៅថាគោរពទៅតាមអ្វីដែលយើង ចង់និយាយថា មិនចង់មានចង់បានដោយ ហៅថាអំពើខុសច្បាប់ ឬមួយក៏ធ្វើអ្វីដើម្បីឲ្យបំផ្លាញប្រទេសជាតិ។

[១១:២១:២១]

**ស៖** តើក្នុងន័យថាដែលលោកនិយាយថា ស្មោះត្រង់ហ្នឹង គឺចង់និយាយផងដែរថា លោក ខៀវ សំផន គាត់ជាអ្នកគោរពតាមច្បាប់ ហើយគោរពពី តាមការណែនាំពីថ្នាក់លើ។ តើវាអាចមានន័យអ៊ីចឹងដែរឬទេ?

**ឆ៖** គាត់គោរពទៅអ្វីដែលគាត់ឃើញថាល្អ គាត់គោរព។ អានេះចង់និយាយថា ស្មោះត្រង់ហ្នឹងមិនមានថាលោភលន់ អំណាច ឬមួយអីទេ។ ចង់បញ្ជាក់ថា ជាទ្រព្យសម្បត្តិអី ក៏គាត់មិនមែនជាអ្នកលោភលន់ ស្មោះត្រង់ តែគេឲ្យអីគាត់យកហ្នឹង ប៉ុណ្ណឹង។ ចង់និយាយអ៊ីចឹង គឺសន្តានចិត្តគាត់គឺស្មោះត្រង់នឹងជាតិ។ គាត់មិនមានមហិច្ឆតាអីចង់ធ្វើអីក្រៅពីបម្រើជាតិ។

**ស៖** ខ្ញុំចង់សូមបញ្ជាក់បន្តិចដែលលោកមានប្រសាសន៍ថា គាត់ស្មោះត្រង់ គឺគាត់ពិនិត្យឃើញពីសកម្មភាពរបស់គាត់ នៅពេលដែលលោកនៅជាមួយគាត់ ក្រោយឆ្នាំ៧៩ ឬក៏គាត់ស្មោះត្រង់ដែរជាមនុស្សដែលមានលក្ខណៈស្មោះត្រង់ផងដែរ ដោយពិនិត្យទៅលើសកម្មភាពរបស់គាត់ ឬក៏អ្វីដែលថាគាត់បានធ្វើនៅមុនឆ្នាំ១៩៧៩?

[១១:២២:៥៦]

**ឆ៖** ខ្ញុំចង់និយាយនេះ និយាយក្រោយពី៧៩ហើយ ដែលខ្ញុំនៅជាមួយគាត់ហ្នឹង។ ខ្ញុំស្គាល់អត្តចរិតគាត់។ បើពីមុនមកខ្ញុំមិននេះទេ ប៉ុន្តែការរស់នៅជាមួយគាត់ក្រោយឆ្នាំ៧៩នេះ បញ្ជាក់ឃើញថាគាត់ជាមនុស្សស្លូតត្រង់។ គាត់មិនមានហៅថាមហិច្ឆតាអីនេះទេ។

**ស៖** នៅពេលដែលឆ្នាំ៧៩ អ៎! ក្រោយឆ្នាំ៧៩ លោកបានមានប្រសាសន៍ថាគាត់ជាមនុស្សស្មោះត្រង់ ហើយធ្វើការស្មោះត្រង់ គោរពច្បាប់ គាត់ធ្វើការតាមសម្បជញ្ញៈរបស់គាត់។ អ៊ីចឹងនៅពេលដែលលោក ខៀវ សំផន -- តើលោកធ្វើការសន្និដ្ឋាន ឬក៏ពិនិត្យឃើញបែបនេះ នៅពេលដែលលោក ខៀវ សំផន គាត់ធ្វើការជាមួយអ្នកផ្សេងៗទៀត ដែលជាមេដឹកនាំដូចគ្នា -- ដែលជាមេដឹកនាំនៃ -- អ្នកផ្សេងៗទៀត ឬក៏យ៉ាងម៉េច?

**ឆ៖** ខ្ញុំចង់និយាយថា គាត់ស្មោះត្រង់ចំពោះដែលគាត់បានធ្វើជាក្រសួងការបរទេសត្រីភាគីនេះ

គាត់គឺថា ការងារគាត់គឺគោរពសម្តេច ទៅតាមលក្ខខណ្ឌនៃត្រីភាគីនេះ។ គាត់មិនមានអីនេះទេ។ គាត់ប្រឹងធ្វើការ ដើម្បីហៅថា រួបរួមត្រីភាគីដើម្បីឆ្ពោះទៅហៅថា មានសន្តិភាពនៅកម្ពុជាតែប៉ុណ្ណឹង។

[១១:២៤:៥៦]

**ស៖** នេះខ្ញុំអាចទៅជា-- អាចជាសំណួរចុងក្រោយរបស់ខ្ញុំ។ លោកអាចបញ្ជាក់បានទេនៅពេលដែលលោក ខៀវ សំផន ធ្វើការជាមួយមេដឹកនាំផ្សេងៗទៀតឆ្នាំមួយពាន់ប្រាំបួន -- ក្រោយឆ្នាំ១៩៧៩ ថាតើលោក ខៀវ សំផន មានការពិភាក្សាញឹកញាប់អំពីការងាររបស់គាត់ជាមួយអ្នកដទៃដែរឬទេ? តើមានទម្លាប់ពិភាក្សាហ្នឹងដែរឬទេ?

**ឆ៖** គាត់ធ្លាប់ប្រាស្រ័យទាក់ទង។ តាមខ្ញុំឃើញហ្នឹងគឺខាងសហការីគាត់ ដូចជាអង្គទូតផ្សេងៗដំណាច់ឆ្នាំមក ត្រូវមកជួបជុំជាមួយគាត់អ៊ីចឹង។ ឯការខ្លឹមសារគាត់ពិភាក្សា ខ្ញុំមិនដឹងទេ ប៉ុន្តែរាល់ឆ្នាំឃើញអង្គទូតមកជួបជុំគាត់។

[១១:២៦:០០]

**លោក ពេជ អង្គ៖**

បាទ អរគុណលោកសាក្សី។ ខ្ញុំអត់មានសំណួរទៀតទេ។ អរគុណលោកប្រធានចំពោះការផ្តល់ឱកាសឲ្យខ្ញុំសួរសំណួរនេះ។ ខ្ញុំមិនដឹងថាសហការីរបស់នឹងមានសំណួរសម្រាប់សួរទៀតឬក៏អត់ទេ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក នួន ជា ប្រសិនបើមានបំណងចង់សួរ!

សូមអញ្ជើញលោក --

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ យើងខ្ញុំពុំមានសំណួរសួរនោះទេ។

**ប្រធានអង្គជំនុំ៖**

អរគុណ។ សូមអញ្ជើញលោកស្រីមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

[១១:២៦:៥៦]

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

ជម្រាបសួរលោកប្រធាន អស់លោក លោកស្រីចៅក្រមជាទីគោរព។ ភាគីទាំងអស់ជាទីគោរព។ មិនអ្វីជាសំខាន់នោះទេ ព្រោះថាខ្ញុំពុំមានសំណួរអ្វីទេ។ អ៊ីចឹងអំមិញលោកប្រធានបានមើលខ្ញុំនោះក៏អត់បញ្ហាអ្វីដែរ។

[១១:២៧:១០]

*(ចៅក្រមពិភាក្សាគ្នា)*

[១១:២៧:៥៩]

**ប្រធានអង្គជំនុំ៖**

លោក ទន់ សឿន ការស្តាប់សក្ខីកម្មរបស់លោករហូតដល់ពេលនេះបានចប់ហើយ ហើយវត្តមានរបស់លោកនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានេះ លែងមានភាពចាំបាច់ទៀតហើយ ហើយលោកអាចវិលត្រឡប់ទៅកាន់លំនៅដ្ឋានរបស់លោកវិញបានហើយ។ អង្គជំនុំជម្រះសូមអរគុណចំពោះលោកដែលបានលះបង់ពេលវេលាដ៏មានតម្លៃមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះក្នុងរយៈពេលកន្លះថ្ងៃនេះ ហើយដោយមានភាពអត់ធ្មត់ ខិតខំប្រឹងប្រែងឲ្យអស់ពីសមត្ថភាពរបស់ខ្លួន។ សក្ខីកម្មរបស់លោកនឹងអាចរួមវិភាគទានក្នុងការស្វែងរកការពិតក្នុងរឿងក្តីនេះ។ សូមជូនពរលោកមានសុខភាពល្អ ជួបតែសំណាងល្អ បានសេចក្តីសុខ សេចក្តីសម្រើន។ ហើយលោកអាចវិលត្រឡប់ទៅវិញបានហើយ។ លោកអាចចាកចេញបានហើយ។

[១១:២៨:៤៦]

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងមន្ត្រីនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនលោក ទន់ សឿន ត្រឡប់ទៅគោលដៅនៅណាដែលគាត់មានបំណងចង់ទៅ ឬក៏ទៅកាន់លំនៅដ្ឋានគាត់វិញបានហើយ! ហើយមេធាវីប្រឹក្សាដូចគ្នាបាទ។

*(សាក្សីចេញពីបន្ទប់សវនាការ)*

[១១:២៩:៣៤]

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការអញ្ជើញសាក្សីដែលមានរហស្សនាម TC-673 ចូលមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ។

*(សាក្សី TC-673 ចូលបន្ទប់សវនាការ)*

[១១:៣២:៤២]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្តីលោកស្រី តើលោកឈ្មោះអី?

**លោកស្រី សូ សុជាតិ៖**

**ឆ៖** ខ្ញុំ សូ សុជាតិ។

**ស៖** លោកស្រី សុជាតិ តើលោកស្រីមានអាយុប៉ុន្មានឆ្នាំ?

**ឆ៖** ៦២ឆ្នាំ។

**ស៖** អរគុណ ហើយសព្វថ្ងៃនេះលោកស្រីមានទីលំនៅ នៅទីកន្លែងណា?

**ឆ៖** ទីលំនៅបច្ចុប្បន្ននៅសឡា សង្កាត់មានជ័យ រាជធានីភ្នំពេញ។

**ស៖** បាទ អរគុណ។ លោកស្រីមានប្រកបមុខរបររកស៊ីធ្វើអ្វី?

**ឆ៖** មេផ្ទះ។

[១១:៣៣:៥៣]

**ស៖** អរគុណ ហើយឪពុកបង្កើតរបស់លោកស្រីឈ្មោះអី? ហើយម្តាយបង្កើតរបស់លោកស្រីគាត់ឈ្មោះអី?

**ឆ៖** ឪពុកបង្កើត សូ ឈឹម។ ម្តាយ អ៊ុង រៀម។

**ស៖** ហើយចុះស្វាមីរបស់លោកស្រីគាត់ឈ្មោះអី?

**ឆ៖** ឈ្មោះ ខៀវ សំផន។

**ស៖** បាទ អរគុណ ហើយលោកស្រីមានកូនប៉ុន្មាននាក់?

**ឆ៖** កូនបួននាក់។

**ស៖** បាទ អរគុណលោកស្រី ហើយដោយសារលោកស្រីត្រូវជាភរិយារបស់លោក ខៀវ សំផន ដែលជាជនជាប់ចោទនៅក្នុងរឿងក្តីនេះ តាមវិធានផ្ទៃក្នុងគឺមិនតម្រូវឲ្យលោកស្រីធ្វើសម្បថទេ។ ប៉ុន្តែដោយឡែកមានការពាក់ព័ន្ធជាមួយនឹងជនជាប់ចោទមួយរូបទៀត គឺលោក នួន ជា ហើយនិងភាគីដទៃទៀតនៃរឿងក្តី ហើយតើលោកស្រីមានជាប់ញាតិលោហិត ឬក៏ញាតិពន្ធជាមួយនឹងភាគីដទៃទៀត នៃ

រឿងក្ដីនេះ ឬក៏ជាមួយនឹងជនជាប់ចោទ នួន ជា ដែរឬទេ?

**ឆៈ** អត់មានជាប់សាច់ញាតិអីជាមួយទេ។

**សៈ** អរគុណ ហើយលោកស្រីបានស្បថរួចហើយឬនៅ ក្នុងករណីដែលត្រូវឆ្លើយតបទៅនឹងសំណួរពាក់ព័ន្ធនឹងករណីលោក នួន ជា?

**ឆៈ** បានស្បថរួចហើយ។

**សៈ** បាទ អរគុណលោកស្រី។ អង្គជំនុំជម្រះសូមប្រាប់អំពីសិទ្ធិនិងករណីយកិច្ចលោកស្រី ក្នុងនាមលោកស្រីជាសាក្សីនៅចំមុខអង្គជំនុំជម្រះ។ ក្នុងនាមលោកស្រីជាសាក្សីនៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការចំពោះមុខអង្គជំនុំជម្រះនៅពេលនេះ លោកស្រីអាចបដិសេធក្នុងការឆ្លើយតបទៅនឹងសំណួរ ឬការធ្វើអំណះអំណាងណាមួយ ឬច្រើនដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង។ សិទ្ធិមិនធ្វើសក្ខី ប្រឆាំងនឹងខ្លួនឯង។ ហើយនៅថ្ងៃនេះ គឺអង្គជំនុំជម្រះបានសម្របសម្រួលជាមួយនឹងអង្គភាពគាំពារសាក្សីនិងអ្នកជំនាញ ផ្ដល់នូវមេធាវីប្រឹក្សាសាក្សីមួយរូបដែលនៅជិតក្បែរលោកស្រីនោះដើម្បីពិភាក្សានៅក្នុងករណីមានសំណួរណាមួយដែលការសួររបស់ភាគី ឬក៏របស់ចៅក្រមមានការសង្ស័យថាមានការដាក់បន្ទុកលើលោកស្រី គឺលោកស្រីពិភាក្សាថា តើលោកស្រីត្រូវឆ្លើយ ឬក៏មិនឆ្លើយតប។

[១១:៣៦:២៩]

ទន្ទឹមនឹងនេះ លោកស្រីក្នុងនាមជាសាក្សីត្រូវមានករណីយកិច្ចត្រូវតែឆ្លើយតបទៅនឹងរាល់សំណួរដែលសួរឡើងដោយភាគី ឬដោយចៅក្រមនៃអង្គជំនុំជម្រះ។ ហើយទន្ទឹមនឹងហ្នឹងដែរគឺសាក្សីត្រូវឆ្លើយការណាដែលពិត ដែលលោកស្រីបានដឹង បានឮ បានឃើញ បានចងចាំ ឬក៏បានសង្កេត ឬក៏មានបទពិសោធន៍ផ្ទាល់ពាក់ព័ន្ធទៅនឹងអង្គហេតុ ឬក៏ព្រឹត្តិហេតុទាំងឡាយដែលភាគីនិងអង្គជំនុំជម្រះនឹងសួរចំពោះលោកស្រី។

ហើយលោកស្រីដែលធ្លាប់បានផ្ដល់សក្ខីកម្ម ឬក៏ផ្ដល់កិច្ចសម្ភាសន៍ជាមួយអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេ ប៉ុន្មានឆ្នាំកន្លងទៅនេះ?

**ឆៈ** អត់មានទេ។

**ប្រធានអង្គជំនុំៈ**

បាទ អរគុណ។ ហើយអង្គជំនុំជម្រះសូមផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដីលោក ខៀវ សំផន ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ មុនភាគីដទៃទៀតនៃរឿងក្ដី។ ហើយ

ក្រុមមេធាវីការពារក្តី ខៀវ សំផន រួមហ្នឹងមេធាវីការពារក្តី នួន ជា មានរយៈពេលកន្លះថ្ងៃនៅក្នុងការសួរសាក្សីរូបនេះ។ សូមអញ្ជើញ!

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក អាកទ្បូ វ៉េកគែន៖**

**ស៖** សូមអរគុណលោកប្រធាន។ ជម្រាបសួរលោកស្រី។ បាទ ខ្ញុំសូមឲ្យលោកស្រីជម្រាបជូនតុលាការជាបឋមអំពីដើមកំណើតរបស់អ្នកស្រី? មុខរបរពីដើមនៅក្នុងសង្គម មុខរបរអីគេ? ហើយឪពុកម្តាយឈ្មោះអីដែរ?

**លោកស្រី សូ សុជាតិ៖**

**ឆ៖** នាងខ្ញុំឈ្មោះ សូ សុជាតិ កើតនៅភូមិកក់ពោន ឃុំស្រែធំ ស្រុករវៀង ខេត្តព្រះវិហារ។ ឪពុកឈ្មោះ សូ ឈឹម ម្តាយ ឈ្មោះ អ៊ុង រៀម របររកស៊ីធ្វើស្រែ។ ហើយខ្លួនខ្ញុំផ្ទាល់កាលនោះនៅរៀន។

**ស៖** លោកស្រីបានប្រាប់ថា ឪពុកម្តាយរបស់លោកស្រីជាកសិករ។ តើគាត់មានដីធ្លីច្រើនទេ?

**ឆ៖** គាត់មានដីធ្លីល្មមចិញ្ចឹមកូនគ្រប់គ្រាន់។

**ស៖** តើនៅក្នុងគ្រួសាររបស់លោកស្រី លោកស្រីមានបងប្អូន ប៉ុន្មាននាក់ដែរ?

[១១:៤០:០០]

**ឆ៖** ខ្ញុំមានបងប្អូនប្រាំបួននាក់។

**ស៖** ហើយនៅក្នុងចំណោមបងប្អូនរបស់លោកស្រី លោកស្រីជាកូនទីប៉ុន្មានដែរ?

**ឆ៖** ខ្ញុំជាកូនទី៦។

**ស៖** តើលោកស្រីអាចជម្រាបជូនបានតុលាការទេ ថាអ្នកស្រីធ្លាប់បានទៅរៀនសូត្រដែរឬទេ ហើយរៀនដល់ថ្នាក់ទីប៉ុន្មាន? ហើយឈប់រៀននៅអាយុប៉ុន្មានឆ្នាំដែរ?

**ឆ៖** ខ្ញុំធ្លាប់នៅរៀននៅសាលានៅអនុវិទ្យាល័យរវៀង ថ្នាក់ទី៥។

**ស៖** ហើយបន្ទាប់ពីថ្នាក់ទី៥មកហ្នឹង លោកស្រីបានឈប់រៀន ឬក៏យ៉ាងម៉េច អ៊ីចឹងមែនទេ?

**ឆ៖** ចាស បានឈប់រៀន។

**ស៖** ហើយកាលដែលលោកស្រីឈប់រៀនហ្នឹង លោកស្រីមានអាយុប៉ុន្មានដែរ? លោកស្រីអាចជម្រាបជូនតុលាការបានទេថា លោកស្រីអង្កាល់ដែលលោកស្រីឈប់រៀនទុំងឆ្នាំណាដែរ ប្រហាក់ប្រហែល?

[១១:៤២:១០]

**ឆ៖** អាយុ១៨ឆ្នាំ ឆ្នាំ១៩៦៩។

**ស៖** តើហេតុអ្វីបានជាអ្នកស្រីឈប់រៀន? ហើយបន្ទាប់មកហ្នឹងលោកស្រីបានប្រកបមុខរបរអ្វីដែរ ធ្វើអីដែរក្រោយពីឈប់រៀនមកនោះ?

**ឆ៖** ក្រោយពីឈប់រៀននាងខ្ញុំនៅផ្ទះ ប្រកបរបរជួយធ្វើស្រែឪពុកម្ដាយ។

**ស៖** ហើយលោកស្រីជួយកិច្ចការធ្វើស្រែចម្ការឪពុកម្ដាយហ្នឹងរយៈពេលប៉ុន្មានឆ្នាំដែរ?

**ឆ៖** រយៈពេល១ឆ្នាំៗជាង។

**ស៖** ហើយ១ឆ្នាំជាងក្រោយមកនុ៎ង មានរឿងអ្វីកើតឡើងដែរ?

**ឆ៖** ១ឆ្នាំជាងកើតឡើងមានរដ្ឋប្រហារ។

**ស៖** បាទ លោកស្រីនិយាយអំពីរដ្ឋប្រហារឆ្នាំ១៩៧០មែនទេ?

**ឆ៖** ចាស។

**ស៖** លោកស្រីអាចជម្រាបជូនតុលាការបានដែរឬទេ អំពីផលវិបាកនៃរដ្ឋប្រហារនេះចំពោះរូបលោកស្រី? នៅពេលដែលលោកស្រីជួយឪពុកម្ដាយរបស់លោកស្រីនោះ ជួយដល់ពេលរដ្ឋប្រហារ ហើយអ៊ីចឹងខ្ញុំចង់ដឹងអំពីផលប៉ះពាល់ ឬក៏ផលពិបាកផ្នែកនយោបាយហ្នឹងទៅលើក្រុមគ្រួសាររបស់លោក ហើយនិងរូបលោកស្រីផ្ទាល់។

[១១:៤៥:០៣]

**ឆ៖** ក្នុងពេលរដ្ឋប្រហារ គឺកើតសង្គ្រាម។ ដូច្នេះមានការលំបាកក្នុងការបង្កបង្កើនផល រស់នៅចិញ្ចឹមជីវិត ដោយសារមានវ៉ៃគ្នា ទម្លាក់គ្រាប់បែក។ អស់។

**ស៖** ក៏ប៉ុន្តែអម្បាញ់មិញនេះ សំណួរខ្ញុំនោះ ថាតើរដ្ឋប្រហារនេះមានផលវិបាកយ៉ាងម៉េចដែរ? ដូចការទម្លាក់គ្រាប់បែក ឬក៏សង្គ្រាមនេះជាដើមនេះ មានផលប៉ះពាល់យ៉ាងម៉េចដែរ លើជីវិតរបស់លោកស្រី? លោកស្រីបានជម្រាបថា លោកស្រីបានឈប់រៀនដើម្បីទៅជួយកិច្ចការស្រែចម្ការដល់ឪពុកម្ដាយរបស់លោក។ ហើយអ៊ីចឹងខ្ញុំចង់ដឹង អម្បាញ់មិញនេះចង់ដឹងពីផលប៉ះពាល់ទៅលើជីវិតរបស់លោកស្រី?

**ឆ៖** ប៉ះពាល់មកលើជីវិតរបស់ខ្ញុំ មិនជារូប គឺមិនលំបាកផ្លូវចិត្តនេះទេ។ គឺគ្រាន់តែលំបាកផ្លូវក្នុងកិច្ចការបង្កបង្កើនផល ធ្វើស្រែ ធ្វើចម្ការ។ ខ្លាច ព្រោះខ្លាចសង្គ្រាម ដូចនេះវាប៉ះផ្លូវចិត្ត។ មានតែ

ប៉ុណ្ណឹង។ ខ្ញុំសូមអរគុណ។

**ស៖** បាទ ដូច្នេះលោកស្រីបានឈប់ជួយកិច្ចការស្រែចម្ការ ទៅដល់ឪពុកម្ដាយរបស់លោកស្រីនុ៎ង។ អ៊ីចឹងមែនទេ?

**ឆ៖** ក្រោយមកមានខាងផ្នែកនេះទៅ ខាងផ្នែកគេទៅអប់រំរៀនសូត្រប្រហែលជាពាក់កណ្ដាល ៧០។ អ៊ីចឹងទៅក៏គេឲ្យចូលព្រៃដើម្បីតស៊ូអីអ៊ីចឹង។

**ស៖** តើអ្នកណាគេជាអ្នកស្នើឲ្យលោកស្រីទៅទទួលការសិក្សារៀនសូត្រ ហើយនិងទៅចូលព្រៃម៉ាគីនោះ?

**ឆ៖** ជាដំបូង ឃើញមានស្ត្រីចំណាស់បន្តិច គាត់បានអញ្ជើញទៅ ហើយហៅផ្នែកស្រីៗ ប្រុសៗនៅក្នុងភូមិបានមកអប់រំរៀនសូត្រ គឺគាត់ឈ្មោះ អ៊ំយឹម។

[១១:៤៩:០១]

**ស៖** ហើយគេបាននិយាយអ្វីខ្លះប្រាប់អ្នកស្រី នៅពេលដែលសិក្សារៀនសូត្រហ្នឹង?

**ឆ៖** នៅពេលនោះ គេបានប្រាប់ថាយើងមានរដ្ឋប្រហារទម្លាក់សម្ដេច។ ដូច្នេះ យើងនាំគ្នាតស៊ូដើម្បីដណ្ដើមឯករាជ្យមកវិញ ហើយនៅក្នុងនោះដើម្បីតស៊ូបាន ទាល់តែយើងទាំងអស់គ្នាធ្វើបដិវត្តន៍។ ហ្នឹងគេនិយាយអ៊ីចឹង។ ខ្ញុំសូមអស់។

**ស៖** តើអ្នកដែលនិយាយអំពីបញ្ហាទាំងអស់នេះ ប្រាប់អ្នកស្រីហ្នឹងឈ្មោះអ្វីដែរ? ហើយពួកគេហ្នឹងធ្វើការតំណាងឲ្យអង្គការណាដែរ?

**ឆ៖** កាលនោះ អត់ទាន់ដឹងតំណាងអង្គការណាទេ គាត់ឈ្មោះអ៊ំយឹម។ អត់ដឹងតំណាងអង្គការណាទេកាលនោះ។

**ស៖** ក៏ប៉ុន្តែគេស្នើឲ្យលោកស្រីតស៊ូប្រឆាំងនឹងអំណាចរបស់សេនាប្រមុខ លន់ នល់ អ៊ីចឹងមែនទេ?

**ឆ៖** ចាស ពិតមែន។

**ស៖** តើអ្នកស្រីបានចូលរួមក្នុងចលនាហ្នឹងទេ នៅពេលហ្នឹង? នៅពេលដែលគេស្នើឲ្យអ្នកស្រីតស៊ូប្រឆាំងហ្នឹង អ្នកស្រីបានចូលរួមនឹងចលនាហ្នឹងទេ?

**ឆ៖** នាងខ្ញុំបានចូលរួមនៅក្នុងចលនាហ្នឹង។

[១១:៥១:៣៨]

**ស៖** តើអ្នកស្រីបានចូលប្រលូកក្នុងចលនាហ្នឹងតាមរបៀបណាដែរ? លោកស្រីអាចជម្រាបជូនតុលាការបានទេ?

**ឆ៖** យើងខ្ញុំបានចូលរួមនៅក្នុងចលនាហ្នឹងគឺទី១ ខាង -- គេបានបង្កើតជាក្រុមតូចៗនៅក្នុងភូមិដូចជាក្រុមនារីប្រវាស់ដៃ ក្រុមសមាគមនារីជួយគ្នាទៅវិញទៅមក ក្រុមពេទ្យភូមិ ក្រុមនីរសារភូមិ និងក្រុមដឹកជញ្ជូនភូមិ។

**ស៖** តើរូបអ្នកស្រីផ្ទាល់នេះ លោកស្រីបានធ្វើអ្វីដែរនៅក្នុងចលនាហ្នឹង?

**ឆ៖** ពេលនោះ ខ្ញុំធ្វើពេទ្យភូមិ។

**ស៖** តើអ្នកស្រីបានទទួលការបណ្តុះបណ្តាលដែរឬទេ ដើម្បីឲ្យក្លាយជាអ្នកពេទ្យ -- ក្លាយជាពេទ្យនេះ?

**ឆ៖** មានគ្រូពេទ្យនៅក្នុងស្រុកពីសង្គម គេឲ្យខ្ញុំទៅរៀនចាក់ រៀនព្យាបាលជាក់ស្តែងជាមួយនឹងគ្រូពេទ្យ គាត់ឈ្មោះ លៀន – គ្រូពេទ្យនៅស្រុក។

[១១:៥៤:០៤]

**ស៖** លោកស្រីទើបតែនិយាយថា លោកស្រីជាពេទ្យនៅក្នុងភូមិហ្នឹង។ អ៊ីចឹងបានន័យថាអ្នកស្រីនៅក្នុង-- នៅជាមួយឪពុកម្តាយរបស់លោកស្រីនៅឡើយទេ នៅពេលដែលលោកស្រីចូលរួមក្នុងចលនានុ៎ងមែនទេ?

**ឆ៖** នៅជាមួយឪពុកម្តាយនៅឡើយ។

**ស៖** តើលោកស្រីស្ថិតនៅ -- ធ្វើជាពេទ្យនៅក្នុងភូមិនុ៎ងរយៈពេលយូរទេ? អ្នកស្រីអាចជម្រាបជូនតុលាការបានទេអំពីពេលវេលាដែលលោកស្រីធ្វើជាពេទ្យនេះ?

**ឆ៖** ប្រហែលជា៣ ឬ៤ខែ ជិតដាច់ៗឆ្នាំ៧០។

**ស៖** បាទ នៅក្នុងវិស័យវេជ្ជសាស្ត្រនេះ តើអ្នកស្រីធ្លាប់បានព្យាបាលអ្នកជំងឺ -- អ្នកភូមិ ឬក៏យុទ្ធជនដែរឬទេ? ខ្ញុំចង់ដឹងថាតើជាប្រភេទអ្នកជំងឺយ៉ាងម៉េចដែរ ដែលលោកស្រីធ្លាប់បានព្យាបាល?

**ឆ៖** មានប្រភេទជំងឺ មានគ្រុនចាញ់ មានរាក ក្តៅខ្លួន។ យើងខ្ញុំយកថ្នាំ ឬក៏ពេទ្យ -- ខាងពេទ្យឲ្យទៅចាក់ យើងខ្ញុំចាក់។ អាហ្នឹងមានពេទ្យអ្នកពិនិត្យ។ មានប៉ុណ្ណឹង។

[១១:៥៦:៣៥]

**ស៖** បាទ អ្នកស្រីទើបតែនិយាយអំពីថ្នាំ ពីអ៊ីហ្នឹង តើ -- ខ្ញុំចង់ដឹងថាតើអ្នកស្រីប្រើសម្ភារៈ

បរិក្ខារពេទ្យហ្នឹងយ៉ាងម៉េចដែរក្នុងពេលចាក់ថ្នាំហ្នឹង? បាទ ខ្ញុំនឹងសួរបញ្ជាក់ឡើងវិញ។ តើវាជាថ្នាំបុរាណ ឬក៏ថ្នាំទំនើប ឬយ៉ាងម៉េចដែរ?

**ឆ៖** ពេលនោះ គឺថ្នាំសម័យទំនើប អត់មានថ្នាំបុរាណទេ។

**ស៖** លោកស្រីបានឆ្លើយថា លោកស្រីបានធ្វើជាពេទ្យនេះ អស់រយៈពេល៣ខែ។ អ៊ីចឹងខ្ញុំចង់ដឹងថាពេលក្រោយមកធ្វើអីទៀត? ពេលក្រោយពី៣ខែនុ៎ង?

**ឆ៖** ពេលក្រោយបានទៅចូលរួមនៅក្នុងកន្លែងក្រុមមួយដែលមានប្រធានភូមិ មាន -- អ្នកនៅក្នុងមន្ទីរហ្នឹងមានប្រុសមានស្រីច្រើន។ ដូច្នេះ ខ្ញុំទៅចូលរួមនៅក្នុងហ្នឹងហើយ នៅធ្វើពេទ្យដដែល។

[១១:៥៨:២៧]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកមេធាវី អរគុណសាក្សី។ ឥឡូវនេះដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយសាមសិបនាទីរសៀលនេះ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ឬក្នុងអំឡុងពេលសម្រាកថ្ងៃត្រង់ ហើយនិងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនេះវិញនៅវេលាម៉ោងមួយសាមសិបនាទីនៅរសៀលនេះ។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ទៅកាន់បន្ទប់រង់ចាំនៅពីក្រោមសាលសវនាការនេះ ហើយនិងឲ្យនាំខ្លួនគាត់ត្រឡប់មកចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញនៅរសៀលនេះឲ្យបានមុនម៉ោងមួយសាមសិបនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១១:៥៩ នាទី ដល់ម៉ោង ១៣:៤៥ នាទី)*

[១៣:៤៥:៣២]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយជាបន្តទៅនេះផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីមានឱកាសក្នុងបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។ សូមអញ្ជើញ!

**លោក គង់ សំអុន៖**

លោកប្រធានសូមមេត្តាអនុញ្ញាតរង់ចាំសហមេធាវីអន្តរជាតិ ដោយសារមុននេះអំមិញប្រកាសថាសម្រាក២០នាទី ដល់ពេលអ៊ីចឹងទៅ គាត់ទៅការិយាល័យដើម្បីរៀបចំឯកសារ។

*(សម្រាករយៈពេលខ្លី)*

[១៣:៤៨:១៧]

**លោក អាកឡូវ វែកគែន៖**

សូមអភ័យទោសអស់លោក លោកស្រីចៅក្រម។

**សួរដោយលោក អាកឡូវ វែកគែន៖**

**ស៖** លោកស្រី យើងនឹងបន្តការសួរសំណួរលោកស្រីតទៅទៀត។ កាលពីព្រឹកមិញនេះ ចម្លើយចុងក្រោយរបស់លោកស្រី គឺថាបានបញ្ជាក់ថា លោកស្រីធ្វើជាពេទ្យ លោកស្រីបានចូលរួមជាមួយក្រុមមួយដែលដឹកនាំដោយមេភូមិម្នាក់ ហើយបន្ទាប់មកទៀតលោកស្រីក៏បន្តការងារជាពេទ្យតទៅទៀត។ ដូច្នេះដើម្បីឲ្យយើងអាចទៅមុខបានលឿននោះ ខ្ញុំចង់ដឹងថាតើលោកស្រីបានជួបលោក ខៀវ សំផន នៅពេលណា ហើយជួបនោះជួបដោយរបៀបណា?

**លោកស្រី សូ សុជាតិ៖**

**ឆ៖** ក្រោយពីពេលចូលរួមនៅក្នុងក្រុមហ្នឹង ហើយរៀនសូត្រអីហើយ លោកអ៊ំយឹមហ្នឹង គាត់ក៏បានអំពាវនាវថា តើអ្នកណាខ្លះទៅចូលរួមតស៊ូនៅជាមួយពួកគាត់នៅក្នុងព្រៃ? ពេលនោះអ្នកទាំងអស់គ្នាច្រើនដែរក៏ចូលទៅជាមួយគាត់។ ដូច្នេះហើយបានជាក្រុមដែលខ្ញុំនៅជាមួយហ្នឹង គឺត្រៀមដើម្បីទៅជាមួយគាត់។ ប្រហែលជាឆ្នាំ៧១ ជាងពាក់កណ្តាលព្រោះច្រើនខែដែរ ខ្ញុំមិនចាំច្បាស់។ ហ្នឹងគាត់រៀបចំដើម្បីធ្វើដំណើរទៅកន្លែងពួកគាត់។

**ស៖** យើងនឹងបន្តទៅលើបញ្ហានេះទៀត ប៉ុន្តែមុននឹងបន្តខ្ញុំចង់សួរពាក់ព័ន្ធនឹងអ្វីដែលលោកស្រីបានឆ្លើយអម្បាញ់មិញនេះ។ ខ្ញុំចង់ដឹងថា តើលោកស្រីចូលចលនាហ្នឹងដោយស្ម័យប្រវត្តិមែនទេដើម្បីប្រឆាំងនឹងរបប លន់ នល់ ឬក៏លោកស្រីចូលហ្នឹងគឺថាជាការបង្ខំ ឬក៏ជាជម្រើសផ្ទាល់ខ្លួន?

[១៣:៥១:១៥]

**ឆ៖** ពេលនោះ តាមការពិតទៅមិនដឹងថាទៅនឹងមានអីទេ គ្រាន់តែដឹងថា រដ្ឋប្រហារហើយមានសង្គ្រាម ហើយមានចក្រពត្តិអាមេរិក ហើយនិងលន់នល់។ ដូច្នេះដើម្បីតស៊ូប្រឆាំងនឹងពួកនេះបានយើងធ្វើបដិវត្តន៍ទៅតស៊ូ ហើយគេពន្យល់អ៊ីចឹងមក ក៏ទាំងអស់គ្នាអត់មានអ្នកណាបង្ខំទេ គឺថាស្ម័គ្រចិត្ត។ ដល់អ៊ីចឹងទៅគឺថាស្ម័គ្រចិត្តទាំងអស់គ្នា អ៊ីចឹងហើយទៅដោយគេហៅថាមានគំនិតមួយតែប៉ុណ្ណឹងថាទៅចូលរួមដើម្បីចង់ឲ្យប្រទេសជាតិមកបានឯករាជ្យឡើងវិញ ថាអ៊ីចឹង មិនយល់ពីបញ្ហាអីទេ ពីព្រោះគេការរៀនសូត្រគឺមានតែប៉ុណ្ណឹង។

**ស៖** ពាក់ព័ន្ធទៅនឹងបញ្ហានេះដដែល លោកស្រីបានបញ្ជាក់ថា លោកស្រីបានចូលរួមក្នុងកិច្ចប្រជុំ។ តើនៅក្នុងកិច្ចប្រជុំទាំងនោះគេមាននិយាយអំពីលទ្ធិកុម្មុយនីស្ត ទ្រឹស្តីនយោបាយកុម្មុយនីស្ត ឬក៏និយាយអំពីនយោបាយទូទៅ? ឬក៏មានចំណុចផ្សេងទៀត? បើសិនជាចំណុចផ្សេងតើនិយាយអំពីអ្វីខ្លះ?

**ឆ៖** ពេលនោះគឺគ្រាន់តែប្រជុំរៀនសូត្រ អប់រំរៀនសូត្រជាគ្នាច្រើន អ៊ីចឹងគឺមិនមានអីនិយាយអំពីបដិវត្តន៍សង្គមនិយមនិយាយអំពីអីទេ គឺគ្រាន់តែធ្វើបដិវត្តន៍ តស៊ូធ្វើបដិវត្តន៍តែប៉ុណ្ណឹង។ ហើយប្រឆាំងជាមួយចក្រពត្តិលន់នល់អ៊ីចឹង។

[១៣:៥៣:៣១]

**ស៖** នៅពេលនោះតើអ្នកបង្រៀន ឬក៏អ្នកដឹកនាំកិច្ចប្រជុំនោះហៅខ្លួនឯងថាជាខ្មែរក្រហមដែរឬទេ? តើពួកគេតែងតែប្រាប់ថាពួកគេជាខ្មែរក្រហមដែរឬទេពេលប្រជុំនោះ?

**ឆ៖** ពេលនោះអត់មានខ្មែរក្រហមទេ គេប្រើពាក្យអ្នកតស៊ូ ដើម្បីប្រឆាំងចក្រពត្តិ។

**ស៖** ឥឡូវនេះសូមត្រឡប់មកនិយាយអំពីហេតុការណ៍បន្តបន្ទាប់គ្នារហូតទៅដល់លោកស្រីបានជួបគ្នាជាមួយលោក ខៀវ សំផន ហ្នឹង។ អ៊ីចឹងតើចំពោះលោកស្រីហ្នឹងហេតុការណ៍ហ្នឹងវាយ៉ាងម៉េចដែរ បានជាបានទៅជួបលោក ខៀវសំផន នោះ?

**ឆ៖** ពេលនោះបានរៀបចំធ្វើដំណើរដោយមនុស្សច្រើនប្រហែលជា២០០នាក់ដែលចេញដំណើរពីស្រុករវៀងខេត្តព្រះវិហារទៅធ្វើដំណើរដោយដើរ ចេញប្រហែលពាក់កណ្តាលឆ្នាំ១៩៧១ ឬមួយក៏ចុងអាហ្នឹងខ្ញុំអត់ចាំច្បាស់ ប្រហែលប៉ុណ្ណឹង។ ចេញដំណើរតាមដែលគាត់ឲ្យទៅ ហើយមានអ្នកនាំទៅពីរនាក់។ ដូច្នេះដើររហូតតាមផ្លូវព្រៃ រហូតទៅដល់គេហៅថាស្ទឹងជីនិត អ៎! មិនមែនស្ទឹងជីនិតទេ គេហៅភូមិអី ភូមិត្រពាំងទឹម។ គេហៅទៅជិតស្ទឹងជីនិត។

[១៣:៥៥:៤១]

**ស៖** ហើយនៅពេលដែលទៅដល់ភូមិត្រពាំងទឹមជិតស្ទឹងជីនិតហ្នឹង លោកស្រីធ្វើអ្វីដែរ?

**ឆ៖** ទៅដល់កន្លែងនោះនៅសម្រាកទាំងអស់គ្នាប្រហែលជា៣ថ្ងៃ ហើយបានអ្នកទាំងអស់គ្នាមានអ្នកគេមកនីរសារ ឬក៏ស្ទីទេកាលនុំងគេហៅនីរសារ មកយកទាំងអស់គ្នាចេញដំណើរតទៅទៀត។ ហើយនៅតែខ្ញុំម្នាក់ឯងទេ នៅបន្តនៅនោះប្រហែលមួយរយៈខ្លីទេ ប៉ុន្មានថ្ងៃខ្ញុំអត់ នៅចាំកន្លែងហ្នឹង។

**ស៖** សូមលោកស្រីរៀបរាប់បន្តទៀត ខ្ញុំកំពុងតែស្តាប់លោកស្រីហើយ។ លោកស្រីពន្យល់ថាលោកស្រីនៅទីនុំងប៉ុន្មានថ្ងៃទៀត។ អ៊ីចឹងតើនៅនុំងលោកស្រីមានភារកិច្ចអ្វីខ្លះដែរនៅពេលនុំង?

**ឆ៖** នៅកន្លែងនោះមានអ្នកម្ចាស់ផ្ទះ ដែលនៅកន្លែងហ្នឹងគេមានចិញ្ចឹមជ្រូកច្រើនដែរ។ ដូច្នេះខ្ញុំក៏ជួយឲ្យបាយជ្រូក ជួយអីប៉ុន្មាននេះហ្នឹងនៅជួយឲ្យបាយជ្រូក ជួយបបរបាយជ្រូកគេហ្នឹង។ រហូតដល់ចេញដំណើរ រហូតដល់មានអ្នកមកនាំចេញដំណើរ។ ចេញដំណើរប្រហែលតែបន្តិចនេះទៅ ដើរទៅក៏ដល់ស្ទឹងជីនិត ឆ្លងស្ទឹងជីនិត។ ឆ្លងស្ទឹងជីនិតហើយក៏មានកន្លែងនេះ គេក៏ប្រាប់ថាកន្លែងអ្នកដឹកនាំ។ កន្លែងអ្នកដឹកនាំខ្ញុំក៏ទៅដល់កន្លែងអ្នកដឹកនាំហ្នឹង ហើយទៅហ្នឹងគឺគេឲ្យដាំបាយ ហើយនិងរួមធ្វើពេទ្យអីខ្លះ។

[១៣:៥៧:៤៩]

ហើយដល់ពេលនោះប្រហែលជា២ថ្ងៃអី មិនទាន់ចេញទៅណាទេ នៅតែដាំបាយ ហើយនៅដេកនៅផ្ទះបាយហ្នឹង ជាមួយមានគ្នាប្រហែលបីនាក់ៗបួននាក់ដែលនៅកន្លែងហ្នឹងស្រាប់។ ហើយពេលនោះអត់ទាន់មានឃើញអ្នកណាទេ ខ្ញុំនៅហ្នឹងផ្ទះបាយក៏អត់ដើរទៅណាដែរ។ ប្រហែលជាពីរបីថ្ងៃ បីបួនថ្ងៃក៏អ្នកទទួលខុសត្រូវនៅកន្លែងហ្នឹងគឺបានរៀបរាប់ថា ជួយលើកបាយទៅ! ជួយលើកបាយយើងខ្ញុំក៏លើកបាយទៅកន្លែងតុ ពីចង្ក្រានបាយទៅកន្លែងតុវាឆ្ងាយដែរ ដាំបាយហើយលើកបាយទៅ។ ពេលនោះក៏ឃើញលោក ប៉ុល ពត, នួន ជា ហើយនិងលោក ខៀវ សំផន។ បើកាលហ្នឹងមិនទាន់ស្គាល់ថាជា ខៀវ សំផន ទេ គ្រាន់តែដឹងថាឈ្មោះគាត់ គឺបងហែម។

**ស៖** កន្លែងដែលលោកស្រីដាំបាយ ហើយនិងកន្លែងដែលលោកស្រីយកម្ហូបទៅហ្នឹងនៅក្នុងផ្ទះវីឡាមួយ ឬក៏ម៉េច? តើលោកស្រីរៀបរាប់បានទេពីកន្លែងនុំង?

**ឆ៖** នៅកន្លែងដាំបាយហ្នឹង គឺនៅក្នុងព្រៃមានដើមឈើពីលើគ្របជិត ខាងក្រោមជម្រះស្អាត ហើយចង្ក្រានបាយជីកជារណ្តៅធំ ហើយចង្ក្រានចុះទៅក្រោមមានគេហៅថា គេធ្វើជាចង្ក្រានចោះ

ហើយមានបំពង់បង្ហុយយ៉ាងវែង ហើយដាំបាយនៅកន្លែងហ្នឹង ហើយធ្វើបាយនៅក្នុងដីផ្ទាល់ហ្នឹង ហើយ ដុះដុតខស ហើយកន្លែងនេះគឺកន្លែងហូបបាយ គឺខ្ទមស្លឹក ប្រក់ស្លឹក អត់មានជញ្ជាំងទេ តុគឺឈើមូលៗ ប៉ុនកដៃ រៀបជាវែងៗ។ កន្លែងអង្គុយ គឺឈើប៉ុនៗកដៃតម្រៀបគ្នាជាវែងៗ អង្គុយតៗគ្នា ទល់មុខគ្នា។ ហើយចម្ងាយប្រហែលជាពីផ្ទះបាយទៅ ប្រហែលជា១០០ម៉ែត្រ តាមការប៉ាន់ស្មាន។

[១៤:០០:៥៩]

**ស៖** ១០០ម៉ែត្រហ្នឹងបណ្តោយ ឬក៏យ៉ាងម៉េច? គេបកប្រែឲ្យខ្ញុំស្តាប់អំមិញថា បណ្តោយ១០០ ម៉ែត្រ។ ខ្ញុំអត់យល់?

**ឆ៖** ១០០ម៉ែត្រពីកន្លែងលើកបាយ ពីផ្ទះបាយហ្នឹង ទៅកន្លែងខ្ទមហូបបាយ កន្លែងលើកបាយ។

**ស៖** ហើយចុះកន្លែងហូបបាយនោះ មានជាផ្ទះ ជាថ្ម ឬអីទេ? មានជញ្ជាំងថ្មីមានអីទេ?

**ឆ៖** កន្លែងហូបបាយគឺជាខ្ទមស្លឹក។ ខ្ទមស្លឹកដូចរោង ហើយធ្វើប្រក់ពីលើទៅ ហើយមានតុហ្នឹង គឺធ្វើអំពីឈើដែលគេកាប់កូនឈើៗប៉ុនកដៃវែងៗហ្នឹង គឺធ្វើជាតុ។ អត់មានផ្ទះថ្ម អត់មានជញ្ជាំងថ្ម មានជញ្ជាំង សូម្បីតែជញ្ជាំងក៏អត់ដែរ វាលទាំងអស់។

**ស៖** សូមអរគុណលោកស្រី។ ឥឡូវនេះ ត្រឡប់មកនិយាយអំពីការជួបគ្នាជាមួយនឹងលោក ខៀវ សំផន។ នៅពេលដែលលោកស្រីជួបហ្នឹង ជួបគ្នាយ៉ាងម៉េច តើមានការញ៉ែគ្នា ឬក៏មានការណែនាំ គ្នាឲ្យស្គាល់ទេ មានការថែចូវអី និយាយលេបខាយដាក់គ្នាអីទេ?

[១៤:០២:៥៥]

**ឆ៖** ពេលនោះ ក៏មិនទាន់ស្គាល់គ្នាភ្លាមដែរ។ ខ្ញុំក៏អត់ដឹងថា ខាងគាត់មានបំណង ឬក៏ចង់បាន ស្នើខ្ញុំអី ក៏នៅទេ អត់ទាន់ទេ។ ប៉ុន្តែពេលប្រហែលជា៣ ឬ៤ខែក្រោយ អ៊ំ យឹម ដែលគាត់នេះ អ៊ំ យឹម ហ្នឹង គឺគាត់មកស្នើខ្ញុំ។ ឯខាងគាត់ ខ្ញុំអត់ដឹងទេ។ អ៊ំយឹម មកស្នើខ្ញុំថា "មិត្តហែម ចង់ស្នើមិត្តដើម្បីរៀប ការ។ តើមិត្តយល់យ៉ាងម៉េចដែរ?" ពេលនោះ ខ្ញុំក៏អត់ៗមាននេះអីទេ ខ្ញុំគ្រាន់តែថា "ខ្ញុំទើបតែមកអ៊ំ ហើយខ្ញុំមិនដឹងគិតយ៉ាងម៉េចទេ។ ខ្ញុំសូមគិតសិនទៅអី អ៊ំ"។ ព្រោះខ្ញុំធ្លាប់និយាយជាមួយគាត់អ៊ីចឹងដែរ។ ហើយខ្ញុំថា "ខ្ញុំសូមគិតមួយរយៈទៅអ៊ីចឹង"។ យូរដែលខ្ញុំបាននិយាយ ខ្ញុំអង្គុយមួយសន្ទុះហើយ បានខ្ញុំ និយាយ។ ខ្ញុំថា "ខ្ញុំសូមគិតមួយរយៈសិន" ហើយមួយរយៈហ្នឹងក៏វែងដែរ ប្រហែលជាជិត១ឆ្នាំ ឬក៏កន្លះ ឆ្នាំអីតាមមើល។ បានគាត់មកសួរខ្ញុំម្តងទៀត។ ឯការស្គាល់តាមរយៈហ្នឹង គឺគាត់ក៏នៅហ្នឹង ហើយទៅ មក កន្លែងហ្នឹង មានកន្លែងដូតទឹក ឆ្លងទៅឆ្លងមក ប៉ុន្តែអត់មានថែចូវមានអីទេ។ គ្រាន់តែថា "ម៉េច!

ហើយមិត្ត! បានអីដាំបាយ បានអីធ្វើសម្ល? អ៊ីចឹងទៅ ធ្វើនេះ បងធ្វើនេះ អ៊ីចឹងធ្វើនោះអ៊ីចឹងទៅ។ ស្ករអី កក្ករ ប្រហើរ"។

[១៤:០៤:៥៣]

ពេលគាត់ទំនេរ គាត់ដើរមកផ្ទះបាយអ៊ីចឹង។ គាត់ថា "មើល! មានអីឲ្យខ្ញុំជួយអត់។ ខ្ញុំអត់មានធ្វើអីទេ។ មក! យកមក!" ហើយពេលខ្លះខ្ញុំមានសណ្ដែក មានអីអ៊ីចឹងដែលយើងបណ្ដុះនឹងផ្ទះហ្នឹង នៅកន្លែងហ្នឹង យកឲ្យគាត់រើសអ៊ីចឹង។ គាត់ក៏អង្គុយរើសនៅតុ តុឈើ ដែលយើងធ្វើនេះហ្នឹង អង្គុយរើសរួចហើយ គាត់ៗពេលខ្លះហើយ ពេលខ្លះមិនហើយ គាត់ត្រឡប់ទៅវិញ។ គាត់មានខ្លះ គាត់ទៅវិញទៅប៉ុណ្ណឹង។

ហើយតាំងពីគាត់ស្នើហ្នឹងមក ខ្ញុំក៏ចាប់ផ្ដើម គេហៅថាត្រួតពិនិត្យ ថាចុះមនុស្សហ្នឹងយ៉ាងម៉េចព្រោះខ្ញុំមិនស្គាល់ដែរ ហើយគាត់ហ្នឹងយ៉ាងម៉េច? គាត់ចាស់ហើយ។ ហើយគេប្រាប់ខ្ញុំ គាត់ប្រាប់ខ្ញុំដែរ គាត់ថាគាត់ជាកំលោះចាស់ ហើយជាបញ្ញាជន ហើយក៏មិនទាន់ថាស្គាល់ថាលោក ខៀវ សំផន ទេ អត់ទេ។ គាត់ជាបញ្ញាជនចាស់ ហើយគាត់ដូចជាពន្យល់ខ្ញុំ: គាត់ថាគាត់ដូចជាស្លូតបូត គាត់មិនមាន ដូចមិនមានអីទេ គាត់អត់កាច អត់អីទេ មិត្តមើលខ្លួនឯងទៅ។ អ៊ំ យ៉ឹម ក៏គាត់និយាយអ៊ីចឹង។

[១៤:០៥:៥៨]

ចាប់ផ្ដើមពេលហ្នឹង ក៏ខ្ញុំក៏ពិនិត្យ ហើយការទាក់ទងមានតែប៉ុណ្ណឹងទេ មានតែទៅមកគាត់ ឆ្លងកាត់ងូតទឹក គាត់ឆ្លងកាត់មកលេង។ ឧទាហរណ៍ថា ជួយរើសបន្លែ ជួនកាលមានបកខ្ទឹមៗអ៊ីចឹងទៅ។ មានធ្វើអីនេះ គាត់ចេះតែមកអង្គុយលេងទៅ។ ពេលគាត់ទំនេរ ហើយក៏ពិនិត្យតាមអ៊ីចឹង។ បានជួបគ្នាអ៊ីចឹង។

ដល់ក្រោយមក ប្រហែលជាកន្លះឆ្នាំ ឬក៏មិនដល់ ខ្ញុំមិនចាំ។ មាន អ៊ំយ៉ឹម ក៏គាត់មកសួរម្ដងទៀត។ មកសួរម្ដងទៀតថា "ម៉េច? មិត្តហែម ឲ្យសួរម្ដងទៀតហើយ ថាមិត្តម៉េចដែរ? អាហ្នឹងស្រេចតែខ្លួនឯងទេ មិត្តព្រមក៏ព្រម មិត្តមិនព្រមហ្នឹង អាហ្នឹងរឿងខ្លួនយើងតើ"។ ថាអ៊ីចេះ។ ហើយខ្ញុំពេលហ្នឹងនឹងឃើញថា អើម្យ៉ាងយើងតស៊ូចូលមកក៏លះបង់អីអ្វីដែលទាំងអស់ហើយ។ ហើយឃើញថាគាត់ហ្នឹងក៏ត្រឹមត្រូវ ខ្ញុំក៏សម្រេចចិត្តៗថារៀបការហ្នឹង។ ដល់ប្រហែលប៉ុន្មាននេះក្រោយ ក៏គេរៀបការឲ្យ។

**ស៖** បន្ទាប់ពីលោកស្រីបានព្រមព្រៀងហើយនោះ ប៉ុន្មានខែដែរបានអាចរៀបការបាននោះ?

[១៤:០៧:៤០]

**ឆ៖** ពេលនោះប្រហែលជា១ខែ ឬក៏ប៉ុន្មាន ១ខែអីជាង ឬក៏២ខែអីប៉ុណ្ណឹងទេ។ រៀបចំ រៀបការឲ្យ។

**ស៖** ហើយអ្នកណាជាអ្នករៀបការឲ្យលោកស្រី? មានពិធីអី រៀបការអីត្រឹមត្រូវទេ?

**ឆ៖** ពិធីមិនមានអីធំដុំទេ គ្រាន់តែមានអ្នកនៅក្នុងកន្លែងហ្នឹងជាអ្នកធ្វើពិធីការ ហើយក៏មិនមានភ្លេងមានភ្ញាត់ មិនមានលោកអីសូត្រមន្តអីទេ ពីព្រោះអីក្នុងព្រៃ ហើយម្យ៉ាងទៀតក៏លាក់ការណ៍។ អាហ្នឹងតាមការប្រាប់ខាងផ្នែកអ្នកដឹកនាំហ្នឹង ដូចថាដូច្នេះយើងការៗតាមរបៀបងាយៗទៅ ឲ្យតែទទួលស្គាល់គ្នាជាប្ដីជាប្រពន្ធ រស់នៅសុខសាន្ត សាមគ្គីគ្នាទៅធ្វើការទៅ យើងការប៉ុណ្ណឹង។ យើងខ្ញុំ -- ខ្ញុំក៏ឯកភាព អត់មានទំនាស់អីទេ ពីព្រោះថាសម្រេចថាលះបង់តស៊ូមកប៉ុណ្ណឹង ក៏សុខចិត្តការតាមអ៊ីចឹង។ ហើយកម្មវិធីគឺមានតែ -- កាលនុំងមានទ្រមួយ ហើយនិងមានម្ហូបម្ហាជា -- គេធ្វើជាសម្ពាយធម្មតា។ ធ្វើពិធីតែ១ថ្ងៃ។

[១៤:០៩:៣៣]

**ស៖** សូមអភ័យទោស។ អម្បាញ់មិញនេះ ខ្ញុំស្ដាប់ការបកប្រែអត់ទាន់ចប់។ ក្នុងពេលដែលរៀបការនុំង លោកដឹងច្បាស់ទេថា គាត់ហ្នឹងគឺឈ្មោះ ខៀវ សំផន?

**ឆ៖** ក្នុងពេលរៀបការហ្នឹង គឺអត់ៗទាន់ដឹងទេចាស។ អត់ៗដឹងផង អត់ដឹងថាលោក ខៀវ សំផន ទេ គ្រាន់ដឹងថាបញ្ញាជន ប៉ុន្តែមិនដឹងបញ្ញាជនហ្នឹងជាឈ្មោះអ៊ីចឹង។ កាលនុំងគេនៅឈ្មោះ អត់ប្រាប់ គេអត់ប្រាប់ថា ខៀវ សំផន អត់ប្រាប់ថាអីផង។

**ស៖** តើលោកស្រីដឹងថាគាត់ជាបញ្ញាជនហ្នឹងដូចម្ដេចបានដឹងបាន គេប្រាប់លោកស្រី ឬក៏យ៉ាងម៉េច? ឬក៏លោកស្រីគ្រាន់តែសង្កេតឃើញថា ប្រហែលជាគាត់ជាបញ្ញាជន ឬក៏មានព័ត៌មានច្បាស់លាស់ជាក់លាក់ថាគាត់ជាបញ្ញាជនអ៊ីចឹងតែម្ដង?

**ឆ៖** អ៊ំយឹម គាត់ប្រាប់។ មុននឹងគាត់ទៅស្នើស្ដីខ្ញុំ គឺគាត់ប្រាប់ថា គាត់ជាបញ្ញាជនចាស់ ហើយកំលោះចាស់ គាត់អត់ទាន់មានប្រពន្ធទេ គាត់អត់យកប្រពន្ធទេ ហើយគាត់បានរត់មកចូលតស៊ូជាមួយនៅក្នុងព្រៃហ្នឹង អត់មានប្រពន្ធទេ។ ថាអ៊ីចឹង។ គាត់នៅស្អាតស្អំទេ គាត់ប្រាប់តែប៉ុណ្ណឹង។

[១៤:១១:២៤]

**ស៖** នៅពេលនោះ នោះគេផ្ដល់ព័ត៌មានដល់លោកស្រីអំពីសមមិត្ត ហែម នៅក្នុងចលនាដែរឬទេ? ក្នុងចលនាដែលលោកស្រីបានចូលរួមហ្នឹងគេមានបានប្រាប់ថា សមមិត្ត ហែម ហ្នឹងគាត់ធ្វើអីទេ?

**ផ៖** ពេលនោះអត់ៗទាន់មានអ្នកណាប្រាប់ទេ។

**ស៖** តើលោកអាច -- លោកស្រីអាចកំណត់អំពីពេលវេលាច្បាស់លាស់នៃការរៀបអាពាហ៍ពិពាហ៍របស់លោកស្រីទេ តើនៅថ្ងៃណា? ខែណា? ឆ្នាំណាដែរ?

**ផ៖** អាហ្នឹងខ្ញុំប្រហែល ព្រោះអីវាមិនជាច្បាស់អីប៉ុន្មានទេ ព្រោះអីអង្គាល់ហ្នឹងវា ខ្ញុំមិនបាននេះ ប៉ុន្តែប្រហែលជាថ្ងៃ គឺប្រហែលរវាងចុងខែ ចុងឆ្នាំ៧២ ដើម៧៣ គឺដូចជាថ្ងៃម្ភៃជាង ម្ភៃអាច ២៥ -- ២៤-២៥។ តាមខ្ញុំចាំចាស ប្រហែលប៉ុណ្ណឹង។ ២៥ - ៧២។

[១៤:១៣:០៧]

**ស៖** ហើយថាចុង៧២ ហ្នឹងប្រហែលជាខែណាដែរលោកស្រី?

**ផ៖** ខែ១២ៗ។

**ស៖** ចាប់ពីពេលរៀបការហើយ តើលោកស្រីរួមរស់នៅជាមួយគ្នាតែម្តង ឬក៏យ៉ាងម៉េច? មានន័យថា គឺរស់នៅក្នុងផ្ទះតែមួយជាមួយលោក ខៀវ សំផន តែម្តង ឬក៏អត់ទេ?

**ផ៖** តាំងពីការហើយក៏រស់នៅជាមួយគ្នារហូតនៅក្នុងផ្ទះតែមួយ។ តាំងពីរៀបការហើយ គឺរស់នៅជាមួយគ្នារហូតនៅក្នុងផ្ទះតែមួយ។

**ស៖** តើលោកស្រីអាចពិពណ៌នាអំពីជីវភាពរស់នៅរបស់លោកស្រីចាប់តាំងពីពេលរៀបការហ្នឹងបានទេ គឺថាលោកស្រីនៅតែនៅក្នុងព្រៃដដែល។ ដូច្នេះតើជីវភាព ឬក៏ផាសុកភាពរស់នៅហ្នឹងយ៉ាងម៉េចដែរ? សូមលោកស្រីពិពណ៌នាជូនតុលាការ។

[១៤:១៤:៣៦]

**ផ៖** តាំងពីការរហូតមកដល់រស់នៅជាមួយគ្នារហូតប្រហែលជាបាន១ខែ ឬយើងត្រូវផ្លាស់ប្តូរកន្លែងរហូត ពីកន្លែងមួយទៅកន្លែងមួយ ពីព្រោះអីអត់មាននៅមួយកន្លែងទេ ខ្លាចក្រែងមានបែកការណ៍ យន្តហោះទម្លាក់។ ដល់អ៊ីចឹង យើងមិនសូវបាននៅមួយកន្លែងទេ។ ពេលខ្លះមានខ្ទមនៅ ពេលខ្លះមានចងជាអង្រឹង ហើយវេចបាយខ្ចប់បាយដើររហូត។ អត់មានសូវនៅកន្លែងទេ។ ហើយនៅមិនដែលនឹងទេ។ ជីវិតនៅក្នុងព្រៃលំបាក លំបាកច្រើនដែរ គ្មានផ្ទះ គ្មានសម្បែងទេ។

**ស៖** ចាប់ពីពេលដែលលោកស្រីរៀបការជាមួយលោក ខៀវ សំផន ហើយ តើគេមានផ្លាស់ប្តូរការងាររបស់លោកស្រីទេ ឬក៏លោកស្រីនៅតែមានភារកិច្ចធ្វើការនៅចង្ក្រានបាយ ផ្ទះបាយដដែល?

**ប្រធានអង្គជំនុំ៖**

ឆ្លើយ! លោកស្រីឆ្លើយ! អម្បាញ់មិញឆ្លើយ លោកស្រី ក្បាលមីក្រូហ្វូនមិនទាន់ប្រតិបត្តិការ។

**លោកស្រី ស្វ សុជាតិ៖**

**ឆ៖** លោកប្រធាន សួរថាម៉េចអំមិញ?

**សួរដោយលោក អាកឡូរ វែកគែន៖**

**ស៖** អម្បាញ់មិញនេះ ខ្ញុំសួរថាចាប់ពីពេលដែលលោកស្រីរៀបការជាមួយលោក ខៀវ សំផន ហើយតើគេមានផ្លាស់ប្តូរការងាររបស់លោកស្រីទេ ឬក៏លោកស្រីនៅតែធ្វើការនៅផ្ទះបាយដដែល?

**ឆ៖** ចាប់ពីការហើយ ខ្ញុំនៅតែធ្វើតែផ្ទះបាយដដែល។

**ស៖** ចាប់ពីពេលរៀបការហើយ តើលោកស្រីជួបលោកខៀវ សំផន ញឹកញាប់ទេ ហើយលោកស្រីអាចរៀបរាប់បានទេ អំពីសកម្មភាពដែលលោកស្រីបានឃើញនោះ?

[១៤:១៧:៥០]

**ឆ៖** ការហើយ ខ្ញុំនៅជាមួយរហូត អត់មានបែកគ្នាទេ។ គ្រាន់តែផ្លាស់កន្លែងទៅមកៗ។ ឯសកម្មភាពការងាររបស់គាត់ ខ្ញុំឃើញតែគាត់នៅផ្ទះមានតុឬស្សីហ្នឹង ពេលខ្លះគាត់សរសេរ ពេលខ្លះអត់ ក៏ខ្ញុំមិនដឹងថាធ្វើអីខ្លះ ក៏ខ្ញុំអត់ដឹងដែរ។

**ស៖** អម្បាញ់មិញនេះលោកស្រីបានឆ្លើយថា លោកស្រីមិនដឹងអំពីឈ្មោះពិតរបស់លោក ខៀវ សំផន ភ្លាមទេ។ អ៊ីចឹងតើលោកស្រីអាចប្រាប់បានទេថានៅពេលណាលោកស្រីដឹងឈ្មោះរបស់គាត់ពិតប្រាកដនោះ? ហើយដឹងដោយរបៀបណា?

**ឆ៖** កន្លងប្រហែលជាប៉ុន្មានខែក្រោយ គេឱ្យមកទទួលដូចជាមានសម្តេច សីហនុ លោកយាងមកស្រុក ប្រហែលជា៧៣ ប្រហែលប៉ុន្មានខ្ញុំអត់ដឹងទេ។ ហើយកាលនោះខ្ញុំទៅដែរ។ ហើយខ្ញុំទៅក្នុងឋានៈអ្នកបម្រើ។ អ្នកបម្រើសម្តេចហ្នឹង។ ដល់ពេលហ្នឹងទើបដឹង។ ដល់ទៅជួបនេះហើយបានដឹង។ ដឹងអ៊ីចឹងទៅពួកអ្នកដែលទៅនេះ គេចំអន់លេងអ៊ីចឹង។ ចុម! អត់ដឹងអីអ៊ីចឹងអ្វី? ចាស ខ្ញុំអត់ដឹងមែនហ្នឹងណ៎ា។ រួចទៅ អ៊ីចឹងទៅបានដឹងពីពេលហ្នឹងមក។

[១៤:១៩:៥៧]

**ស៖** ចុះពីមុនមកលោកស្រីធ្លាប់ឮឈ្មោះ ខៀវ សំផន អីទេ ឬក៏លោកស្រីមិនដែលស្គាល់ឈ្មោះនេះទាល់តែសោះ?

**ឆ៖** អត់ដែលឮឈ្មោះផង។

**ស៖** តើលោកស្រីអាចរៀបរាប់អំពីចរិតរបស់លោក ខៀវ សំផន ដែលលោកស្រីបានកត់សម្គាល់ឃើញនៅក្នុងអំឡុងពេលរៀបការហើយដំបូងៗតើគាត់មានគុណវិបត្តិ ឬក៏គុណសម្បត្តិអ្វីខ្លះ?

**ឆ៖** ក្រោយពីរៀបការហើយខ្ញុំឃើញជាគុណសម្បត្តិ គឺថាគាត់ជាមនុស្សអត់ធ្មត់ បើជាមនុស្សគឺសុភាពរាបសាមិនដែលមានអីទំនាស់នៅក្នុងកន្លែង ស្លូតបូត ហើយធ្វើអីក៏ធ្វើតែខ្លួនឯង។ មិនមានឃើញស្អីក្រៅពីចរិតទន់ភ្លន់របស់គាត់ទេ ហើយចំពោះខ្ញុំក៏អ៊ីចឹងដែរ។ តាំងពីខ្ញុំការហើយរហូតមកដល់សព្វថ្ងៃនេះក៏មិនមានអីទំនាស់ជាផ្លូវចិត្ត ដែលថាគាត់ជេរស្តីឬមួយក៏ ទោះបីលំបាកស្រួលយ៉ាងម៉េចក៏ដោយមានតែគាត់ជួយ។ ជួយនៅពេលលំបាកនៅពេលដែលជាពិសេសគឺកូន មានកូនបង។ ពេលនោះគាត់នៅលំបាកខ្លាំងណាស់។ ហើយសម្រាលហើយក៏មិនមានអ្នកណាជួយគឺធ្វើដោយខ្លួនឯងទាំងអស់។ ក្រោយមកបានគាត់ដូចត្រឡប់ពីស្រុកចិនមកវិញ គាត់នៅជួយកូនខ្ញុំបានប្រហែលបានជិត១ខែ ហើយគាត់មកគាត់អត់ទៅណា គាត់នៅជួយខ្ញុំរហូត។ ខ្ញុំឃើញអត្តចរិត ខ្ញុំឃើញឬកពារអត់មិនមែនជាអ្នកធំអ្នកនេះទេ គឺធ្វើទាំងអស់តាំងពីគក់កន្ទបតាំងពីស្អី គឺជួយខ្ញុំសព្វគ្រប់ អត់ឲ្យខ្ញុំចុះអូរ ព្រោះកន្លែងហ្នឹងវាចុះអូរជ្រៅ។

[១៤:២៣:១១]

**ស៖** តើកូនដំបូងរបស់លោកស្រីហ្នឹងកើតនៅពេលណាដែរ?

**ឆ៖** កូនខ្ញុំកើតនៅថ្ងៃ០៤ ខែ៥ ១៩៧៤។

**ស៖** អម្បាញ់មិញនេះលោកស្រីបានរៀបរាប់អំពីអត្តចរិតរបស់លោក ខៀវ សំផន គឺថានៅពេលធ្វើការនោះគាត់មិនដែលឈ្លោះប្រកែកជាមួយអ្នកណាទេ ហើយគាត់ធ្វើអីគឺដោយខ្លួនឯងទាំងអស់។ អ៊ីចឹងតើលោកស្រីដឹងទេ តើការងារគាត់ធ្វើអ្វីខ្លះនៅពេលនោះ?

**ឆ៖** នៅពេលនោះខ្ញុំមិនដឹងគាត់ធ្វើអីទេ ប៉ុន្តែគាត់តែងតែអង្គុយសរសេរ។

**ស៖** តើលោកស្រីធ្លាប់ឃើញគាត់ប្រជុំគ្នាជាមួយអ្នកផ្សេងទៀតញឹកញាប់ដែរឬទេ?

**ឆ៖** ក្នុងអំឡុងប៉ុន្មាននេះដូចអត់ឃើញមានប្រជុំអីផង។ មានតែកន្លែងអ្នកធ្វើការ អ្នកដឹកនាំ ធ្វើការដូចជាបង្រៀនខាងផ្នែកមូលដ្ឋានដែលមកពីមូលដ្ឋានមកច្រើនៗ គេមករៀន ប៉ុន្តែគាត់ខ្ញុំឃើញនៅផ្ទះគាត់អត់ឃើញគាត់ទៅផង។

[១៤:២៥:៣៤]

**សៈ** លោកស្រីបានឆ្លើយផងដែរថា ក្រោយពីសម្រាកកូនទី១នោះលោក ខៀវ សំផន នៅជិតលោក នៅគាំទ្រលោកស្រី។ តើចំពោះប្រជាជនទូទៅ ចំពោះបុរសទូទៅហ្នឹងតើសកម្មបែបហ្នឹង អំពើបែបហ្នឹងដែលថានៅជិតប្រពន្ធ មើលថែទាំកូនដែលទើបតែកូនខ្ចីអ៊ីចឹង វាជារឿងធម្មតាទេនៅពេលនុ៎ង?

**ផៈ** នៅពេលនោះតាមខ្ញុំដឹងគឺថា បុរសខ្មែរគឺពេលធ្វើអ៊ីចឹងគឺសំខាន់ណាស់ ពីព្រោះគេកម្រទៅធ្វើអ៊ីចឹងទេ ដែលតាមខ្ញុំដឹង។ ឯអ្នកផ្សេងឯទៀតក៏អាចមានអ៊ីចឹងដែរតាមមើល ពីព្រោះនៅពេលហ្នឹងវាពិបាក ប៉ុន្តែជាទូទៅកម្រទៅធ្វើអ៊ីចឹងណាស់។ ដូច្នេះខ្ញុំឃើញថាចំណុចសំខាន់ដែលគាត់ជាមនុស្សល្អគួរឲ្យខ្ញុំគោរព គួរឲ្យខ្ញុំស្រឡាញ់ គឺមកពីអ៊ីចឹង។

**សៈ** តើលោកស្រីបន្តរស់នៅក្នុងព្រៃនុ៎ងរហូតទៅដល់ពេលណាដែរ? ហើយការរបៀបដែលរស់នៅក្នុងព្រៃហ្នឹង គឺថានៅបន្តយូរទៀតទេក្រោយពីលោកស្រីសម្រាលទី១រួចហើយនោះ? សូមលោកបញ្ជាក់អំពីរយៈពេលដែលលោកស្រីរស់នៅក្នុងព្រៃ ដូចដែលលោកស្រីបានរៀបរាប់អម្បាញ់មិញនេះ?

[១៤:២៧:៣៧]

**ផៈ** តាំងពីហ្នឹងរស់នៅក្នុងព្រៃរហូត អត់មានទាន់ចេញទៅខ្លួងទេ រហូតរំដោះភ្នំពេញ នៅតែក្នុងព្រៃទេ។

**សៈ** នៅពេលរំដោះភ្នំពេញនោះ តើលោកអាចស្រីអាចបញ្ជាក់ទេថា លោកស្រីនៅកន្លែងណាដែរពេលនុ៎ង?

**ផៈ** ពេលមុនរំដោះភ្នំពេញ គឺពួកខ្ញុំមកសម្រាលនៅក-១៧ ហើយបានប៉ុន្មានគាត់នៅជាមួយរួចទៅ ទៅប-២០។ ទៅប-២០ហើយ បានប៉ុន្មានខែទេ ដូចជាទៅគេហៅថា មន្ទីរមាយ។ អាហ្នឹងជាមន្ទីរថ្មី ខ្ញុំក៏មិនដឹងនៅកន្លែងណាដែរ។ ហ្នឹងទៅទាំងអស់គ្នា ទាំងកូនខ្ចី ទាំងខ្ញុំកូនខ្ចីអីក៏ទៅទាំងអស់គ្នា។

**សៈ** នៅពេលរំដោះទីក្រុងភ្នំពេញថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ តើលោក ខៀវ សំផន នៅក្បែរនៅជាប់នឹងលោកស្រីដែរឬទេ?

[១៤:២៩:២៥]

**ផៈ** ប្រហែលជាមុនរំដោះ គាត់បានទៅមុនខ្ញុំប្រហែលជា១០ថ្ងៃ ឬកន្លះខែ។ ចេញពី គាត់ចេញពីមាយ គាត់ថាជិតរំដោះហើយ "ខ្ញុំទៅមុន" ថាអ៊ីចឹង។ ហើយទៅកន្លែងណាខ្ញុំអត់ដឹងទេ។ ហើយខ្ញុំត្រឡប់មកប-១៧វិញ ហើយពីរនាក់កូន។ ហើយរំដោះភ្នំពេញបាន១អាទិត្យ ខ្ញុំបានចេញដំណើរពី ១៧ ទៅ និងកូនទៅដល់ស្ពី គេហៅ "ស្តុកគោល"។ ស្តុកគោល ទៅដល់ពេលយប់។ នៅពេលយប់ ហើយ

ជួបគាត់នៅកន្លែងហ្នឹង ជួបនៅកន្លែងស្តុកគោលហ្នឹង មួយយប់ហ្នឹង។ ដល់ព្រលឹមឡើង ហើយគាត់ចេញមកមុនខ្ញុំពេលព្រឹក។ ហើយខ្ញុំត្រូវយកកូនទៅផ្ញើជាមួយប្រពន្ធលោក សួរ ហុង នេះ គឺគាត់ឈ្មោះឈឿង នៅស្តុកគោល។ ព្រលឹមឡើង ខ្ញុំយកកូនទៅផ្ញើនឹងគេហើយ បានខ្ញុំចេញដំណើរ។ ប្រហែលជាថ្ងៃបន្តិចបានខ្ញុំចេញ។ ខ្ញុំទៅតាមក្រោយ។ ទៅៗនៅកន្លែងគេហៅថា រ៉ាវទេះភ្លើង គេឲ្យខ្ញុំទៅដាំបាយ។ ពេលនោះ អ្នកទាំងអស់កូនខ្ចី មានតែខ្ញុំកូនបាន១ឆ្នាំ។ ១ឆ្នាំជាង ជិត១ឆ្នាំ។ ហើយកូនខ្ញុំមិនទាន់លែងបៅផង ហើយខ្ញុំយកទៅផ្ញើគេ។ ខ្ញុំក៏សុខចិត្តទៅ ទៅនៅស្ថានីយរថភ្លើង។

[១៤:៣១:៥០]

**ស៖** បាទ អ្នកស្រីទើបតែនិយាយថា អ្នកស្រីបានទៅដល់រ៉ាវទេះភ្លើង។ ហើយខ្ញុំចង់ដឹងថា តើស្ថានីយរថភ្លើងហ្នឹងនៅស្រុកណាដែរ?

**ឆ៖** ស្ថានីយរថភ្លើងហ្នឹង គឺខ្ញុំអត់ចាំទេពេលហ្នឹង។ ទៅវាមានផ្ទះមួយធំ របៀបដូចរង្វង់អ៊ីចឹង។ ហើយខ្ញុំអត់ដឹងថា នៅកន្លែងណាទេ ព្រោះភ្នំពេញខ្ញុំអត់ស្គាល់។ ហើយទៅ ខ្ញុំនៅខាងក្រោមហ្នឹង ធ្វើបាយដាំបាយ។ តែមានគេដាំ មានស្រីៗ បួនប្រាំ បួនដប់នាក់នៅកន្លែងហ្នឹង ដែលដាំមុនខ្ញុំ។ ហើយខ្ញុំទៅ ខ្ញុំជួយថែម ដល់ពេលនេះ ខាងគេគ្រាន់តែជួយបេះបន្លែបេះអីទៅ ខ្ញុំអ្នកស្ងួរអ្នកអ៊ីចឹង។

**ស៖** បន្ទាប់ពីបានជួបលោក ខៀវ សំផន ១យប់នៅស្តុកគោលនោះ។ តើលោកបានទៅណាទៀត?

**ឆ៖** ជួប១យប់ហ្នឹង ហើយព្រលឹមឡើង គាត់ចេញដំណើរមកភ្នំពេញមុនខ្ញុំ។ គាត់ចេញពេលព្រលឹម ហើយខ្ញុំយកកូនទៅផ្ញើប្រពន្ធលោក សួរ ហុង នៅកន្លែងហ្នឹងដែរ កន្លែងស្តុកគោលហ្នឹងដែរ។ យកទៅផ្ញើគេហើយបានខ្ញុំចេញដំណើរទៅដែរ ប៉ុន្តែចេញផ្សេងគ្នា។ គាត់ចេញទៅមុន ហើយខ្ញុំទៅតាមក្រោយ ប្រហែលជាម៉ោងប្រាំបី ប្រាំបួនថ្ងៃដែរហើយ ខ្ញុំចេញ។ ខ្ញុំចេញមកភ្នំពេញដែរ មកដល់ស្ថានីយរថភ្លើងហ្នឹង។

[១៤:៣៤:០៧]

**ស៖** អ្នកស្រីនិយាយអម្បាញ់មិញថា អង្កាល់សម័យនោះអ្នកស្រីមិនដឹងថា ស្ថានីយរថភ្លើងនោះនៅទីណានោះទេ? ប៉ុន្តែសព្វថ្ងៃនេះ អ្នកស្រីដឹងថាស្ថានីយរថភ្លើងនេះនៅស្រុកណា? ឬនៅក្នុងទីក្រុងណាទេ?

**ឆ៖** ខ្ញុំដឹងថា នៅភ្នំពេញ តែមិនដឹងនៅក្នុងស្រុក ខេត្តណាផង។ ឥឡូវហ្នឹង ក៏នៅតែអត់ដឹងថា

តើភ្នំពេញនៅម្តុំក្នុងស្រុកណា? ដឹងថានៅភ្នំពេញ។ មិនបានចាប់អារម្មណ៍ថានៅកន្លែងស្រុកណា ភូមិណា អត់បាន--។

**ស៖** បាទ សូមអរគុណ។ អ៊ីចឹងលោកស្រីបាននិយាយថា លោកស្រីបានបន្តធ្វើជាចុងភៅនៅស្ថានីយរថភ្លើងនៅក្នុង នៅទីក្រុងភ្នំពេញ។ តើនៅទីនុំង លោកស្រីបានជួបលោក ខៀវ សំផន ទៀតទេ?

**ឆ៖** នៅទីនោះ អត់បានជួបទេ។

**ស៖** តើអ៊ីចឹងលោកស្រីបានជួបគាត់ហ្នឹងនៅពេលណាដែរ?

**ឆ៖** ចេញពីរ៉ារទេះភ្លើង យើងទៅក-២។ ហ្នឹងខ្ញុំទៅជួបគាត់នៅក-២។

**ស៖** បាទ ក-២ ហ្នឹងជាអ្វី?

**ឆ៖** ក-២ ជាកន្លែងអី កាលណោះខ្ញុំក៏អត់ដឹងដែរ ប៉ុន្តែទៅសម្រាកនៅកន្លែងហ្នឹងប្រហែលជាប៉ុន្មានថ្ងៃទេ ដូចជាតិចដែរ។ មិនដឹងជាកន្លែងស្អី ខ្ញុំក៏ដឹងដែរ ប៉ុន្តែទៅសម្រាកទេ អត់មានធ្វើអីទេ។

[១៤:៣៦:៣៧]

**ស៖** តើអ្នកស្រីស្ថិតនៅស្ថានីយរថភ្លើងហ្នឹងប៉ុន្មានថ្ងៃ ហើយបានចេញទៅក-២? ប្រហែលរយៈពេលហ្នឹងប៉ុន្មានថ្ងៃដែរ មុននឹងចេញទៅក-២?

**ឆ៖** មុនចេញទៅក-២ ខ្ញុំមិនចាំ ប្រហែលជា១អាទិត្យ ឬក៏ប្រហែលប៉ុណ្ណឹង។ ឬក៏លើសហ្នឹង ក៏ខ្ញុំអត់ៗចាំដែរ ឬក៏លើសហ្នឹង ក៏ខ្ញុំអត់ៗចាំដែរ។

**ស៖** លោកស្រីនិយាយថា នៅអ្នកស្រីសម្រាកនៅក-២ ហើយបានជួបលោក ខៀវ សំផន ហើយតើពេលក្រោយមកទៀតហ្នឹង លោកស្រីបានធ្វើអីដែរ?

**ឆ៖** ក្រោយមក គឺមកនៅព្រះវិហារព្រះកែវៗ ខ្ញុំដាំបាយ។

**ស៖** អ៊ីចឹងបានន័យថា នៅព្រះវិហារព្រះកែវមរកតហ្នឹង តើលោកស្រីបានបន្តការងារជាចុងភៅដដែលអ៊ីចឹងមែនទេ?

**ឆ៖** ចាស។

[១៤:៣៨:១០]

**ស៖** តើចាប់ពីពេលដែលអ្នកស្រីបានជួបលោក ខៀវ សំផន ឡើងវិញ លោកបាន -- លោកស្រីបានរួមរស់នៅជាមួយគ្នាឡើងវិញជាធម្មតាអ៊ីចឹងមែនទេ?

**ឆ៖** ពេលនោះ អត់ -- នៅព្រះវិហារព្រះកែវក៏មិនបាននៅជាមួយគ្នាទេ។ ខ្ញុំនៅផ្នែកផ្ទះបាយ

ណោះ ហើយកន្លែងវាចង្អៀត ហើយនៅដើម្បីស្ងាត់ អត់មានអ្នកណាចេញចូលអីទៅមកបានទេ។ ដូច្នេះ ខ្ញុំនៅផ្ទះបាយ ខ្ញុំអត់មានបានទៅនៅជាមួយគាត់ទេ។

**ស៖** តើអ្នកស្រីនៅធ្វើម្ហូបនៅវិមានព្រះកែវមរកតហ្នឹងរយៈពេលប៉ុន្មានដែរ? ហើយបន្ទាប់មកទៅធ្វើអីទៀត?

**ឆ៖** នៅព្រះវិហារព្រះកែវ គឺប្រហែលជាប៉ុន្មានខែខ្ញុំមិន១ចាំច្បាស់ទេ អាចពាក់កណ្ដាល៧៥ ឬក៏ចុង៧៥អី កាលហ្នឹងមើល៍ រួចមកក-១។ កន្លែងក-១ នៅមាត់ទន្លេ នៅជាប់ទន្លេបាសាក់។ មកក-១ ខ្ញុំនៅផ្ទះបាយដដែល។ ប៉ុន្តែនៅហ្នឹងក៏មានគេអ្នកដាំបាយច្រើនដែរ។

**ស៖** តើនៅក-១ នោះលោកស្រីបានរួមរស់ជាមួយលោក ខៀវ សំផន ឡើងវិញដែរឬទេ?

[១៤:៤០:១៧]

**ឆ៖** នៅក-១ ខ្ញុំទៅសម្រាកនៅកន្លែងបន្ទប់របស់គាត់ ព្រោះអីគាត់នៅម្នាក់ឯង ហើយពេលដែលគាត់ចុះមកលេង ទៅលេងកូនខ្ញុំអាបងនៅជាមួយខ្ញុំនៅកន្លែងមាត់ទន្លេបាសាក់ហ្នឹង មានផ្ទះស្បូវមួយខ្ញុំនៅហ្នឹង ខ្ទមស្បូវហ្នឹង ហើយគាត់ចេញមកគាត់ថា "ទៅសម្រាកលេងជាមួយខ្ញុំទៅខ្ញុំនៅម្នាក់ឯងទេ"។ ជាន់ -- ផ្ទះហ្នឹងដូចជាជាន់ទី៣ ឬក៏ទី២ ខ្ញុំមិនចាំច្បាស់ ហើយនៅចំហៀងខាងគេ បន្ទប់របស់គាត់។ ដូច្នេះ ខ្ញុំតែឡើងទៅនាំកូនប្រុសមួយហ្នឹងទៅសម្រាកជាមួយគាត់។

**ស៖** តើលោកស្រីអាចពិពណ៌នាអំពីការរៀបចំបន្ទប់ហ្នឹងទេ ដូចជាគ្រឿងសង្ហារឹមអីជាដើមនោះ តើមានអីខ្លះ? មានគ្រែមានអីទេ?

**ឆ៖** នៅក្នុងបន្ទប់ហ្នឹងគឺអត់មានស្អីទាំងអស់ តុក៏អត់ គ្រែក៏អត់ សូម្បីតែខ្នើយក៏អត់ដែរ គឺទទេក្រាលតែកន្ទេលហើយ កើយអាស្អីបាឡូខោអាវហ្នឹង សំពៀតខោអាវហ្នឹង។ អត់មានអីទេ នៅតុក៏អត់នៅអីក៏អត់ដែរ។ ក្រាលកន្ទេលអ៊ីចឹងទៅសម្រាកជាមួយកូនជាមួយអីអ៊ីចឹងទៅ។

[១៤:៤២:២៥]

**ស៖** បើតាមលោកស្រីដឹងនោះ ក-១ ហ្នឹងជាកន្លែងអ្វីដែរ ហើយគេ -- កន្លែងនុំងគេធ្វើអី?

**ឆ៖** បើតាមខ្ញុំដឹង ក-១ ហ្នឹងគឺកន្លែងអ្នកដឹកនាំធ្វើការធំដែរ ព្រោះអីកន្លែងហ្នឹងមានបាំងរបងដោយដែកស័ង្កសីជិត ហើយធំ គឺសម្រាប់ដឹកនាំធ្វើការ។

**ស៖** មេដឹកនាំធ្វើការនៅទីនោះ ហើយខ្ញុំចង់ដឹងថា ពួកគេរស់នៅទីនោះដែរឬទេ? បាទ ខ្ញុំចង់និយាយថាគាត់ស្នាក់នៅទីហ្នឹងតែម្ដង?

**ឆ៖** អ្នកដឹកនាំដូចជា ប៉ុល ពត, តា នួន ជា គឺនៅទីនោះ ហើយនិងអ្នកផ្សេងមួយចំនួនទៀត គាត់នៅទីនោះ។

**ស៖** បាទ អ្នកណា?

**ឆ៖** ដូចជាអ្នកមកពីមូលដ្ឋាន ខ្ញុំមិនស្គាល់ឈ្មោះទាំងអស់ទេ ពីព្រោះអីអត់មានចេញចូលទេ។ គ្រាន់តែដឹងថា កាលហ្នឹងគឺមានអ្នកមកច្រើន ពីព្រោះអីធ្វើបាយច្រើន។

**ស៖** បាទ តើលោកស្រីអាចពិពណ៌នាអំពីម្ហូបអាហារដែលអ្នកស្រីបានធ្វើ។ អ៊ីចឹងខ្ញុំចង់ដឹងថា តើម្ហូបសម្បូរបែបទេ? អ៊ីចឹងអាចរៀបរាប់អំពីរបបអាហារនៅពេលនោះបានដែរឬទេ? ពេលដែលអ្នកស្រីធ្វើម្ហូបនុ៎ង?

**ឆ៖** ពេលដែលនៅក-១ ម្ហូបអាហារ វាមិនសំបូរ មិននេះទេ។ ប៉ុន្តែសម្លប្រហើរ កកូរហើយមានម្ហូបមួយមុខ ថែមមួយមុខទៀតជាម្ហូបគោក សម្រាប់ដែលមានភ្ញៀវអ្នកដឹកនាំថាមកពីមូលពីដ្ឋានអីអ៊ីចឹង។ គេប្រើពាក្យថា សម្រាប់អ្នកចាស់ៗ។ ហើយក៏មិនមានអីសំបូរហូរហៀរនេះទេ គ្រាន់តែថាធ្វើដោយសន្សំសំចៃ ពីព្រោះគេប្រាប់ថាឲ្យធ្វើសន្សំសំចៃពីព្រោះយើងខ្វះខាត។ នេះមិនមែនជាសំបូរហូរហៀរទេ។ ម្ហូបអាហារធ្វើធម្មតា សម្លប្រហើរ កកូរ ម្ជូរគ្រឿង មិនមានអីជាប្រណីតទេ។

[១៤:៤៦:០២]

**ស៖** តើអ្នកស្រីបានទៅនៅ ក-១ហ្នឹងរយៈពេលប៉ុន្មានដែរ?

**ឆ៖** នៅ ក-១ ប្រហែលជាប៉ុន្មានខែ ខ្ញុំមិនចាំ ប៉ុន្តែក្រោយមកបានទាំងអស់គ្នាសុទ្ធតែអ្នកដឹកនាំចេញមក ក-៣។ ខ្ញុំនៅ-- ដូចគាត់អីចេញមកមុនខ្ញុំ ក្នុងរវាងខែ១ ឬក៏ចុង៧៥ ឬក៏ដើម៧៦ ព្រោះខ្ញុំមានទម្ងន់អាទី២ កូនទី២។

**ស៖** តើអ្នកស្រីនិយាយថាលោក ខៀវ សំផន បានចេញមុនលោកស្រី ហើយក្រោយមកលោកស្រីបានទៅជួបគាត់នៅ ក-៣ ឬក៏ចេញក្នុងពេលជាមួយគ្នា?

**ឆ៖** ចេញក្រោយ ព្រោះខ្ញុំសម្រាលកូនទី២ហើយ ខ្ញុំចេញមកក្រោយគាត់ប្រហែលជា២ខែ ឬ៣ខែអីប៉ុណ្ណឹងទេ។ ហើយខ្ញុំមក ក-៣ ដែរ។

**ប្រធានអង្គជំនុំ៖**

បាទអរគុណលោកមេធាវី អរគុណសាក្សី។ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក១៥នាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបីដប់ប្រាំនាទី សូមអញ្ជើញចូលវិញ

ដើម្បីបន្តកិច្ចដំណើរការសវនាការ។ មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់ផ្តល់សក្ខីកម្មនេះវិញនៅវេលាម៉ោង១៥នាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៤៨ នាទី ដល់ម៉ោង ១៥:១៣ នាទី)*

[១៥:១៥:00]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តី ខៀវ សំផន ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។ សូមអញ្ជើញ!

**សួរដោយលោក អាកទូរ វែកគែន៖**

បាទអរគុណលោកប្រធាន។

**ស៖** លោកស្រីមុននឹងត្រឡប់មកនិយាយពីរឿងរបស់អ្នកស្រីដែល-- អម្បាញ់មិញនេះ ខ្ញុំសូមសេចក្តីបំភ្លឺមួយនៅពេលដែលលោកស្រីនៅក្នុងព្រៃ តើនៅពេលដែលលោកស្រីសម្រាលកូនទី១ របស់លោកស្រីហ្នឹង លោក ខៀវ សំផន នៅជាមួយលោកស្រីទេ នៅថ្ងៃដែលលោកស្រីសម្រាលកូនហ្នឹង?

**លោកស្រី សូ សុជាតិ៖**

**ឆ៖** នៅពេលខ្ញុំសម្រាលគាត់អត់នៅទេ។ គាត់ក្រៅ គាត់ទៅចិន។ ដល់ពេលខ្ញុំសម្រាលបានជិត១ខែបានគាត់អញ្ជើញមកវិញ។

**ស៖** ហើយបន្ទាប់មកទៀតលោកស្រីបានឆ្លើយថា លោកខៀវ សំផន បានថែទាំលោកស្រី។ តើគាត់នៅថែទាំលោកស្រីហ្នឹងអស់រយៈពេលប៉ុន្មានដែរ?

**ឆ៖** តាំងពីគាត់មកពីចិនមកគាត់មកនៅជាមួយខ្ញុំរហូតមិនដឹងជាប៉ុន្មានខែទេ ប្រហែលជា បីបួនខែ ឬក៏ប៉ុន្មានទេ ព្រោះអីជិត នៅរហូតទៅដល់ពីមន្ទីរ១៧។ នៅប្រហែល៣ខែ នៅមន្ទីរ១៧ បាន

ចេញពីហ្នឹងទៅ ប-២០។ នៅប-២០ នៅជាមួយគ្នាដែរ។ ដល់ចេញពី ប-២០ បានទៅភូមិមាឃ ក៏នៅជាមួយគ្នា ទាំងខ្ញុំទាំងគាត់នៅជាមួយគ្នា។ គាត់ទៅមាឃបានតែបន្តិចទេ ដល់ជិតរំដោះភ្នំពេញ។

[១៥:១៦:៣៤]

**ស៖** ហើយអ្នកស្រីក៏បានលើកឡើងផងដែរថានៅក្នុងរយៈពេលបួនប្រាំខែហ្នឹង គាត់បានថែទាំលោកស្រី។ លោកស្រីអាចពិពណ៌នាទេថាគាត់ថែទាំលោកស្រីយ៉ាងម៉េចទៅ? សកម្មភាពគាត់មានអ្វីខ្លះ?

**ឆ៖** សកម្មភាពទី១ គឺជួយមើលកូន គក់កន្ទបអត់ឲ្យដួសទឹក អត់ឲ្យខ្ញុំចុះទឹក បាយទឹកដែលគេនេះមក ក៏ជួយយកមក គឺក្នុងមួយរយៈបីខែហ្នឹងគាត់ហាមថាមិនឲ្យដើរ ឲ្យនៅ។ បើមិនអ៊ីចឹងច្បាស់ជាឈឺចង្កេះ ឈឺជង្គង់ ចាស់ទៅហ្នឹងមិនទាន់ទេ។ ប៉ុន្តែរយៈពេលប៉ុន្មានដែលខ្ញុំសម្រាលហើយខ្ញុំធ្វើតែខ្លួនឯងមុនទៅហើយហ្នឹង ទើបបានគាត់មក។ គាត់ថាងាប់ហើយយ៉ាងនេះបើនៅតែអ៊ីចឹងឈឺងាប់ ថាអ៊ីចឹងហើយបានគាត់នៅរហូតទៅ។ ធ្វើសព្វគ្រប់ គាត់អត់ឲ្យខ្ញុំចុះទឹក អត់ឲ្យដើរទៅណាទេ។

**ស៖** បាទ ខ្ញុំសូមអរគុណ។ ឥឡូវយើងនឹងត្រឡប់មកនិយាយអំពីអ្វីដែលយើងនិយាយមុនពេលសម្រាកអម្បាញ់មិញនេះ។ គឺថាអ្នកស្រីបានលើកឡើងថា លោក ខៀវ សំផន ទៅធ្វើការនៅមន្ទីរ ក-៣ ហើយលោកស្រីនៅ ក-១ តើនៅពេលណាមួយនោះលោកស្រីបានទៅជួបគាត់នៅ ក-៣ ដែរឬទេ ឬក៏លោកស្រីស្នាក់នៅក-១ ដដែល?

**ឆ៖** ពេលនោះខ្ញុំនៅក-១ ដដែល ដល់កូនខ្ញុំបានប្រហែលបាន ២ខែ, ៣ខែ ថា២ខែចុះ បានខ្ញុំទៅ ក-៣ ជួបគាត់។ ជួបនៅ ក-៣។

**ស៖** ហេតុអ្វីក៏អ្នកស្រីមិនទៅតាមគាត់នៅមន្ទីរ ក-៣ ភ្លាមៗទៅ ឬក៏មានហេតុផលពិសេសណាមួយដែលអ្នកស្រីមិនអាចទៅបាន?

[១៥:១៩:២៤]

**ឆ៖** ពេលនោះខ្ញុំក៏អត់ដឹងជាហេតុផលអីដែរ ការរៀបចំខាងមន្ទីរខាង គេសម្រេចថាឲ្យនៅ គឺនៅ សម្រេចថាឲ្យត្រូវទៅគឺទៅ។ ដូច្នេះ ខ្ញុំអត់មានដឹងហេតុផលអីដែលចំពោះផ្ទាល់ខ្លួនទេ។

**ស៖** បាទ ដូច្នេះ គឺថា២ខែក្រោយមក អ្នកស្រីទៅមន្ទីរ ក-៣។ អ៊ីចឹងខ្ញុំសួរពីលក្ខខណ្ឌរស់នៅមន្ទីរក-៣។ តើលក្ខខណ្ឌយ៉ាងម៉េចដែរអ្នកស្រី?

**ឆ៖** ខ្ញុំទៅដល់ ក-៣ ខ្ញុំឃើញប្ដីខ្ញុំរស់នៅផ្ទះឈើមួយពុក ទ្វារក៏អត់ សូម្បីតែជណ្ដើរក៏ពុកដែរ ហើយបង្គន់ក៏អត់ទ្វារដែរ។ ដូច្នេះ ពេលនោះ ខ្ញុំអត់ទៅនៅជាមួយគាត់ទេ ពីព្រោះអីផ្ទះ នៅមិនកើតទេ។

ហើយគាត់ក៏និយាយដែរ គាត់ថា "មិនបាច់មកនៅហ្នឹងទេ។ ផ្ទះពុក ហើយអត់មានទ្វារ"។ ហើយខ្ញុំត្រូវអ៊ីចឹងទៅ។ ខ្ញុំថា "អ៊ីចឹង ខ្ញុំនៅជាមួយប្រពន្ធតា នួន ជា។ ផ្ទះគាត់មានបន្ទប់មានអី"។ ខ្ញុំក៏នៅជាមួយប្រពន្ធតា នួន ជា នៅជាប់ផ្ទះបាយ។ ហើយប្រហែលជា -- ហើយអត់បានទៅនៅជាមួយគាត់ទេ។

ប្រហែលជាប៉ុន្មានខែក្រោយ ឬពីរបីខែក្រោយ ឮថា តាប៉ុល ពត ឲ្យរៀបចំផ្ទះមួយ។ ថា "មិត្តហែម ឯងទៅនៅអ៊ីចឹង? ហើយរៀបចំផ្ទះមួយឲ្យគាត់ទៅ សមរម្យ"។ បានឃើញអ្នកនេះ គេរៀបចំផ្ទះមួយ មកជិតផ្ទះបាយឆ្លងផ្ទះមួយល្វែង ឆ្លងផ្លូវមួយល្វែងផ្ទះ ហើយឆ្លងមកម្ខាងៗ អាហ្នឹងទៅនៅខាងជើង នៅខាងជើងផ្ទះដែលនៅហ្នឹង។ ឆ្លងមកម្ខាងបានរៀបចំផ្ទះហ្នឹងហើយ បានគេឲ្យខ្ញុំមកនៅជាមួយគាត់។ ហើយស្ថានការណ៍ពេលនោះក៏ពិបាកនេះដែរ ព្រោះអីនៅមានការអត់បាយ អត់នេះ វាមិនសូវមានបាយមានទឹកអី។ ទឹកមាន ប៉ុន្តែវាមិនសូវមានអង្ករហូបគ្រប់គ្រាន់ទេ។ ពេលខ្លះហូបនំប៉័ង បាយមួយពេល ហើយអ្នកដឹកនាំក៏ហូបអ៊ីចឹងដែរ ហើយម្ហូបគឺមានតែសម្លកកូរប្រហើរដូចគ្នា។ អត់មានម្ហូបអីពិសេស ស្អីពិសេសអត់ទេ។ ហើយគេរៀបផ្ទះថ្មមួយដែលឲ្យហ្នឹង គឺដំបូលកាត់ មានមួយជាន់។

[១៥:២៣:២១]

**ស៖** ហើយចាប់ពីពេលដែលអ្នកស្រីរួមរស់នៅជាមួយគាត់នៅក្នុងផ្ទះថ្មីនុ៎ង ថាផ្ទះដែលលោកស្រីទើបតែរៀបរាប់ថានៅក្នុងមន្ទីរក-៣ហ្នឹង។ តើលក្ខខណ្ឌជីវិតហ្នឹង ប្រសើរជាងមុនទេ ព្រោះថាអង្គាល់នៅ ក-១ នេះ ពុំមានគ្រែអ្វីទេ អ៊ីចឹងកេងនៅផ្ទាល់នឹងដី នៅលើកន្ទេលអីអ៊ីចឹង។ តើលក្ខខណ្ឌនៅរស់នៅ ក-៣ នោះ នៅពេលដែលលោកស្រីបានជួបលោក ខៀវ សំផន នៅធ្វើការនៅមន្ទីរ ក-៣ ហ្នឹង លក្ខខណ្ឌប្រសើរជាងអង្គាល់នៅ ក-១ ឬក៏យ៉ាងម៉េច?

**ឆ៖** ខ្ញុំសូមជម្រាប ផ្ទះគឺល្អគួរសម ជាផ្ទះថ្ម ប៉ុន្តែគ្មានគ្រែ គ្មានស្អីទេ ពូកអីក៏គ្មានទេ គឺដេកក្រាលកន្ទេលធម្មតា ឥដ្ឋ។ តុក៏អត់ដែរ។ កូនស្រីខ្ញុំលំបាក ក្តៅ យប់អត់បានដេកទេ គាត់ជួយមើល ជួយព ដល់ជិតភ្លឺបានៗដេក។ ដល់អ៊ីចឹងសុំគ្រែឫស្សី។ ដាច់ចិត្តថា អ្ហឺ! សុំគ្រែឫស្សីគេ គេរកគ្រែឫស្សីណាបានមួយមកឲ្យខ្ញុំ។ ខ្ញុំក៏សុំគ្រែឫស្សីមួយមកក្តៅណាស់ ក៏សុំគ្រែឫស្សីគេមួយ គេក៏រកបានឲ្យគ្រែឫស្សីបន្ទះ ដាក់បន្ទះតូចៗធំដែរ លើកដាក់ៗក្បែរជញ្ជាំង ហើយសម្រាកទាំងអស់គ្នាហ្នឹង ឲ្យវាល្ហើយ អត់ក្រាលកន្ទេល។ ហើយកូនខ្ញុំ វាក្តៅ វានៅតែយំអ៊ីចឹង រហូតដល់ធំនេះ ១ឆ្នាំនេះហ្នឹងបានវា -- ខ្ញុំរួចទៅខ្ញុំយកអា-- សុំអង្រឹងឲ្យគេរកអង្រឹងនេះដែកហ្នឹង យកមកចងអង្រឹងយោល។ ដល់ពេលហ្នឹងគាត់ក៏មិន -- អត់មាត់ទេ គ្រាន់តែថា "ហ៊ឺ! កូនអើយដេកទៅ"។ ពរកូននៅជិតបង្អួចកោសពោះ ជួយពរម្តងម្នាក់ៗ

រហូតដល់កូនដេក បានជិតភ្លឺហើយ គាត់ក៏មិនសូវបានសម្រាក ខ្ញុំក៏មិនសូវបានសម្រាកដែរយប់ៗនោះ។ ដូច្នេះជីវិតខ្ញុំឃើញអ៊ីចឹង ខ្ញុំអត់ចង់មកសាឡើងវិញទេ។ មិនស្រួលទេ នៅក្នុងព្រៃក៏ដូចអ៊ីចឹង ហើយមកនៅមានគេរំដោះហើយក៏មិនទាន់ មិនមានផ្ទះទេ។

[១៥:២៦:៤៦]

**ស៖** លោកស្រីទើបតែនិយាយអំពីកូនស្រីរបស់លោកស្រី ហើយចុះកូនទី១ដែលកើតមុនហ្នឹង តើកូនប្រុសហ្នឹងនៅមន្ទីរក-៣ ជាមួយលោកស្រី និងលោក ខៀវ សំផន ដែរឬក៏អត់?

**ឆ៖** ប្រុស គេសម្រេចឲ្យទៅនៅកន្លែងកុមារ។ អាយុត្រឹមតែបាន៣ឆ្នាំ ជិត៣ឆ្នាំ។ ហើយយើងខ្ញុំគេសម្រេចអ៊ីចឹងហើយ ក៏ធ្វើម៉េចអាណិតកូនដែរ ប៉ុន្តែធ្វើម៉េច ជាទូទៅគេនៅអ៊ីចឹង ត្រូវតែទៅនៅ។ អាណិតកូន នឹកកូនដែរ ប៉ុន្តែធ្វើម៉េច។ តាំងពីហ្នឹងមក កូនទៅនៅមណ្ឌលកុមារ ក្នុង១ខែហ្នឹង ឲ្យដូចជាឈឿង ឬក៏ពីណាទេនៅ? ថាទៅសុំយកមកលេងម្តង លេងមកបាន១អាទិត្យ ត្រឡប់ទៅវិញ វាយំ។ អាណិតកូន។

**ស៖** តើអ្នកណាជាអ្នកសម្រេចបញ្ជូនកូនប្រុសហ្នឹងទៅកន្លែងគេថែរក្សាកុមារហ្នឹង? អ្នកស្រីដឹងថាសេចក្តីសម្រេចចេញពីមកពីខាងណាទេ?

**ឆ៖** កាលហ្នឹងខាងៗផ្នែកមន្ទីរ។ អ្នកនៅមន្ទីរហ្នឹង ថាគេសម្រេចខាងលើយ៉ាងម៉េច គាត់ក៏ធ្វើតាមអ៊ីចឹង។ ហើយខ្ញុំបាននិយាយដែរ ខ្ញុំថាចាំឲ្យវាធំបន្តិចទៀតទៅអ៊ី ៤ឆ្នាំអីទៅ។ គាត់ថា ទេគេសម្រេចអ៊ីចឹង ខ្ញុំម៉េចប៉ាន។ អ៊ីចឹងក៏ទៅៗ យកកូនទៅ វាអត់ចង់ទៅ វាយំ តោងជាប់។

[១៥:២៨:២៤]

**ស៖** លោកស្រីបាននិយាយថា កាលពីដំបូង អ្នកដែលនៅក-១នោះបានចេញទៅនៅក-៣ទាំងអស់គ្នា។ តើអ្នកដែលនៅក-៣នោះ ដែលនៅពីហ្នឹងស្រាប់ហើយហ្នឹង គាត់នៅតែបន្តនៅក-៣ ជាមួយពួកលោកស្រីដែលបានទៅពេលក្រោយទេ ឬក៏មានការប្រែប្រួលផ្លាស់ប្តូរយ៉ាងម៉េចដែរ?

**ឆ៖** នៅប្រហែលជាបួនប្រាំខែ ក៏មិនដល់ ខ្ញុំក៏មិនៗចាំច្បាស់ រួចទៅក៏ខាងលោកតា នួន ជា, តា ប៉ុល ពត ហើយនិងមួយចំនួនដូចជា តាអៀង សារី ប្រពន្ធគាត់, តាសុន សេន ប្រពន្ធគាត់, តា វន វ៉េត, តា-- អ្នកផ្សេងទៀត ខ្ញុំភ្លេចនេះហើយ។ ក្រៅពីនោះក៏គេចេញទាំងអស់ពី ក-៣។ ចេញទៅកន្លែងគេ ទៅក-៣ ទាំងអស់។ ក្រោយមកអត់មានអ្នកណាមកទៀតទេ មានតែតា នួន ជា មកម្តងៗ។ នៅតែប្តីខ្ញុំម្នាក់ឯង។

**ស៖** បាទ ខ្ញុំសោកស្ដាយណាស់ដែល ឥឡូវខ្ញុំសូមលោកស្រីផ្ដល់ព័ត៌មានលម្អិត ព្រោះថាខ្ញុំអត់យល់ទេអ្វីដែលលោកស្រីបាននិយាយអម្បាញ់មិញនោះ ប្រហែលជាមានការលំបាកក្នុងការបកប្រែក៏មិនដឹង។ ឥឡូវខ្ញុំព្យាយាមសួរម្ដងទៀត។ សំណួរខ្ញុំអម្បាញ់មិញ គឺចង់ដឹងថា តើលោកស្រី នៅពេលដែលលោកស្រីមកដល់ក-៣ ដើម្បីជួបលោក ខៀវ សំផន លោកបានឆ្លើយថា លោកស្រីនៅជាមួយប្រពន្ធរបស់លោក នួន ជា។ ថាពីដើមទីនោះ ពីដំបូងថា លោកស្រីរស់នៅជាមួយប្រពន្ធលោក នួន ជា នៅជិតចង្ក្រានបាយ នៅក-៣ ហ្នឹងអ៊ីចឹងមែនទេ?

[១៥:៣១:៤៨]

**ឆ៖** មែន។

**ស៖** បាទ អ៊ីចឹងនៅពេលហ្នឹង នៅពេលដែលលោកស្រីបានទៅដល់ក-៣ តើមានមេដឹកនាំផ្សេងទៀតដែលរស់នៅមន្ទីរក-៣ នេះទេ ពេលដែលលោកស្រីទើបតែទៅដល់ហ្នឹង?

**ឆ៖** ពេលដែលខ្ញុំទៅដល់ គឺឃើញអ្នកដឹកនាំនៅកន្លែងហ្នឹងទាំងអស់។

**ស៖** តើមេដឹកនាំទាំងអស់ហ្នឹងនៅទីនុំងអស់រយៈពេលប៉ុន្មាន? ពួកគេ -- ពួកគាត់ទាំងអស់នុំងនៅទីនោះរហូតដល់កងទ័ពខ្មែរក្រហមចូលមកដល់ភ្នំពេញ ឬក៏យ៉ាងម៉េច? សូមលោកស្រីបញ្ជាក់។

**ឆ៖** សូមទោសលោកប្រធាន ខ្ញុំអត់យល់។ ពេលនៅកន្លែងហ្នឹងមានខ្មែរក្រហមមកដល់អាម៉េច? ខ្ញុំដូចអត់យល់ត្រង់ហ្នឹង។

**ស៖** បាទ ខ្ញុំសូមសួរឡើងវិញ។ បាទ អម្បាញ់មិញខ្ញុំចង់ដឹងថា អ៊ីចេះថា មេដឹកនាំខ្មែរក្រហមនៅក-៣ នៅពេលដែលអ្នកស្រីមកដល់។ អ៊ីចឹងខ្ញុំចង់ដឹងថា តើពួកគាត់នេះនៅតែបន្តរស់នៅក-៣ នេះអស់រយៈពេលយូរដែរទេ នៅមន្ទីរក-៣នេះ?

**ឆ៖** ពួកគាត់នៅមន្ទីរក-៣ អស់រយៈប្រហែលជា៤ ឬ៥ខែអីប៉ុណ្ណឹងទេ។ រួចពួកគាត់ចេញទាំងអស់ ចេញពីកន្លែងហ្នឹងទាំងអស់ទៅវិញ។ នៅតែប្ដីខ្ញុំទេ នៅកន្លែងក-៣។

[១៥:៣៣:៥២]

**ស៖** បាទ អ៊ីចឹងមេដឹកនាំទាំងអស់ហ្នឹងចេញទៅណាដែរ? អ្នកស្រីដឹងដែរឬទេ ពួកគាត់ទៅណាដែរ? ចេញទៅណា?

**ឆ៖** ចេញទៅតាមកន្លែងរៀងរបស់គាត់រៀងខ្លួន គឺពួកគាត់សុទ្ធតែមានមន្ទីរ ក្រសួង ការកាន់កាប់។ ទៅកន្លែងហ្នឹង តាមខ្ញុំដឹងគឺគ្រាន់តែស្នាក់ដើម្បីរៀបចំកន្លែង ហើយទៅស្នាក់កន្លែងស្ងាត់តែប៉ុណ្ណឹង

ទេ។ ហើយតា ប៉ុល ពត, នួន ជា លោកនៅកន្លែង ក-១។ ហើយអ្នកផ្សេង គឺនៅកន្លែងក្រសួងរបស់គេរៀងៗខ្លួន ហ្នឹងតាមខ្ញុំដឹងក្រោយមក ឮថាគាត់ទៅនៅតាមក្រសួងកន្លែងរបស់គាត់អ៊ីចឹង។

**ស៖** បាទ លោកស្រី និងលោក ខៀវ សំផន បន្តរស់នៅមន្ទីរក-៣ នេះរហូតដល់ពេលណាដែរ?

**ឆ៖** នាងខ្ញុំរស់នៅជាមួយគាត់រហូតដល់ពេលវៀតណាមចូលកាន់កាប់។

**ស៖** តើអ្នកស្រីអាចរៀបរាប់បានទេអំពីសកម្មភាពរបស់លោកស្រីនៅមន្ទីរ ក-៣ ហើយនិងមុខងាររបស់លោកស្រី?

[១៥:៣៥:៤០]

**ឆ៖** ខ្ញុំសូមជម្រាបនៅ ក-៣ មុខងារដែលនាងខ្ញុំនេះ គឺមានតែដាំបាយឲ្យប្ដី ហើយនិងមើលកូន។ មានតែពីរហ្នឹងទេ។

**ស៖** តើលោកស្រី ពេលនោះមានដឹងថាលោក ខៀវ សំផន ធ្វើអីទេរាល់ថ្ងៃ ពេលថ្ងៃៗ?

**ឆ៖** ជារៀងរាល់ថ្ងៃ គាត់នៅម្នាក់ឯង គឺពេលដែលខ្ញុំមកធ្វើបបរបោសច្រាសផ្ទះបាយ ព្រោះត្រូវសម្អាតរាល់ថ្ងៃ។ រៀងរាល់ថ្ងៃគាត់តែងតែពរកូនស្រីហ្នឹង អាកណ្ដាលហ្នឹង ពង្វូតទឹកង្វូតអីហើយពចុះមកទៅកន្លែងធ្វើការគាត់ជារៀងរាល់ថ្ងៃមិនដែលខានទេ។ រួចទៅ បើមានការអីគាត់ ក៏យកមកដាក់ឲ្យខ្ញុំនៅផ្ទះបាយ។ ខ្ញុំមិនដែលទៅកន្លែងធ្វើការគាត់ទេ។ ពេលនោះ ខ្ញុំក៏អត់ទាន់ដឹងថាការងារគាត់ស្អីនោះទេ។ ប៉ុន្តែកូនស្រីខ្ញុំទៅជាមួយគាត់ញឹកញាប់។ អ៊ីចឹងទៅ កាលនោះវានៅចេះនិយាយតិចៗ។ និយាយមិនច្បាស់ទេ។ ហើយវាត្រឡប់មកវិញ អាហ្នឹងយូរដែលបានវាត្រឡប់មកវិញ មានអីស្អីអ៊ីចឹងទៅ វាចេះតែកាន់ធ្វើ។ វាចេះតែនិយាយថាស្អី "ណូៗ" ហ្នឹងគឺនិយាយដូចនិយាយទូរស័ព្ទអ៊ីចឹង។ ហើយខ្ញុំក៏សួរថា "ពុកស្អី ណូៗហ្នឹង?"។ វាចេះនិយាយអីហ្នឹង "ណូៗតុមួយ។ នាបម៉ាន់ៗម៉េច?" អាហ្នឹងខ្ញុំឆ្ងល់។ តែវាមក វានិយាយតែអ៊ីចឹង។

[១៥:៣៧:៤៦]

បានខ្ញុំសួរគាត់ គាត់ថា "អឺ ពួកហ្នឹង ពួកអ្នកដែលនៅហ្នឹង គាត់ឲ្យទូរស័ព្ទរៀបអីវ៉ាន់ហ្នឹងណា។ គ្រាន់តែវាទៅ វាឮ ហើយឲ្យគេរៀបអីវ៉ាន់ គេត្រូវការអីវ៉ាន់ ស្នើអីវ៉ាន់ពីកន្លែងឃ្លាំងទៅ។ ដាក់នៅតាមមូលដ្ឋានហ្នឹងណា។ ដល់អ៊ីចឹងឲ្យគេរៀបឲ្យហ្នឹង វានិយាយតាមគេហ្នឹង"។ ហើយខ្ញុំថា "អ៊ីចឹង កន្លែងហ្នឹងរៀបអីវ៉ាន់?" គាត់ថា "ខ្ញុំរៀបអីវ៉ាន់ហ្នឹង តែគេត្រូវការអីវ៉ាន់អីហ្នឹង យើងរៀបឲ្យគេហ្នឹងណា"។ អ៊ីចឹងហើយខ្ញុំនឹកឃើញថា បែបអាហ្នឹងកន្លែងគាត់រៀបអីវ៉ាន់ប៉ុណ្ណឹងហើយ។ ចេះតែនិយាយតៗមក។

គាត់ថា គាត់រៀបអីវ៉ាន់គ្រប់មុខទាំងអស់ តាំងពីអំបិល ប្រហុក ខោអាវ ចានឆ្នាំង យកទៅមូលដ្ឋាន ដឹកទៅមូលដ្ឋាន។ អាហ្នឹងគាត់ប្រាប់ខ្ញុំ។ អាហ្នឹងខ្ញុំដឹងពេលហ្នឹងទេ ពីមុនមក ខ្ញុំអត់ដែលបានទៅទេ ពីព្រោះខ្ញុំរវល់ណាស់នៅផ្ទះបាយម្នាក់ឯងម្យ៉ាង ហើយកូនផង អីផង។ ហើយខោអាវ គក់ខោអាវ គក់អីខ្លួនឯងទាំងអស់ អត់មាននេះទេ។ អីចឹងដឹងការងារគាត់ ដោយសារអីចឹងទេ។ ហើយគាត់តែហើយៗ គាត់ពកូនមកវិញហើយ ហូបបបរអីហើយ។ ជួនកាលទៅផ្ទះ ជួនកាលគាត់ទៅកន្លែងគាត់ហ្នឹងទៅ ទៅកន្លែងធ្វើការគាត់ទៅ យកវាទៅវិញ ដឹកដៃវាទៅវិញទៀតទៅ។

[១៥:៣៩:២២]

**ស៖** តើលោក ខៀវ សំផន អវត្តមានញឹកញាប់ទេនៅមន្ទីរ ក-៣?

**ឆ៖** ដូចមិនមានចេញទៅណាញឹកញាប់ទេ។ ជួនកាល ខ្ញុំតាមខ្ញុំដឹងនេះ ដូចជាគាត់ទៅ ក-១ ទៅអីអីចឹងម្ដងម្កាល។ ហើយកម្រទៅនេះទេ មកហូបបាយហូបអីវិញអីចឹង។ មិនដែលអត់ទេ។

**ស៖** តើនៅពេលដែលគាត់ចេញពីមន្ទីរ ក-៣ នោះតើមានកងការពារ ឬក៏អង្គរក្សអីការពារគាត់ទេ?

**ឆ៖** អត់មានទេ។

**ស៖** អីចឹងគាត់ធ្វើដំណើរយ៉ាងម៉េចទៅ?

**ឆ៖** គាត់មានអ្នកបើកឡាំប៉ាតាៗគឺដូចជាកង់បួន អត់មានជញ្ជាំងទេ ជិះពីក្រោយទៅអីចឹង។ ហ្នឹងគាត់ជិះតែអាហ្នឹង អត់មានឡាន អត់មានជាឡានស្អីល្អ ឬក៏ប្រណីតអីអត់មានទេ។

**ស៖** បាទ នៅពេលចាប់ពីពេលដែលមេដឹកនាំខ្មែរក្រហមចេញពីក-៣ នេះទៅ តើមានមនុស្សរស់នៅក-៣ ច្រើនទេ? ហើយមានសកម្មភាពនៅមន្ទីរក-៣ ច្រើនទេ មានការិយាល័យច្រើនទេ? មានបុគ្គលិកច្រើនទេ? ហើយគេមកធ្វើការញឹកញាប់ទេ នៅមន្ទីរ ក-៣ នោះ? តើនៅមន្ទីរ ក-៣ មានសកម្មភាពច្រើនទេ បើតាមការសង្កេតរបស់អ្នកស្រី?

[១៥:៤១:៤៣]

**ឆ៖** នៅមន្ទីរក-៣ គឺស្ងាត់ឈឹងអត់មានអ្នកណាចេញចូល ហើយក៏នៅគ្នាតិច។ ហើយខ្ញុំនៅពីរនាក់ មានម្នាក់ទៀតគាត់កូនខ្ចីដែរឈ្មោះ អឿន។ នៅតែពីរនាក់ហ្នឹងទេ។ ដល់អ្នកការពារអ្នកនេះ គេមានតែនៅខាងក្រៅ។ តែប៉ុន្មាននាក់ខ្ញុំអត់ដឹងទេ។ នៅខាងក្រៅទេ នៅខាងក្នុងហ្នឹង ប៉ុន្តែផ្នែកផ្សេងគ្នា។ នៅដោយឡែកពីគ្នា។ ឯខ្ញុំនៅក្នុងហ្នឹងគឺអត់មានគ្នាច្រើនទេ។ មានតែពីរបីនាក់។

**ស៖** បាទពីរបីនាក់ហ្នឹងអ្នកស្រីចង់និយាយយ៉ាងម៉េចដែរ មានចំនួនប៉ុន្មានអាចផ្ដល់ចំនួនប្រហាក់ប្រហែលបានទេ ចន្លោះពីប៉ុន្មានទៅប៉ុន្មាននាក់ដែរ?

**ឆ៖** មានគាត់ ហើយនិងអ្នកដែលនៅជាមួយគាត់ហ្នឹងដូចជាពីរនាក់។ ពីរនាក់ អ្នកនៅកន្លែងទូរស័ព្ទរៀបអីវ៉ាន់ ហ្នឹងហើយខ្ញុំ ហើយនិងឈ្មោះ អឿន មួយទៀត។ ហើយក្រៅពីនោះមិនមានទេ មានតែគេនៅខាងក្រៅ។

**ស៖** អ្នកដែលនៅខាងក្រៅនោះ គឺជាអ្នកយាមឬក៏យ៉ាងម៉េចលោកស្រី?

**ឆ៖** ខាងក្រៅហ្នឹងគឺការងារអីខ្ញុំអត់ដឹងទេ ប៉ុន្តែអាចយាមតាមមើល មិនច្បាស់។

**ស៖** លោកស្រីបានលើកឡើងថាលោកស្រីបានស្នាក់នៅភ្នំពេញរហូតដល់វៀតណាមចូល។ តើលោកស្រីអាចរៀបរាប់បានទេ អំពីរបៀបដែលលោកស្រីចាកចេញពីទីក្រុងភ្នំពេញ ឬក៏លោកស្រី មិនបានចាកចេញពីទីក្រុងភ្នំពេញទេ? បានសូមអញ្ជើញរៀបរាប់។

[១៥:៤៤:៣៩]

**ឆ៖** ក្រោយវៀតណាមចូលថ្ងៃ ខ្ញុំសម្រាលកូនមួយទៀតបានពីរថ្ងៃ ខ្ញុំត្រូវចេញ។ ខ្ញុំត្រូវចេញទៅ -- កាលនោះគាត់ទៅយកខ្ញុំជាមួយ ឈឿង យកពីពេទ្យមកហើយ រៀបចំឲ្យជិះរទេះភ្លើង ថ្ងៃ០៤ ខ្ញុំសម្រាលថ្ងៃ២។ ភ្លេចហើយ។ ខ្ញុំត្រូវចេញល្ងាចថ្ងៃ០៤ ឬថ្ងៃណាទេ ខ្ញុំភ្លេចហើយនេះ។ ខ្ញុំសម្រាលថ្ងៃ០៤ ដល់ថ្ងៃ០៦។ ល្ងាចថ្ងៃ០៦ហ្នឹង បើខ្ញុំសម្រាលថ្ងៃ០៤ ល្ងាចថ្ងៃ០៦ គាត់ទៅយកខ្ញុំជាមួយនឹង ឈឿង ហើយជូនទៅដាក់នៅរ៉ារទេះភ្លើងហើយ ហើយឲ្យជិះរទេះភ្លើងជាមួយនឹងកូនពីរនាក់ទៀត។ ហ្នឹងទៅយកកូនពីកន្លែងមណ្ឌលកុមារមក ត្រូវចេញទាំងយប់ហ្នឹង ហើយខ្ញុំកូនខ្ចី ទើបតែបាន២ថ្ងៃ។ អ៊ីចឹងជិះរទេះភ្លើងរហូត ចេញទៅរហូត ហើយគាត់ គាត់ថា “គាត់យប់ហ្នឹង ក៏គាត់ចេញទៅដែរ” ថាអ៊ីចឹង។ ចេញទៅរហូតពេលហ្នឹង អត់មាននេះទេ គឺអត់មានដែលជួបគាត់ទេ។ រហូតដល់ចេញដំណើរទៅដល់ស្រុកអាចម៍រមាស ហើយក៏រទេះភ្លើងគេឈប់ត្រឹមហ្នឹង អត់មានអីទៅទៀត។ បានលោក សួរ ហុង ទៅយក -- ទៅមើលទៅឃើញហើយ ដឹកខ្ញុំយកមកបាត់ដំបង។

[១៥:៤៧:០៦]

ពេលនោះ ខ្ញុំគ្រុនផង ក្ដៅផង អត់ដឹង អត់ដឹងខ្លួនទេ គេចាក់ថ្នាំចាក់អីទៅ ព្រលឹមឡើងបានដឹងហើយចាប់ផ្ដើមទៅធ្វើដំណើរដល់ស្វាយទៀត។ ហើយទៅដល់ស្វាយ ចាប់ពីហ្នឹងទៅ ប្រហែលជាថ្ងៃ ១១, ១២, ១៣ បានវៀតណាមចូលមក។ ចាប់ផ្ដើមចេញពីស្វាយ រត់រហូត ដើររហូតទៅ រហូតដល់

ព្រំដែន តាមព្រំដែនរហូត។ បាន៧ខែ អាកូនប្រុសខ្ញុំហ្នឹងក៏ស្លាប់។ នេះស្លាប់នៅខែ៧ហ្នឹង ហើយអត់ដែលបានជួបគាត់ម្តងទេ។ អាកូនស្លាប់ក៏មិនដែលឃើញមុខដែរ។

**ស៖** បាទ លោកស្រី ឥឡូវខ្ញុំសូមត្រឡប់មកនិយាយមកក្រោយវិញ ខ្ញុំចង់ដឹងថា លោកស្រីស្គាល់ឈ្មោះ ឌឿន ទេ?

**ឆ៖** មកនៅ ក-៣ ទើបឮឈ្មោះ ឌឿន ហើយឃើញដែរ ឃើញនៅហ្នឹងប្រហែលជាតិដែរទេ។ ហើយគាត់ហ្នឹង អត់សូវនៅកន្លែងផង ឃើញតែគាត់ចេញចូលនៅក្នុងរយៈពេលប៉ុន្មានខែ ដល់នេះទៅ ក៏ទៅកន្លែងគេបាត់អស់ ទាំងអស់គ្នាទៅ។ ហើយជាក់ស្តែងអត់មានដែលបាននិយាយគ្នានេះទេ គ្រាន់តែឃើញ ហើយក៏អត់ស្គាល់អីច្បាស់លាស់ អត់ទេ។ គ្រាន់តែឃើញប៉ុណ្ណឹង។

[១៥:៤៩:០៣]

**ស៖** តើលោកស្រីដឹងអំពីសកម្មភាពរបស់ ឌឿន នេះទេ? សកម្មភាពជាក់លាក់គាត់អ្វីដែរ នៅ ក-៣?

**ឆ៖** ចាស ខ្ញុំអត់ដឹងទេ។

**លោក អាកទួរ វ៉ែកកែន៖**

បាទ លោកប្រធាន ខ្ញុំសួរចប់ហើយ លោកប្រធាន។ សូមអរគុណ។ សូមអរគុណលោកស្រី។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

**លោក អាកទួរ វ៉ែកកែន៖**

បាទ លោកប្រធាន ខ្ញុំសូមសួរមួយសំណួរទៀត លោកប្រធាន។

[១៥:៤៩:៥៤]

**សួរដោយលោក អាកទួរ វ៉ែកកែន៖**

**ស៖** លោកស្រីជាសំណួរចុងក្រោយ។ តើលោកស្រី -- លោកស្រីអាចជម្រាបជូនតុលាការបានដែរឬទេ ថាហេតុអីបានជាលោកស្រីមកទីនេះ? ហើយស្វាមីរបស់លោកស្រីត្រូវបានចោទកាន់ពីឧក្រិដ្ឋកម្មដ៏ធ្ងន់ធ្ងរ។ វត្តមានរបស់លោកស្រីនៅទីនេះគឺដើម្បីគាំទ្រដល់ស្វាមីរបស់លោកស្រី។ លោកស្រីចង់ពន្យល់ទៅតុលាការពីមូលហេតុដែលលោកស្រីចង់គាំទ្រដល់ប្តី ស្វាមីរបស់លោកស្រីឬក៏អត់ ឬក៏យ៉ាងម៉េច?

**ឆ៖** ខ្ញុំចង់ជម្រាបលោកប្រធានតុលាការ ខ្ញុំមកនេះគឺចង់បង្ហាញថាប្ដីរបស់ខ្ញុំ ទោះបីតុលាការត្រូវដាក់ទោសទៅ គេចោទប្រកាន់យ៉ាងម៉េចក៏ដោយ ប៉ុន្តែខ្លួនខ្ញុំផ្ទាល់គឺចង់បង្ហាញថាប្ដីខ្ញុំជាមនុស្សយ៉ាងម៉េច ខ្ញុំដឹង។ គឺថាមនុស្សស្លូតបូត រាបសា ទន់ភ្លន់ មិនប្រកាន់អ្នកណាក៏ដោយ មិនថាអ្នកក្រ អ្នកមាន គឺប្ដីខ្ញុំត្រូវទាំងអស់។ ហើយទោះបីជាលំបាកវេទនានៅក្នុងព្រៃមួយរយៈកាលដែលខ្ញុំ និងគាត់បានចាប់ដៃគ្នាជាប្ដីប្រពន្ធមក ខ្ញុំឃើញប្ដីខ្ញុំស្មោះត្រង់ ខ្ញុំជឿជាក់ស្មោះត្រង់ ទោះបីតុលាការចោទប្រកាន់ ឬក៏អ្នកណាចោទប្រកាន់យ៉ាងម៉េចក៏ដោយ ខ្ញុំសូមអះអាង ខ្ញុំជាប្រពន្ធ គឺមិនមែនស្រួលដូចងាយៗដូចអ្នកទាំងអស់គ្នាមើលឃើញនោះទេ គឺលំបាកណាស់។ លំបាកទាំងនៅក្នុងព្រៃ ជីវភាព លំបាកទាំងការរស់នៅ រត់លូនរហូតមកដល់មានផ្ទះមានសម្បែង រំដោះហើយ ក៏មិនមានងាយស្រួលដូចអ្នកទាំងអស់គ្នាថានោះទេ គឺលំបាកណាស់។

[១៥:៥២:៤០]

ដូច្នេះ ប្ដីខ្ញុំ បើប្រៀបធៀបនឹង -- នៅក្នុងប្រុសទាំងអស់ ខ្ញុំឃើញប្ដីខ្ញុំល្អជាងគេ។ ជាពិសេសសីលធម៌ គុណធម៌ មិនដែលធ្វើឲ្យខ្ញុំពិបាកចិត្តដោយសារអំពើអីមួយគឺអត់ទេ ហើយស្មោះត្រង់ក្នុងមួយជីវិតនេះ គឺថាគ្មានបុព្វសិទ្ធិស្អីទាំងអស់។ សូម្បីតែផ្ទះ សូម្បីតែរបស់របរប្រើប្រាស់ សូម្បីតែឡាន ដែលអ្នកដឹកនាំទាំងអស់ មានឡាន មានផ្ទះ មានសម្បែង គេស្អាតៗ ប្ដីខ្ញុំអត់ទេ។ មួយជីវិតស្មោះត្រង់ គឺត្រង់តែម្ដង។ ត្រង់នេះហើយ ដែលខ្ញុំជឿជាក់ៗប្ដីខ្ញុំ គឺមិនមែនជាអ្នកឃោឃៅកាប់សម្លាប់ដើរចាប់ដើរចងគេឯងនោះទេ។ ខ្ញុំសូមធានា គឺឃើញ ខ្ញុំឃើញជាក់ស្ដែង ហើយខ្ញុំក៏រស់នៅលំបាកវេទនា ហើយជួយខ្ញុំក្នុងរយៈពេល៣ឆ្នាំ កូនចៅយ៉ាងម៉េច អត់យ៉ាងម៉េចក៏ដោយ ព្រោះគាត់អាណិតខ្ញុំណាស់។ ខ្ញុំជាស្រីលំបាកណាស់។

[១៥:៥៤:២២]

ហើយខ្ញុំដឹងហើយថាបងប្អូនរងគ្រោះ ដែលនៅកន្លែងជម្លៀស ដែលនៅកន្លែងការដ្ឋាន គេបង្អត់បាយបង្អត់ទឹក តែខ្ញុំក៏មានការលំបាកដូចតែគ្នាដែរ។ តែក្នុងហ្នឹង តើហេតុអីបានវាមានអ៊ីចឹង។ ខ្ញុំសូមតុលាការវិនិច្ឆ័យតាមហ្នឹងចុះ ពីព្រោះខ្ញុំធានាប្ដីខ្ញុំថា មានជាអ្នកឃោរឃៅកាប់សម្លាប់ ឬក៏ធ្វើអីដោយអំពើចោកទាប ដើរចាប់ចង មានអំណាច លោភលន់ បុណ្យស័ក្តិ គឺអត់មានទាំងអស់។ រស់នៅជាក់ស្ដែងតាំងពីឆ្នាំមុន៧៥ ក្រោយរំដោះ៧៥ ជាក់ស្ដែងដូចខ្ញុំបាននិយាយរួចមកហើយ ហើយនិងពេលដែលវៀតណាមចូល មិនដែលបានជួបគ្នាម្ដងណាសោះរហូតដល់ឆ្នាំ៨៣។ ៨២-៨៣ បែកគ្នារហូត ហើយ

ជួប ហើយក៏មួយភ្លែតក៏បែកគ្នាតទៀត។

**ស៖** លោកស្រីបាទ! ខ្ញុំសូមសំណួរចុងក្រោយដែលបន្ទាប់ពីស្តាប់លោកស្រីអំមិញនេះ ខ្ញុំចង់ចោទសំណួរមួយទៀត។ បាទ កាលពីដើមសវនាការនេះ លោក -- គាត់បានសួរលោកស្រីថាតើលោកស្រីបានធ្វើអ្វី? លោកស្រីបានឆ្លើយថាលោកស្រីជាមេគ្រួសារ។ អ៊ីចឹងខ្ញុំសួរលោកស្រីថា តើកម្រិតជីវភាពរបស់លោកស្រីយ៉ាងម៉េចដែរ ហើយរស់នៅនោះតាមរបៀបណា? មធ្យោបាយអីដើម្បីរស់រានមានជីវិតនេះ?

[១៥:៥៦:៤៥]

**ប្រធានអង្គជំនុំ៖**

លោកស្រី សុជាតិ កុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក ឃីត រេយ៉ន័រ៖**

លោកប្រធាន សំណួរទាំងអស់នេះ គឺដូចជាមិនពាក់ព័ន្ធទៅនឹងបញ្ហាអ្វីនៅក្នុងបញ្ហារឿងក្តីនោះទេ ហើយក៏មិនពាក់ព័ន្ធទៅនឹងលោក ខៀវ សំផន -- មិនពាក់ព័ន្ធលក្ខណៈអត្តចរិតរបស់លោក ខៀវ សំផន ហើយក៏មិនពាក់ព័ន្ធទៅនឹងបញ្ហាអ្វីទាំងអស់។ ហេតុដូច្នេះហើយ ដោយសារផ្អែកលើមូលដ្ឋានហ្នឹងខ្ញុំសូមជំទាស់ទៅលើសំណួរបែបនេះ។

**លោក អាកទួរ វ៉ែកគែន៖**

លោកប្រធាន ខ្ញុំសូមឆ្លើយតប។ បាទ ខ្ញុំគិតថា ការជំទាស់របស់សហព្រះរាជអាជ្ញានេះពុំមានហេតុផលអ្វីទេ។ ហើយជាការសំខាន់ណាស់ដែលតុលាការយើងនេះដឹងអំពីហៅថា របៀប ឬក៏មធ្យោ-បាយរស់នៅរបស់ប្រពន្ធគាត់នេះ គាត់រស់នៅជាមួយលោក ខៀវ សំផន។ អ៊ីចឹងសំណួរនេះវាស្រួលងាយយល់ទេ។ អ៊ីចឹងចម្លើយក៏អាចឆ្លើយខ្លីដែរ ហើយខ្ញុំចង់ដឹងថាតើគាត់មើលទៅឃើញយ៉ាងម៉េចដែរកូនក្តីខ្ញុំនេះ ព្រោះគាត់ជាអ្នកនៅក្បែរគាត់ជាងគេ។

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:៥៨:១៤]

**ប្រធានអង្គជំនុំ៖**

បាទ សេចក្តីជំទាស់ និងសំអាងហេតុនៃសេចក្តីជំទាស់របស់តំណាងសហព្រះរាជអាជ្ញា មាន

លក្ខណៈសមស្រប ពីព្រោះសំណួរនេះមិនពាក់ព័ន្ធនឹងអត្តចរិតនៃរបស់ជនជាប់ចោទទេ អំពីជីវភាពរាល់ថ្ងៃរបស់សាក្សីនោះ។ ដូច្នេះសាក្សីមិនបាច់ឆ្លើយតបទៅនឹងសំណួរចុងក្រោយនេះទេ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកស្រី សូ សុជាតិ កិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ ដល់ពេលសម្រាកហើយអង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ។ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃអង្គារ ទី១១ ខែមិថុនា ឆ្នាំ២០១៣ ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹកទៅ។

សវនាការនៅថ្ងៃស្អែកនេះ នៅពេលព្រឹកអង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្តាប់សក្ខីកម្មសាក្សី សូ សុជាតិ ដែលនឹងបន្តសួរដេញដោលដោយសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី ហើយនិងអាចមានពេលផ្តល់ពេលវេលាជូនទៅក្រុមមេធាវីការពារក្តី នួន ជា។ ហើយសូមភាគី -- ហើយនិងពេលរសៀល អង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់នៅសក្ខីកម្មសាក្សីដែលមានរហស្សនាម TCW-648។ បាទ សូមភាគីនៃរឿងក្តី ហើយបុគ្គលិកគាំទ្រកិច្ចដំណើរការសវនាការរបស់អង្គជំនុំជម្រះសាលាដំបូង និងសាធារណជនជ្រាប។

[១៥:៥៩:៣៧]

ហើយលោកស្រី សុជាតិ អង្គជំនុំជម្រះស្តាប់នូវសក្ខីកម្មរបស់លោកស្រីមិនទាន់ចប់នៅឡើយទេ អង្គជំនុំជម្រះធ្វើសវនាការស្តាប់លោកស្រីនៅព្រឹកថ្ងៃស្អែកទៀត។ ដូច្នេះ អងង្គជំនុំជម្រះសូមកោះអញ្ជើញលោកស្រីមកបន្តផ្តល់សក្ខីកម្មនៅព្រឹកថ្ងៃស្អែកទៀត ដែលនឹងចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹកទៅ។

មន្ត្រីរដ្ឋបាលតុលាការសម្រាប់សម្រួលជាមួយនឹងមន្ត្រីនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនសាក្សីរូបនេះត្រឡប់ទៅកាន់ទីកន្លែងដែលគាត់ស្នាក់នៅវិញ ហើយនិងឲ្យគាត់ត្រឡប់មកកាន់ទីកន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញនៅថ្ងៃស្អែកវេលាម៉ោងប្រាំបួន។ ហើយសូមអញ្ជើញលោកមេធាវី ម៉ម រិទ្ធា ដែលជាមេធាវីប្រឹក្សាសាក្សីមកចូលរួមជាមួយសាក្សីរូបនេះដែរ។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនពួកគាត់ទាំងពីររូបមកចូលរួមសវនាការនេះវិញនៅព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួន។ ដោយឡែកលោក នួន ជា បង្គាប់ឲ្យនាំខ្លួនមកនៅត្រឹមបន្ទប់ឃុំខ្លួនខាងក្រោម ឲ្យគាត់ចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយតាមមធ្យោបាយសោតទស្សន៍។ សម្រាកចុះ។

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៦:០០ នាទី)*